**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ តេជគុណ **សាំង សាមីត**

លោក **ហូ សេងហុង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ តេជគុណ **សាំង សាមីត**

លោក **ហូ សេងហុង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៦

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

## សេចក្តីថ្លែងអំណរគុណ

ជាបឋម អាត្មាភាព ភិក្ខុ **សាំង សាមីត** និងលោក **ហូ សេងហុង** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច សូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុក និងអ្នកម្តាយដែលបានផ្តល់ កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំណែនាំ និងការឧបត្ថម្ភគ្រប់បែបយ៉ាងទាំងធនធាន (ថវិកា និងសម្ភារៈ) និង ស្មារតីដល់យើងខ្ញុំគ្រប់បែបយ៉ាង រហូតដល់កូនមានឱកាសបានសិក្សារៀនសូត្រដល់ថ្ងៃបញ្ចប់ថ្នាក់មហាវិទ្យាល័យ ដោយលោកទាំងពីរខិតខំ ជំនះរាល់ឧបសគ្គ មិនខ្លាចនឿយហត់ ពុះពារឱ្យកូនបានរៀនសូត្រ មានចំណេះដឹង ខ្ពង់ខ្ពស់ ដើម្បីរស់នៅក្នុងសង្គមប្រកបដោយសុភវិនិច្ឆ័យ។ អាត្មាភាពខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ បណ្ឌិតទាំងអស់ដែលបានខិតខំផ្ទេរចំណេះដឹង និងចំពោះការ ស្វាគមន៍ដ៏រាក់ទាក់ កក់ក្តៅបំផុតក្នុងការជួយសម្រួលផ្នែកឯកសារ ទិន្ន័យ ស្មារតី និងសម្ភារៈផ្សេងៗ ដើម្បីបាន ផ្តល់លទ្ធភាពដល់យើងខ្ញុំក្នុងការបន្តការសិក្សា និងឈានដល់ការសរសេរសារណាប្រកបដោយជោគជ័យពីសំណាក់៖

- ឯកឧត្តម **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងគណៈ គ្រប់គ្រងទាំងអស់ដែលបានខិតខំដឹកនាំសាកលវិទ្យាល័យ និងសម្របសម្រួលរាល់តម្រូវការ នៃការសិក្សារបស់និស្សិត
- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន អប់រំ ណែនាំ ផ្តល់មតិយោបល់ ផ្តល់ឯកសារ និងត្រួតពិនិត្យសារណាស្រាវជ្រាវនេះយ៉ាងយកចិត្តទុកដាក់ និងទឹកចិត្តរីករាយ
  លោក ឆេង ឆៃ ប្រធានក្រុមប្រឹក្សាសង្កាត់ ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល អាណត្តិទី៤ សហការីដែលបានអនុញ្ញាត និងសហការផ្តល់បទសម្ភាស ទិន្ន័យ ព័ត៌មាន និងឯកសារពាក់ព័ន្ធ
- លោកឪពុក និងអ្នកម្តាយ ដែលបានជួយឧបត្ថម្ភគាំទ្រទាំងកម្លាំងកាយចិត្ត និងជួយសម្របសម្រួលដំណើរការសរសេរសារណាគ្រប់បែបយ៉ាង
- មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់គ្នា ដែលបានជម្រុញលើកទឹកចិត្ត ផ្តល់ព័ត៌មាន ពិភាក្សាផ្លាស់ប្តូរយោបល់ ចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗ ក្នុងការស្វែងរកដំណោះស្រាយក្នុងការស្រាវជ្រាវ យើងខ្ញុំសូមថ្លែងអំណរគុណ ជូនពរដល់លោកអ្នកទាំងអស់គ្នា សូមជួបនូវតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិធាន កុំបីឃ្លៀងឃ្លាតឡើយ។ សូមទទួលនូវការគោរពដឹងគុណ និងការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

# អារម្ភកថា

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍដែលគ្រប់វិស័យនៅពុំទាន់មានការអភិវឌ្ឍ បាន រីកចម្រើនធំធាត់ខ្លាំងនៅឡើយ។ ជាក់ស្តែងនៅមួយប្រទេសកម្ពុជាបានធ្វើកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រង រដ្ឋបាសាធារណៈរបស់ខ្លួនតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ដោយហេតុថារដ្ឋបាលសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់កំណែទម្រង់ជាច្រើនលើកច្រើនសាររហូតមកដល់ ពេលបច្ចុប្បន្ននេះ ហើយក្តីក៏រមែងនៅតែមានចំណុចខ្វះខាតមិនទាន់មានភាពល្អប្រសើរនូវឡើយទេ។ ដូច្នេះកម្ពុជា គ្មានជម្រើស ណាល្អប្រសើក្រៅពីការខិតខំប្រឹងប្រែងធ្វើការកំណែទម្រង់ប្រព័ន្ធរដ្ឋបាល ឱ្យក្លាយទៅជារដ្ឋបាលសាធារណៈ មួយ មានលក្ខណៈបែបទំនើប និងនវានុវត្តន៍ ដោយផ្តោតលើប្រជាជនជាស្នូលនោះទេ។

រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយបែបវិមជ្ឈការសម្រាប់រដ្ឋបាលថ្នាក់ក្រោម ជាតិដូចជា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍជាតិ គឺចាប់ផ្តើមពី ការធ្វើកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដែលនៅកៀកប្រជាពលរដ្ឋ។ ដូច្នេះហើយ ការធ្វើកំណែទម្រង់ តាមបែបវិមជ្ឈការឃុំ សង្កាត់មានសារៈសំខាន់ណាស់ដែលជារឿងមិនអាចមើលរំលងបានឡើយ ហើយត្រូវយក ចិត្តទុកដាក់ខ្ពស់បំផុត អនុវត្តបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីទទួលបានចីរភាពលើការគ្រប់គ្រងរដ្ឋបាល និង ការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ រដ្ឋបាលឃុំ សង្កាត់បានទទួលបាននូវ តួនាទី មុខងារ សិទ្ធិអំណាច ភាពជាម្ចាស់ ការទទួលខុសត្រូវ និងធនធាន (មនុស្ស ថវិកា និងទ្រព្យសម្បត្តិ) ពីរាជរដ្ឋាភិបាលក្នុងការបំពេញ តម្រូវការជូនប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ការសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល តាម បែបវិមជ្ឈការនេះ ដើម្បីធ្វើការឈ្វេងយល់ឱ្យកាន់តែច្បាស់ពីការអនុវត្តការងារតាមនយោបាយវិមជ្ឈការនៃ រដ្ឋបាលសង្កាត់ព្រែកឫស្សី ។ ជុំវិញការអនុវត្តការងារប្រចាំថ្ងៃរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី ដោយបានផ្សារ ភ្ជាប់ជាមួយទ្រឹស្តី គោលនយោបាយ និងរបបគតិយុត្តនានាបន្ថែមទៀត។

ទោះបីជាយើងខ្ញុំខិតខំពិនិត្យឡើងវិញនូវខ្លឹមសារ និងពាក្យពេចន៍ច្រើនដងហើយក៏ពិតមែន តែយើងខ្ញុំ ជឿជាក់ថា ឯកសារមួយនេះក៏នូវមានចំណុចខ្វះចន្លោះមួយចំនួន និងមិនទាន់គ្រប់ជ្រុងជ្រោយពេញលក្ខណៈ នូវឡើយទេ អាស្រ័យហេតុនេះ សូមសាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់គ្នាមេត្តាអធ្យាស្រ័យ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថាចំពោះសារណាស្រាវជ្រាវនេះ នឹងក្លាយជាឯកសារជំនួយស្មារតីដ៏មាន ប្រយោជន៍សម្រាប់មិត្តអ្នកអានទាំងអស់គ្នាជាក់ជាមិនខានឡើយ។

# ការឧទ្ទិសស្នាដៃ

ទូលព្រះបង្គំ ខ្ញុំករុណាអាត្មាភាព ខ្ញុំបាទ សូមឧទ្ទិសស្នាដៃដែលកើតឡើងពីការសិក្សាស្រាវជ្រាវលើប្រធានបទ៖ **ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល** (**២០២០-២០២២**) ជូនចំពោះ៖

- ជីដូន ជីតា ញាតិការទាំងប្រាំពីរសន្តាន និងអ្នកមានគុណដែលបានជួយជ្រោមជ្រែងកន្លងមក។
- អ្នកប្រាជ្ញ បញ្ញវន្តខ្មែរ ដែលបានបូជាកម្លាំងកាយចិត្ត និងទ្រព្យធនធានក្នុងការការពារ ចងក្រងឯកសារអក្សរសាស្ត្រទុកជាមរតកសម្រាប់កូនខ្មែរជំនាន់ក្រោយ។ សូមមនសិការជាតិខ្មែរ ស្ថិតនៅជាប់ជានិច្ចក្នុងដួងព្រលឹងប្រជារាស្ត្រខ្មែរ។
- ប្រជារាស្ត្រខ្មែរគ្រប់ជំនាន់ និងគ្រប់រូបដែលបានខិតខំធ្វើពលិកម្មគ្រប់បែបយ៉ាង នៅក្នុងការការពារប្រទេសជាតិ និងអភិវឌ្ឍមាតុភូមិប្រទេសជាតិខ្មែរយើងឱ្យបានរស់រានរហូតដល់ពេលបច្ចុប្បន្ន និងរួចផុតពីការឈ្លានពានរបស់ពួកបរទេស។
- សូមឱ្យព្រះរាជាណាចក្រកម្ពុជាមានសុខសន្តិភាព សុវត្ថិភាពជាយូរអង្វែងជរាបរៀងទៅ។
- សូមឱ្យមានឯករាជ្យជាតិខ្មែរ បូរណភាពទឹកដី កាន់តែរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃ សូមឱ្យកូនខ្មែរគ្រប់រូប និងគ្រប់សម័យកាលខិតខំរៀនសូត្រដើម្បីអនាគត គ្រួសារ និងមាតុប្រទេសជាតិរបស់យើងទាំងអស់គ្នា។

# អំណរអំណាច

ទូលព្រះបង្គំ ខ្ញុំករុណាអាត្មាភាព ខ្ញុំបាទ ទាំងពីរអង្គនាក់សូមធ្វើការធានាអះអាងថា ខ្លឹមសារ និងលទ្ធផលនៃការស្រាវជ្រាវសារណាមួយ នេះគឺជាកិច្ចការដែលយើងខ្ញុំទាំងពីរនាក់បានធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់ដែលបានស្រាវជ្រាវមក ដោយផ្អែកលើទិន្នន័យដែលជាលទ្ធផលនៃការអនុវត្តទទួលបានពី **សាលាសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល** និងទិន្នន័យដែលពាក់ព័ន្ធមួយចំនួនទៀតបានស្រាវជ្រាវ មកពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សៀវភៅ ឯកទេសរបស់សាស្ត្រាចារ្យ និងអត្ថបទច្បាប់ផ្សេងៗនៅក្នុងបណ្ដាញសង្គមអ៊ីនធើណែត។ ទិន្នន័យទាំងអស់ ដែលមានក្នុងសេចក្ដីរៀបរាប់នៃការស្រាវជ្រាវខាងលើនេះផ្អែកលើការស្រាវជ្រាវ និងយោងតាមទ្រឹស្ដីដែលបាន អនុវត្តរួចយកមកធ្វើការបកស្រាយពន្យល់ និងចងក្រងជាសារណាមួយនេះឡើងដើម្បីជាឧត្តមប្រយោជន៍ដល់សិស្សានុសិស្ស និងសាធារណជនឱ្យទទួលបាននូវចំណេះដឹងថ្មីៗជាច្រើនដែលមាននៅក្នុងស្នាដៃមួយនេះ។

តាខ្មៅ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

ហត្ថលេខា

សាំង សាមីត ហូ សេងហុង

**មាតិកា** **ទំព័រ**


**បញ្ជីអក្សរកាត់** ................................................ Vii

**សេចក្តីផ្តើម**

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ................................................ **១**

**២.ចំណោទបញ្ហា** ................................................ **២**

**៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ** ................................................ **៣**

**៤.ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ** ................................................ **៣**

**៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** ................................................ **៣**

**៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** ................................................ **៤**

**៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ** ................................................ **៦**

**ជំពូកទី១**

**រំលឹកទ្រឹស្តីនិងគោលការណ៍សំខាន់ៗ**

**១.១.ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា** ................................................ ៨

១.១.១.និយមន័យវិមជ្ឈការ ................................................ ៩

១.១.២.មុខងារវិមជ្ឈការ វិមជ្ឈការមានមុខងារពីរខុសគ្នាគឺ ................................................ ៩

១.១.៣.លក្ខណៈពិសេសនៃវិមជ្ឈការ ................................................ ៩

១.១.៤.ទម្រង់ផ្សេងៗនៃវិមជ្ឈការ ................................................ ១០

១.១.៥.វិមជ្ឈការរដ្ឋបាល ................................................ ១០

១.១.៦.វិមជ្ឈការបច្ចេកទស ................................................ ១១

១.១.៧.វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធ ................................................ ១១

១.១.៨.វិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យ ................................................ ១១

**១.២.ការរៀបចំរដ្ឋបាលឃុំ សង្កាត់** ................................................ ១២

១.២.១.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ................................................ ១២

១.២.២.ការចុះឈ្មោះបេក្ខជនបោះឆ្នោត ................................................ ១២
១.២.៣.ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត ................................................ ១៣
១.២.៤.រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់ ................................................ ១៣
១.២.៥.ក្រុមប្រឹក្សាឃុំ សង្កាត់ ................................................ ១៤
១.២.៦.មេឃុំ ឬចៅសង្កាត់ ................................................ ១៤
១.២.៧.ជំទប់ឃុំ ឬចៅសង្កាត់រង ................................................ ១៥
១.២.៨.គណៈកម្មាធិការនានា ................................................ ១៥
**១.៣.ស្មៀនឃុំ សង្កាត់** ................................................ ១៦
១.៣.១.បុគ្គលិកឃុំ សង្កាត់ ................................................ ១៦
១.៣.២.មេភូមិ ................................................ ១៧
១.៣.៣.តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ................................................ ១៧
១.៣.៤.អំណាចរដ្ឋបាលឃុំ សង្កាត់ ................................................ ១៧
១.៣.៥.តួនាទី និងមុខងាររបស់រដ្ឋបាលឃុ សង្កាត់ ................................................ ១៨
១.៣.៦.កិច្ចការរដ្ឋបាលឃុំ សង្កាត់ ................................................ ១៩
១.៣.៧.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ................................................ ១៩
១.៣.៨.ដីកាឃុំ សង្កាត់ ................................................ ១៩
**១.៤.សេចក្តីសម្រេចឃុំសង្កាត់** ................................................ ២០
១.៤.១.លិខិតរដ្ឋបាលឃុំ សង្កាត់ ................................................ ២០
១.៤.២.ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខាររបស់ឃុំ សង្កាត់ ................................................ ២២
១.៤.៣.ការគ្រប់គ្រងបុគ្គលិក ................................................ ២២
១.៤.៤.ការគ្រប់គ្រងឯកសារ ................................................ ២២
១.៤.៥.ការគ្រប់គ្រងសម្ភារបរិក្ខារ ................................................ ២៣

១.៤.៦.ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់........................................................................ ២៣

១.៤.៧.លិខិតអញ្ជើញ........................................................................ ២៣

១.៤.៨.ការបង្កើតរបៀបវារៈប្រជុំ........................................................................ ២៣

១.៤.៩.ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណជន........................................................................ ២៣

## ជំពូកទី២

## ដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឬស្សី

**២.១. ប្រវត្តិ និងស្ថានភាពទូទៅ**........................................................................ ២៤

២.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ........................................................................ ២៤

២.១.២. ស្ថានភាពសេដ្ឋកិច្ច........................................................................ ២៤

២.១.៣.ការរៀបចំ និងការព្រឹត្តទៅរបស់រដ្ឋបាលសង្កាត់ព្រែកឬស្សី........................................................................ ២៤

២.១.៤. សមាសភាពក្រុមប្រឹក្សា........................................................................ ២៤

២.១.៥. គណៈកម្មាធិកានានារបស់សង្កាត់ព្រែកឬស្សី........................................................................ ២៥

២.១.៦.ការអភិវឌ្ឍរបស់សង្កាត់ព្រែកឬស្សី........................................................................ ២៥

២.១.៧.កម្មវិធីវិនិយោគ........................................................................ ២៦

២.១.៨. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់........................................................................ ២៨

២.១.៩.ការរៀបចំ និងអនុម័តថវិការបស់សង្កាត់........................................................................ ២៨

២.១.១០.កំណត់ហេតុប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សី........................................................................ ២៩

**២.២ ការពិភាក្សា និងការសម្រេច**........................................................................ ២៩

២. ២.១.ចំណូល ចំណាយថវិការបស់សង្កាត់........................................................................ ៣២

២.២.២.ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាចៅសង្កាត់ និងមន្ត្រីភូមិ........................................................................ ៣៣

២.២.៣. ប្រព័ន្ធទូទាត់ គណនេយ្យភាពលទ្ធកម្ម........................................................................ ៣៣

២.៣.៤.ប្រព័ន្ធទូទាត់........................................................................ ៣៤

២.២.៥.ប្រព័ន្ធគណនេយ្យ ..... ៣៤
២.២.៦.កិច្ចលទ្ធកម្មសង្កាត់ ..... ៣៤
២.២.៧.គោលការណ៍អភិវឌ្ឍ ..... ៣៥
២.២.៨. ចក្ខុវិស័យអភិវឌ្ឍ ..... ៣៥
**២.៣. គោលបំណងអភិវឌ្ឍ** ..... ៣៥
២.៣.១. គោលដៅអភិវឌ្ឍ ..... ៣៥
២.៣.២. យុទ្ធសាស្ត្រអភិវឌ្ឍ ..... ៣៦
២.៣.៣. យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ..... ៣៦
២.៣.៤. យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច ..... ៣៦
២.៣.៥. យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ..... ៣៧
២.៣.៦. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..... ៣៧

## ជំពូកទី៣

## សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. សមិទ្ធផល** ..... ៣៩
៣.១.១.ការគ្រប់គ្រងរដ្ឋបាល ..... ៣៩
៣.១.២.ការគ្រប់គ្រងស្ថិតិ ..... ៣៩
៣.១.៣. លិខិតបទដ្ឋានគតិយុត្ត និងលិខិតនានា ..... ៤០
៣.១.៤. ស្ថិតិក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិក ..... ៤០
៣.១.៥. ដីកា សេចក្តីសម្រេច និងលិខិត ..... ៤១
៣.១.៦. កិច្ចប្រជុំក្រុមប្រឹក្សានិងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងសង្កាត់ (គ.ក.ន.ក) . ៤១
៣.១.៧. កម្មវិធីប្របត្តិការសេវារដ្ឋបាល ..... ៤១
៣.១.៨.ការសម្រុះសម្រួលទំនាស់ ..... ៤២

៣.១.៩.ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ................................ ៤២
៣.១.១០. ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន វប្បធម៌ បេតិកភណ្ឌជាតិ ........................ ៤២
៣.១.១១. ការងារសហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ......... ៤៣
៣.១.១២. ការឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ................................................ ៤៣
៣.១.១៣.គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិការសង្កាត់............................... ៤៣
៣.១.១៤.គម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង.......................................................... ៤៤
៣.១.១៥.ការអនុវត្តថវិកា ............................................................................................ ៤៤
៣.១.១៦.ការគ្រប់គ្រងទ្រព្យសម្បត្តិ ................................................................................. ៤៥
៣.១.១៧. ការអភិវឌ្ឍសមត្ថភាព ...................................................................................... ៤៦
៣.១.១៨.សកម្មភាពសេវាសង្គម ..................................................................................... ៤៦
៣.១.១៩.ការងារអគ្រានុកូលដ្ឋាន ................................................................................... ៤៦
៣.១.២០.ការផ្តល់សេវារដ្ឋបាល........................................................................................ ៤៦
**៣.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម** ........................................................................ ៤៩
៣.២.១. ផ្នែកសេដ្ឋកិច្ច ............................................................................................... ៤៩
៣.២.២.ផ្នែកសង្គមកិច្ច ............................................................................................... ៥១
៣.២.៣. អភិបាលកិច្ច ................................................................................................. ៥៣
៣.២.៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ................................................. ៥៣
**៣.៣.ដំណោះស្រាយ** .................................................................................................... ៥៣
៣.៣.១.ពង្រឹងផ្នែកសេដ្ឋកិច្ច........................................................................................ ៥៣
៣.៣.២.សង្គមកិច្ច ..................................................................................................... ៥៥
៣.៣.៣.ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ ......................................... ៥៧
៣.៣.៤. ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ......................................................... ៥៨

**សេចក្តីសន្និដ្ឋាន** ........................................................................................................៥៩
**អនុសាសន៍** ..................................................................................................................៦១
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

## បញ្ជីអក្សរកាត់

**គ.ជ.ប** ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**គ.ផ.ថ** ៖ គណៈកម្មាធិការកសាងផែនការនិងថវិកាសង្កាត់

**គ.ក.ន.ក** ៖ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងសង្កាត់

**ក.ប.ឃ.ស** ៖ ក្រុមប្រឹក្សាឃុំ សង្កាត់

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមស៊ីវិលច្រើនលើកច្រើនសារ។ដោយសារឆ្លងកាត់សង្គ្រាមដែលបានអូសបន្លាយប្រមាណបីទសវត្សរ៍ មិនត្រឹមតែបង្អាក់ការអភិវឌ្ឍនៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយ រដ្ឋបាលសង្គមសេដ្ឋកិច្ច វប្បធម៌ប្រពៃណី និងទំនៀមទម្លាប់ ជាពិសេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៩។ បន្ទាប់ពីប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រួមទាំង ផ្អែកលើគំនិតផ្ដួចផ្ដើម ក្នុងការសម្របសម្រួល ខាងនយោបាយ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល បានរៀបចំក្របខណ្ឌគោលនយោបាយ សម្រាប់បោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាល ថ្នាក់ក្រោមជាតិ ដោយត្រូវបានរៀបចំឡើងនាឆ្នាំ១៩៩៩ និងបានឈានទៅដល់រៀបចំច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័តនៅ ខែមករា ឆ្នាំ២០០១។ នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសចំនួន ១,៦២១ ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ចាប់ពីពេលនោះមក កំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ ត្រូវធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់។ សមិទ្ធផលនៃកំណែទម្រង់ដែលបាន សម្រេចបាននៅថ្នាក់ឃុំ សង្កាត់ បានជម្រុញ និងលើទឹកចិត្តដល់រាជរដ្ឋាភិបាលដើម្បីពង្រីកដំណើរការកំណែទម្រង់នេះរហូតដល់ថ្នាក់ក្រោមជាតិតាមរយៈការដាក់ចេញក្របខណ្ឌ យុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការឆ្នាំ២០០៥។ ផ្អែកលើតម្រូវការកំណែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដោយ បានរៀបចំដែនដីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។ រាជធានីភ្នំពេញចែកជា  ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។ ខេត្តចែកជា ក្រុង និងជាស្រុក។ ក្រុងចែកជាសង្កាត់។ ស្រុកចែកជា ឃុំ និងសង្កាត់ ប៉ុន្តែសង្កាត់ក្នុងស្រុកមិនទាន់មានឡើយ។

ក្នុងនោះដែរ ផ្អែកមួយដ៏សំខាន់គឺ រាជរដ្ឋាភិបាលបានដាក់ចេញនូវនយោបាយវិមជ្ឈការថ្នាក់ឃុំ សង្កាត់ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាទិសដៅអាទិភាពធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ។ ជាក់ស្ដែងនាពេលបច្ចុប្បន្ននេះ រដ្ឋបាលឃុំសង្កាត់ជាមណ្ឌលរដ្ឋបាលអនុវត្តនយោបាយវិមជ្ឈការផង និងវិសហវិមជ្ឈការផង។ ក្នុងដំណើរការនេះ រាជរដ្ឋាភិបាលចាត់ទុកដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្វិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ។ ក្នុងន័យ ទិសដៅ នៃកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ គឺដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងជម្រុញ ការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ ពិសេសនឹងទទួលបាននូវផល

ប្រយោជន៍បីធំៗរួមមាន ផ្តល់លទ្ធភាពប្រជាពលរដ្ឋក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ប្រសិទ្ធភាពខ្ពស់នៃការផ្តល់សេវាសាធារណៈ និងការកៀរគរធនធាននៅមូលដ្ឋាន។ នយោបាយនេះ បានផ្តល់លទ្ធភាពខ្ពស់ទៅដល់ប្រជាពលរដ្ឋក្នុងការស្នើ និងការទទួលយកសេវា ប្រកបដោយប្រសិទ្ធភាព សាមញ្ញ រហ័សទាន់ចិត្ត តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។ ក្នុងន័យនេះ សិទ្ធិអំណាចមូលដ្ឋានដែលបានទទួលយកដោយក្រុមតំណាងប្រជាពលរដ្ឋមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់) អ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលធ្វើសកម្មភាពបម្រើផលប្រយោជន៍ជូន សាធារណៈ ក្នុងកិច្ចការអភិវឌ្ឍដែលប្រជាពលរដ្ឋបានបោះឆ្នោតជាសកលដោយផ្ទាល់ ដើម្បីឈរជាតំណាង ការពារសិទ្ធិសេរីភាព និងផលប្រយោជន៍របស់ខ្លួនក្នុងមូលដ្ឋានឃុំ សង្កាត់។ ដោយសារការសង្កេតឃើញនូវទិដ្ឋភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈបែបនេះហើយ ដែលជាចំណាប់អារម្មណ៍ របស់ក្រុមយើងខ្ញុំបានឈានដល់ការសម្រេចជ្រើសរើសយកប្រធានបទ "**ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ និងដើម្បីឈ្វេងយល់កាន់តែច្បាស់លាស់ អំពីការអនុវត្តនយោបាយវិមជ្ឈការនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ២.ចំណោទបញ្ហា

យោងតាមលំនាំបញ្ហា បានជម្រុញឱ្យក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី មានការទទួល ខុសត្រូវលើការគ្រប់គ្រងលើកិច្ចការរដ្ឋបាល ការផ្តល់សេវាសាធារណៈ ការពារផលប្រយោជន៍ លើកកម្ពស់ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងដោះស្រាយរាល់បញ្ហាប្រឈមក្នុងដែនសមត្ថកិច្ច តាំងនាមជាអ្នកដឹកនាំ និងជាអ្នកតំណាងប្រជាពលរដ្ឋ។ ដូច្នេះ ចំណុចសំខាន់នៃការស្រាវជ្រាវលើប្រធានបទស្តីពី ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សីតាមបែបវិមជ្ឈការ ផ្តោតសំខាន់លើបញ្ហាដូចខាងក្រោម៖

- ហេតុអ្វីបានជារដ្ឋបាលថ្នាក់ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមបែបវិមជ្ឈការ?
- តើរដ្ឋបាលសង្កាត់ព្រែកឫស្សីបានអនុវត្តតាមនយោបាយវិមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានដល់ កម្រិតណា? មានតម្លាភាព គណនេយ្យភាព គុណភាព និងប្រសិទ្ធភាពដែរឬទេ? តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ព្រែកឫស្សីបានជួបប្រទះនូវបញ្ហាអ្វីខ្លះ?
- តើលទ្ធផលនៃការអនុវត្តការងារកន្លងមកនៅសង្កាត់ព្រែកឫស្សី ទទួលបានផលយ៉ាងដូចម្តេច? និងមានបញ្ហាប្រឈមអ្វីខ្លះ?
- តើអាជ្ញាធរនៃរដ្ឋបាលសង្កាត់ព្រែកឫស្សីបានចាត់វិធានការដោះស្រាយចំពោះបញ្ហាប្រឈមបែបណាខ្លះ ដើម្បីដោះស្រាយ និងកែលម្អបញ្ហាទាំងនោះឱ្យបានល្អប្រសើរ?

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណង៖

- ឱ្យសាធារណជននិងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានយល់ដឹងអំពីការគ្រប់គ្រងតាមបែបវិមជ្ឈការ និង តួនាទី ភារកិច្ច របៀបការងាររបស់អាជ្ញាធររដ្ឋបាលសង្កាត់ព្រែកឫស្សី ឈ្វេងយល់អំពីការអនុវត្ត នយោបាយវិមជ្ឈការក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សីសិក្សាអំពីដំណើរការគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី
- ឈ្វេងយល់អំពីប្រព័ន្ធអភិបាលកិច្ចល្អ និងរបៀបបម្រើសេវាសាធារណៈរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី ឈ្វេងយល់អំពីសមិទ្ធផលដែលសម្រេចបាន វិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈម ។
- រួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាតដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋបាលសង្កាត់ និងការជម្រុញ កិច្ចអភិវឌ្ឍសង្គមប្រកបទៅដោយប្រសិទ្ធភាព តាមរយៈការផ្តល់ជាអនុសាសន៍ល្អៗ។

## ៤.ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែលើសកម្មភាព នៃការ អនុវត្តការងាររបស់រដ្ឋបាលសង្កាត់ព្រែកឫស្សីក្នុងឆ្នាំ ២០២០-២០២២ តែប៉ុណ្ណោះ។ ដូច្នេះហើយ ចំពោះប្រធាន បទស្តីពី ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល តាមបែបវិមជ្ឈការនេះ យើងខ្ញុំសូមធ្វើ ការបកស្រាយ ទៅលើចំណុចមួយចំនួនដែលទាក់ទងជាមួយនឹងដំណើរការគ្រប់គ្រងរដ្ឋបាល សមិទ្ធផលដែល សម្រេចបានបញ្ហាប្រឈមនិងដំណោះស្រាយលើបញ្ហាផ្សេងៗរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកសិក្សាគ្រប់រូបលើប្រធានបទ ឬជំនាញដែលខ្លួន ជ្រើសរើស មានន័យថាសារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ដំបូងគឺឲ្យអ្នកស្រាវជ្រាវបានយល់ដឹង និងចងចាំ បានច្បាស់ ហើយកាន់តែលម្អិតលើប្រធានបទ បន្ទាប់មកវាក៏បានផ្តល់សារៈប្រយោជន៍ជាច្រើនទៀតដល់ អ្នកអាន និងសាធារណជនទាំងឡាយ ដែលបានអាននូវស្នាដៃស្រាវជ្រាវនេះ។ សារៈប្រយោជន៍ទាំងនេះ រួម មានជាអាទិ៍គឺ៖

### ក.ប្រយោជន៍សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងរដ្ឋបាល សង្កាត់ សាមី

- បានយល់ដឹងអំពីការអនុវត្តការងារ និងផែនការអភិវឌ្ឍរបស់រដ្ឋបាលសង្កាត់
- យល់ដឹងអំពីរបៀបការរៀបចំការងាររដ្ឋបាលមួយចំនួន
- អាចបង្ហាញអំពីការពេញចិត្ត ឬមិនពេញចិត្តចំពោះការដឹកនាំ និងការអនុវត្តការងាររបស់

រដ្ឋបាលសង្កាត់

- បង្កើនការយល់ដឹងទាក់ទងការបម្រើសេវាសាធារណៈរបស់រដ្ឋបាលសង្កាត់
- យល់ដឹងអំពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់កាន់តែច្បាស់បន្ថែមទៀត រដ្ឋបាលសង្កាត់បាន បង្ហាញពីសក្តានុពល កិច្ចអភិវឌ្ឍ និងសមិទ្ធផលដែលសម្រេចបាន បង្ហាញពីការយកចិត្តទុកដាក់របស់រដ្ឋបាលសង្កាត់ចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- រដ្ឋបាលសង្កាត់សាមីដែលចុះធ្វើការសិក្សាស្រាវជ្រាវ ទទួលបានឯកសារសម្រាប់តម្កល់ទុកក្នុងសាលាសង្កាត់

**ខ.ប្រយោជន៍សម្រាប់និស្សិត**

- បានប្រតិបត្តិតាមទិសដៅរបស់សាកលវិទ្យាល័យ
- ក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្របានដោយជោគជ័យ
- បានឈ្វេងយល់កាន់តែច្បាស់អំពីយន្តការ ការអនុវត្តនីតិវិធីក្នុងការបំពេញតួនាទី និងភារកិច្ចក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឈ្វេងយល់កាន់តែច្បាស់ពីយុទ្ធសាស្ត្រ ក្របខណ្ឌច្បាប់ និងគោលនយោបាយ ក្នុងការបម្រើសេវាសាធារណៈ និងអភិបាលកិច្ចល្អជូនប្រជាពលរដ្ឋ
- បានរួមចំណែកដោយផ្ទាល់ក្នុងការជួយជម្រុញនិងលើកកម្ពស់ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព

**គ.ប្រយោជន៍សម្រាប់សាកលវិទ្យាល័យ សាធារណជន និងប្រទេសជាតិ**

- សាកលវិទ្យាល័យទទួលបានឯកសារសម្រាប់តម្កល់ទុក
- មិត្តអ្នកអាន និងសាធារណជនអាចឈ្វេងយល់បន្ថែមពីទ្រឹស្តីមួយចំនួនពាក់ព័ន្ធក្នុងកិច្ចការស្រាវជ្រាវនេះ និងយល់កាន់តែច្បាស់អំពីការអនុវត្តការងាររដ្ឋបាលសង្កាត់
- សង្កាត់មានការរីកចម្រើនដោយកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាលសង្កាត់ធ្វើឱ្យប្រទេសមានការរីកចម្រើន
- ការផ្តល់សេវាសាធារណៈបានល្អធ្វើឱ្យការងាររលូនទៅមុខស្របតាមគោលនយោបាយជាតិ
- បានបង្ហាញពីការចូលរួមអភិវឌ្ឍប្រទេសជាតិតាមរយៈការចូលរួមដែលមិនអាចខ្វះបានពីមូលដ្ឋាន។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

### ក.ក្របខណ្ឌនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានកំណត់លើការសិក្សាស្រាវជ្រាវនៅក្នុងការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល តាមបែបវិមជ្ឈការ ក្នុងឆ្នាំ ២២២០-២០២២ តែប៉ុណ្ណោះ។

## ខ.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវចំនួន០៣បែបគឺ (១) វិធីសាស្ត្របែបរុករក (២) វិធីសាស្ត្របែបពិពណ៌នា និង(៣) វិធីសាស្ត្របែបប្រៀបធៀបវិភាគ។ មូលហេតុដែល យើងខ្ញុំជ្រើសរើសប្រធានបទនេះ ដោយសារមុននឹងសរសេរសារណាមួយឲ្យបានល្អ ត្រូវការឯកសារដែលមានស្រាប់ ការសម្ភាសផ្ទាល់ជាមួយមន្ត្រី ការស្រង់យកទិន្នន័យ និងព័ត៌មានដើម្បីប្រៀបធៀប រួចធ្វើការវិភាគលើទ្រឹស្តី ខ្លឹមសារនិងអត្ថបទគតិយុត្ត ទស្សនទានគោលនយោបាយវិមជ្ឈការ និងទស្សនទាននានា។ ហេតុដូច្នេះជាហេតុនាំឱ្យឈាន ទៅដល់ការសម្រេចជ្រើសរើសយកវិធីសាស្ត្រសិក្សាស្រាវជ្រាវខាងលើ សម្រាប់ធ្វើការបន្ថែមឱ្យគ្នាទៅវិញទៅមក។

### ខ.១.ការប្រមូលទិន្នន័យ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវកាន់តែច្បាស់ ទិន្នន័យដែលត្រូវបានស្រាវជ្រាវមានពីរប្រភេទគឺ ទិន្នន័យចម្បង និង ទិន្នន័យបន្ទាប់បន្សំ។ ទិន្នន័យចម្បង ក្រុមយើងខ្ញុំបានមកពីការចូលរួមផ្ទាល់ក្នុងការ ដែលទាក់ទងនឹងបទពិសោធន៍ក្នុងរដ្ឋបាលព្រែកឫស្សីជាក់ស្តែងតែម្តង។ ដើម្បីឱ្យការសិក្សាស្រាវជ្រាវកាន់តែច្បាស់ ទិន្នន័យដែលត្រូវមានពីរប្រភេទគឺ ទិន្នន័យចម្បង និង ទិន្នន័យបន្ទាប់បន្សំ។ ទិន្នន័យចម្បង ចំណែកទិន្នន័យបន្ទាប់បន្សំ បានតាមរយៈការប្រមូលផ្តុំឯកសារផ្សេងៗ ការពិភាក្សាទាក់ទងច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច និងគោលនយោបាយនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញ ជាពិសេសចំពោះច្បាប់ស្តី ពីការគ្រប់គ្រងរដ្ឋបាលសង្កាត់

(មើលក្នុងឧបសម្ព័ន្ធ ១.) ផែនទីសង្កាត់ព្រែកឫស្សី (មើលឧបសម្ព័ន្ធ ២.)ប្រការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សី(មើលក្នុឧបសម្ព័ន្ធ ៣.)សៀវកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សី (២០២២-២០២៤) (មើលក្នុងឧបសម្ព័ន្ធ ៤.)របាយការណ៍ ប្រចាំខែមីនា ឆ្នាំ២០២២ (មើលក្នុងឧបសម្ព័ន្ធ ៥.) រូបថតជាមួយចៅសង្កាត់ និងមេប៉ុស្តិ៍(មើលក្នុងឧបសម្ព័ន្ធ ៦.)សម្ភាសជាមួយចៅសង្កាត់ និង ស្មៀនរបស់រដ្ឋបាលព្រែកឫស្សី (មើលក្នុងឧបសម្ព័ន្ធ ៧.)លិខិតបញ្ជាក់របស់រដ្ឋបាលសង្កាត់ព្រែកឫស្សី (មើលក្នុងឧបសម្ព័ន្ធ ៨.)ការស្រាវជ្រាវ សារព័ត៌មានឯកសារពាក់ព័ន្ធ មួយចំនួនទៀតពី ប្រព័ន្ធអ៊ីនធឺណិត ព្រមទាំងការប្រឹក្សាយោបល់ពីសាស្ត្រាចារ្យណែនាំផងដែរ។

### ខ.២.ការវិភាគទិន្នន័យ

ការវិភាគអាស្រ័យលើប្រភេទទិន្នន័យ ចំពោះទិន្នន័យចម្បង ការវិភាគធ្វើឡើងដោយម៉ត់ចត់ទៅតាមការពិភាក្សា ការស្ទង់មតិជាច្រើនលើកច្រើនសារមានភាពជាក់លាក់ ច្បាស់លាស់ ដើម្បីបញ្ជាក់ថាការបកស្រាយ ធ្វើឡើងអនុលោមតាមខ្លឹមសារដើមទាំងស្រុង ពុំមានការបញ្ចេញបញ្ចូល ឬបំផ្លើសព័ត៌មានឡើយ។

ហេតុដូច្នេះ ហើយ រដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា យុទ្ធសាស្ត្រ គោលនយោបាយ កម្មវិធីអភិវឌ្ឍ និង របាយការណ៍របស់រដ្ឋបាលសង្កាត់ព្រែកឬស្សី ត្រូវបានលើកឡើងមកពិចារណា ឆ្លុះបញ្ចាំងជាមួយនិងការអនុវត្តជាក់ស្តែង និងប្រៀបធៀបទៅនឹងទិន្នន័យដែលទទួលបានពីការសម្ភាសផ្ទាល់ពីមន្ត្រីរបស់រដ្ឋបាលសង្កាត់ព្រែកឬស្សីស្របតាម លក្ខណៈសត្យានុម័ត។ ចំណែកឯទិន្នន័យបន្ទាប់បន្សំ ដែលបានដកស្រង់ចេញពីឯកសារផ្សេងៗ សៀវភៅរបស់ សាស្ត្រាចារ្យល្បីៗ ក៏ដូចជាមតិពន្យល់បន្ថែមរបស់សាស្ត្រាណែនាំសារណា ការវិភាគចាត់ទុកទិន្នន័យនេះជាព័ត៌មានពិចារណាបំពេញបន្ថែមឱ្យខ្លឹមសារគោលនៃសារណាស្រាវជ្រាវនេះ។

### ខ.៣.វិធីសាស្ត្រវិភាគ

ទិន្នន័យដែលប្រមូលបាន និងធ្វើការវិភាគលក្ខណៈបែបប្រៀបធៀប វិភាគ ដោយរកចំណុចវិជ្ជមាន និង អវិជ្ជមានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការប្រៀបធៀប វិភាគរកចំណុចវិជ្ជមាន និង អវិជ្ជមានត្រូវផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីច្បាប់ ដែលកំពុងចូលជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរាជរដ្ឋាភិបាល ទ្រឹស្តីវិទ្យាសាស្ត្រ និងយុទ្ធសាស្ត្ររបស់ សង្កាត់ ក្នុងការអនុវត្តការងារជាក់ស្តែង ដែលពាក់ព័ន្ធ។ ក្នុងករណីមានភាពអវិជ្ជមានកើតឡើង វិធីសាស្ត្រវិភាគទិន្នន័យនេះ ក៏ត្រូវបានវិភាគស្វែងរក ដំណោះស្រាយសមស្រប ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានក្នុងរដ្ឋបាល សង្កាត់ និងមូលដ្ឋាន។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

រចនាសម្ព័ន្ធស្រាវជ្រាវក្រោមប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាលតាមបែបវិមជ្ឈការ" នេះត្រូវបានចងក្រងចែកចេញតាមប្លង់ដូចខាងក្រោមនេះ

សេចក្តីថ្លែងអំណរគុណៈ បរិយាយអំពីការគោរព ការដឹងគុណ និងការថ្លែងអំណរគុណចំពោះលោក អ្នកមានគុណទាំងពីរ លោកសាស្ត្រាចារ្យ ឯកឧត្តមសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យណែនាំ លោកចៅសង្កាត់ មិត្តភក្តរួមជំនាន់ទាំងអស់ដែលបានរួមចំណែកយ៉ាងធំធេង និងជួយជម្រុញឱ្យយើងទាំងពីរបានបញ្ចប់ការសិក្សារដោយជោគជ័យ។

- **អារម្ភកថា៖** បរិយាយអំពីអារម្មណ៍ និងការយល់ឃើញចំពោះប្រធានបទដែលពួកខ្ញុំទាំងពីរបានខិតខំស្រាវជ្រាវ រួមទាំងគំនិតមួយចំនួនទៀត។
- **សេចក្តីផ្តើម៖** និយាយអំពីបញ្ហាដែលបានបង្ហាញពីចំណុចដំបូងបំផុតនៃប្រធានបទ ការកកើតឡើងដំបូងនៃការរៀបចំក្របខណ្ឌគោលនយោបាយសម្រាប់បោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិឆ្នាំ១៩៩៩។ ចំណោទបញ្ហា ដែលប្រមូលផ្តុំទៅដោយចម្ងល់ជាច្រើនដែលទាក់ទងទៅនឹងលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងរដ្ឋបាល ការអនុវត្តការងារ ជាពិសេស

លើសេវាសាធារណៈ និងការដោះស្រាយចំពោះបញ្ហាផ្សេងៗ គោលបំណងនៃការស្រាវជ្រាវរបស់អត្ថបទទាំងមូល ទំហំ និងដែនកំណត់នៃការស្រាវជ្រាវដែលក្រុមយើងខ្ញុំបានកំណត់ត្រឹម ឆ្នាំ២០២០-២០២២ តែប៉ុណ្ណោះ សារៈសំខាន់នៃការស្រាវជ្រាវ គឺពិតជាល្អសម្រាប់ប្រជាពលរដ្ឋ ឃុំ សង្កាត់ និស្សិត និងសាកលវិទ្យាល័យ សាធារណជន និងប្រទេសជាតិ ដោយរួមមាន វិធីសាស្ត្រស្រាវជ្រាវដែលបង្ហាញពីវិធីសាស្ត្រ ក្នុងការប្រមូលព័ត៌មានជាមួយរដ្ឋបាលឃុំ សង្កាត់ មេប៉ុស្តិ៍ ប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

- **ជំពូកទី១ រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ៖** ជំពូកនេះបង្ហាញអំពីទ្រឹស្តីមួយចំនួនដែលពាក់ព័ន្ធ នឹងប្រធានបទ ដែលមានដូចជា ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ តួនាទី មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងកិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់។
- **ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឬស្សី៖** ជំពូកនេះបង្ហាញអំពីស្ថានភាពទូទៅ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលសង្កាត់ព្រែកឬស្សី ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រួមទាំង ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់ព្រែកឬស្សី
- **ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ៖** ជំពូកនេះ បានលើកឡើងអំពី សមិទ្ធផលដែលរដ្ឋបាលសង្កាត់ព្រែកឬស្សីសម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយ រួមទាំងសមិទ្ធផលរបស់រដ្ឋបាលសង្កាត់ព្រែកឬស្សី។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ផ្នែកនេះជាចំណុចចុងក្រោយនៃសារណានេះ ដោយសង្ខេបនូវរាល់លទ្ធផលទាំងអស់ ដែលទទួលបានពីការស្រាវជ្រាវ និងបង្ហាញពីការអនុសាសន៍មួយចំនួន។

# ជំពូកទី១

# រំលឹកទ្រឹស្តីគោលការណ៍សំខាន់ៗ

# ជំពូកទី១
# រំលឹកទ្រឹស្តីនិងគោលការណ៍សំខាន់ៗ

## ១.១.ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ។ ដោយសារវិមជ្ឈការគឺជាធាតុផ្សំសំខាន់ក្នុងការអនុវត្តនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ប្រព័ន្ធវិមជ្ឈការនៅកម្ពុជាមានគោលបំណងចម្បង៣យ៉ាងគឺ(១)ជម្រុញឲ្យដំណើរការលទ្ធិប្រជាធិបតេយ្យនិងការគ្រប់គ្រងបែបអភិបាលកិច្ចល្អនៅមូលដ្ឋានជម្រុញគុណភាពក្នុងការរស់នៅឲ្យមានភាពកាន់តែប្រសើរឡើងរបស់ប្រជាពលរដ្ឋ (២)ផ្តល់ឱកាសកាន់តែច្រើនឡើងទៅដល់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តរៀបចំការអភិវឌ្ឍនៅមូលដ្ឋាន និង(៣) ធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការបែងចែកនូវសេវាកម្មជាមូលដ្ឋានផ្សេងៗ។[1]រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា វិមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជារាស្ត្រ លើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជារាស្ត្រ និងលើកកម្ពស់ការផ្តល់នូវ សេវាកម្មចាំបាច់ដល់មូលដ្ឋាន សមស្របទៅតាមតម្រូវការជាក់ស្តែងរបស់ខ្លួន។ ការរៀបចំ ប្រព័ន្ធគ្រប់គ្រងមូលដ្ឋាន ដែលធានាឲ្យមានការចូលរួមប្រាស្រ័យពីប្រជាពលរដ្ឋគឺជាវិធីសាស្ត្រគ្រប់គ្រងមាន តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ វិមជ្ឈការ គឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់លើកកម្ពស់អភិបាលកិច្ចល្អ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រ សំដៅអភិវឌ្ឍប្រទេសទាំងមូល។ ដូច្នេះ ការសម្រេចរបស់រាជរដ្ឋាភិបាលក្នុង ការជ្រើសរើស ឃុំ សង្កាត់ឱ្យអនុវត្តនូវការគ្រប់គ្រងតាមនយោបាយវិមជ្ឈការ គឺជាការថ្លឹងថ្លែងពិចារណាយ៉ាង ហ្មត់ចត់ ដោយមានហេតុផលជាក់ស្តែង និងសមស្របបំផុតសម្រាប់បរិបទ នៃប្រទេសកម្ពុជា។ ទន្ទឹមនឹងហេតុ ផលនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានអនុម័តដោយរដ្ឋសភាកម្ពុជា ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការចាប់ផ្តើមអនុវត្តនូវគោលនយោបាយវិមជ្ឈការ នៅកម្ពុជា។ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុម័តនៅឆ្នាំ២០០១ដែលនាំឱ្យមានការផ្លាស់ប្តូរយ៉ាងស៊ីជម្រៅទៅលើបរិយាកាសនយោបាយ កម្ពុជា។ ច្បាប់ទាំងពីរនេះ បានបង្កើតឲ្យមានក្រុមប្រឹក្សាឃុំ សង្កាត់តាមបែបវិមជ្ឈការដែលជាអង្គភាពដ៏សំខាន់ សម្រាប់អភិបាលកិច្ចមូលដ្ឋាន ហើយច្បាប់ទាំងពីរនេះ នាំឱ្យមានការបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាទាំងនោះ។ ជាក់ស្តែងនៅប្រទេសកម្ពុជា វិមជ្ឈការបានក្លាយជាគោល

[1] ដកស្រង់ចេញពីសៀវភៅ វិមជ្ឈការ និងវិសហមជ្ឈការ និពន្ធដោយ សាស្ត្រាចារ្យ កៅ មុយថង ឆ្នាំ២០០៧ ទំព័រទី៣

នយោបាយពិតប្រាកដបន្ទាប់ពីមានការបោះឆ្នោតឃុំ សង្កាត់លើកទី១ ត្រូវបានរៀបចំធ្វើឡើងនៅថ្ងៃអាទិត្យ ទី០៣ ខែកុម្ភៈ ឆ្នាំ២០០២ ដោយមានអ្នកបោះ ឆ្នោតជាង ៤,៥លាននាក់ បានបោះឆ្នោតជ្រើសរើសសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១,១២៦រូប តំណាងឲ្យ ឃុំសង្កាត់ចំនួន ១,៦២១ នៅក្នុងការបោះឆ្នោតនោះ មាន បេក្ខជនឈរឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតចំនួន ៧៥,៦៥៥រូប។ មិនតែប៉ុណ្ណោះ មានការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី២ លើកទី៣ និងនីតិកាលបន្ត បន្ទាប់ទៀត។

**១.១.១.និយមន័យវិមជ្ឈការ**

ប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះវិមជ្ឈការ គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវ ភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់មូលដ្ឋាន ហើយក្រុម ប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះ ក្នុងន័យនេះ រាល់កិច្ចការនានាដែលបានធ្វើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សា ក្រុម ប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅក្នុងមូលដ្ឋាន របស់ខ្លួន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។[2]វាជាដំណើរមួយ ដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈ ត្រូវបានផ្ទេរពីរដ្ឋបាល កណ្ដាលឱ្យទៅរដ្ឋបាល ថ្នាក់មូលដ្ឋាន ដែលមានគោលបំណងទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងគោលគំនិតស្ដីពី Subsidiarity ជា គោលគំនិតក្នុងការបង្ហាញនូវការផ្ទេរអំណាចឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមលក្ខណៈដែលរដ្ឋបាលថ្នាក់ក្រោម ជាតិ អាចទទួលយកបានសមស្របទៅសមត្ថភាពក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។[3]

**១.១.២.មុខងារវិមជ្ឈការ វិមជ្ឈការមានមុខងារពីរខុសគ្នាគឺ**

មុខងារនៃធម្មានុរូបកម្មនៃអំណាចរបស់រដ្ឋ ពោលគឺនៅពេលធ្វើវិមជ្ឈការអំណាចរបស់រដ្ឋបង្ហាញឱ្យ ឃើញសេរីភាវូបនីយកម្ម និងរបបមួយមានលក្ខណៈប្រជាធិបតេយ្យ។ ហេតុនេះ នយោបាយក្នុងការធ្វើ វិមជ្ឈការ របស់រដ្ឋ គឺនយោបាយមួយចំណេញខាងស្មារតី ឬចិត្តសាស្ត្រ និយាយរួមអំណាចកណ្ដាលត្រូវ បានគោរពដោយ ប្រជាជន។ មុខងារនៃការបំពេញចិត្តទាមទារចេញមកពីកម្លាំងនយោបាយ និងសង្គម ដែលមិនត្រួតពិនិត្យដោយ ឧបករណ៍រដ្ឋ និងជាកម្លាំងដែលទាមទារសេរីភាពជាសមូហភាពមួយផ្នែក។

**១.១.៣.លក្ខណៈពិសេសនៃវិមជ្ឈការ**

បច្ចេកទេសនៃការគ្រប់គ្រងតាមនយោបាយវិមជ្ឈការមានលក្ខណៈពិសេសចំនួន បីគឺៈ

---

[2] ដកស្រង់ចេញពីសៀវភៅ ប្រពន្ធ័គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ឆ្នាំ២០០៩ ទំព័រ១៨

[3] អុង ចំរើន សក្ខាប័ននីតិរដ្ឋបាលទូទៅ, ២០០១ ទំព័រ ទី៧

- បុគ្គលភាពគតិយុត្ត សំដៅដល់ប្រព័ន្ធវិមជ្ឈការដែលមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ។ ប្រព័ន្ធនេះ ជាប្រធាននៃនីតិខុសពីរដ្ឋ ប្រព័ន្ធទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចផ្ទាល់ខ្លួន មានគោលដៅ សិទ្ធិ អំណាច និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ថវិកា សម្ភារៈ និងធនធានមនុស្ស)។
- សមត្ថកិច្ចផ្ទាល់ សំដៅដល់ប្រព័ន្ធវិមជ្ឈការខុសពីសមត្ថកិច្ចរដ្ឋ។ ពោលគឺមានលក្ខណៈគតិយុត្តពីរគឺៈ (១) មិនមែនជាសមត្ថកិច្ចជាគោលការណ៍ទេ ប៉ុន្តែជាសមត្ថកិច្ចដែលកំណត់ដោយច្បាប់ និង (២) នៅ ពេលរដ្ឋកំណត់ភារកិច្ចឲ្យហើយ រដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានឡើយ។
- ការប្រើប្រាស់សមត្ថកិច្ចស្វយ័ត មានន័យថាគ្មានរណបឋានុក្រមទេ រវាងរដ្ឋ និងប្រព័ន្ធវិមជ្ឈការ។ គ្មានអំណាចបង្គាប់បញ្ជាទេ។ ប៉ុន្តែការត្រួតពិនិត្យរបស់អំណាចកណ្តាលនៅតែមាននូវឡើយ ព្រោះរដ្ឋនៅតែជារដ្ឋទោលដដែល។ ហើយស្វ័យភាពមិនមែនឯករាជ្យភាពទេ។ ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងតាមរបៀបពីរយ៉ាងដែលអង្គការត្រួតពិនិត្យអាចជាអង្គការតុលាការ ឬអាជ្ញាធររដ្ឋបាល។

### ១.១.៤.ទម្រង់ផ្សេងៗនៃវិមជ្ឈការ

ទម្រង់ផ្សេងៗនៃវិមជ្ឈការ មានការកំណត់ជាច្រើនប្រភេទទៅតាមការបោះពុម្ពផ្សាយរបស់បុគ្គលល្បីៗ និងស្ថាប័នផ្សេងៗលើសកលលោក ក្នុងការគ្រប់គ្រងរដ្ឋបាលសធារណៈ។ ចំណែកឯការបោះពុម្ពផ្សាយរបស់ United Nation Development Program (UNDP) ត្រូវបានមកស្រាយយ៉ាងសាមញ្ញនៃទ្រឹស្តីវិមជ្ឈការ ដោយផ្តោតលើការគ្រប់គ្រងវិស័យសាធារណៈ។ ទម្រង់វិមជ្ឈការនីមួយៗ ត្រូវឈរលើគោលការណ៍អភិបាលកិច្ចល្អ និងអាស្រ័យតាមករណីពិសេសរបស់ប្រទេសនីមួយ។

### ១.១.៥.វិមជ្ឈការរដ្ឋបាល

វិមជ្ឈការរដ្ឋបាល ត្រូវបានគេចាត់ទុកថាមានការទាក់ទងនឹងការអភិវឌ្ឍ គឺជាទម្រង់ទូទៅ និងត្រូវបានគេទទួលស្គាល់ថាជាទម្រង់វិមជ្ឈការ។ វិមជ្ឈការរដ្ឋបាល មានន័យថា ជាការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងបែងចែកប្រភពប្រាក់វិភាជន៍ពីរាជរដ្ឋាភិបាល និងភ្នាក់ងារផ្សេងៗរបស់ខ្លួនឲ្យមូលដ្ឋានអង្គភាព ភ្នាក់ងាររាជរដ្ឋាភិបាលមូលដ្ឋាន ស្ថិតក្រោមបង្គាប់របស់រាជរដ្ឋាភិបាល ឬក្រុមហ៊ុនពាក់កណ្តាលស្វយ័ត អាជ្ញាធរមុខងារ។[4] គេអាចហៅថាវិមជ្ឈការរដ្ឋបាល វិមជ្ឈការដែនដី វិមជ្ឈការដែនដី ត្រូវបានធ្វើឡើងទៅលើនីតិបុគ្គលសាធារណៈដែនដី ដែលមានដែនដីវិសាលភាពទូលំទូលាយ ដូចជាខេត្តដែលហៅថា វិមជ្ឈការផ្តល់ទៅឱ្យ អភិបាលកិច្ច ឬសមូហភាពដែនដីវិញ ដែលមិនផ្តោតលើអភិបាលកិច្ច ឬសមូហភាពមូលដ្ឋានទេ។ នីតិបុគ្គលសាធារណៈដែនដី គឺមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត ហើយក្រុមប្រឹក្សានេះជាអ្នកបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិ ដែលជាទូទៅមានអង្គទាំងពីរនេះ មានភារកិច្ច តួនាទីដោយ

---

[4] ឧទ្ទេសនាមដោយ សម្តេចក្រឡាហោម ស ខេង, កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ២០១៩, ទំព័រទី១៨

ឡែកពីគ្នា គឺក្រុមប្រឹក្សាមានតួនាទីជាអ្នកចេញសេចក្ដីសម្រេចនានា ហើយនាយកប្រតិបត្តិជាអ្នកអនុវត្តសេចក្ដីសម្រេច។

**១.១.៦.វិមជ្ឈការបច្ចេកទេស**

វិមជ្ឈការអំពីមុខងារដែលសិទ្ធិអំណាចមានពីរប្រភេទ គឺវិមជ្ឈការបច្ចេកទេស និងវិមជ្ឈការសេវាកម្ម តម្រូវឱ្យមានការធ្វើវិមជ្ឈការនៅថ្នាក់រដ្ឋបាល។ វិមជ្ឈការបច្ចេកទេស របៀបគ្រប់គ្រងសេវាកម្មសាធារណៈដោយមានការផ្ទេរការទទួលខុសត្រូវអំពីសិទ្ធិអំណាចដឹកនាំគ្រប់គ្រងបច្ចេកទេសណាមួយឱ្យទៅអាជ្ញាធរមួយគ្រប់គ្រងទៅតាមច្បាប់ ក្នុងគោលបំណងបម្រើផលប្រយោជន៍ទូទៅឲ្យមានប្រសិទ្ធភាព។ ក្នុងបរិបទប្រទេសកម្ពុជា គ្រប់គ្រង វិមជ្ឈការបច្ចេកទេសបានរៀបចំរួចរាល់ហើយ ពោលគឺដែលបានប្រគល់សិទ្ធិ ឱ្យគ្រប់គ្រងតាមបែបវិមជ្ឈការបច្ចេកទេសមានដូចជា អាជ្ញាធរកំចាត់មីន អាជ្ញាធរអប្សរា អាជ្ញាធរអគ្គសនីកម្ម រដ្ឋករទឹក។ល។[5]

**១.១.៧.វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធ**

ការស្ថាបនានូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការសម្រេចចិត្តប្រើប្រាស់ធនធានផ្សេងៗ។ ការទទួលខុសត្រូវខាងសារពើពន្ធ គឺជាធាតុផ្សំយ៉ាងសំខាន់នៃវិមជ្ឈការ ព្រោះថារដ្ឋបាលមូលដ្ឋានត្រូវមានប្រាក់ចំណូលគ្រប់គ្រាន់ (ប្រមូលនៅមូលដ្ឋាន និងបញ្ជូនពីថ្នាក់ជាតិ) ដើម្បីធ្វើការសម្រេចក្នុងការចំណាយ។ វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើន ដែលសរុបជារួមមកមានដូចខាងក្រោមៈ

ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយយកតាមថ្លៃពីអ្នកប្រើប្រាស់

ការពង្រីកចំណូលនៅមូលដ្ឋាន តាមរយៈការយកពន្ធអាករ និងការយកថ្លៃដោយប្រយោល

ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តររដ្ឋបាល និងការផ្ដល់អំណាចក្នុងការខ្ចីហិរញ្ញប្បទាន ដើម្បីបម្រើផលប្រយោជន៍នៅមូលដ្ឋាន។

**១.១.៨.វិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យ**

វិមជ្ឈការនយោបាយ ជាការផ្ដល់ឲ្យប្រជាពលរដ្ឋទាំងឡាយធ្វើការបោះឆ្នោតជ្រើសតាំងជាតំណាងពួកគាត់នូវការផ្ដល់សិទ្ធិអំណាចច្រើនជាងមុនក្នុងការធ្វើសេចក្ដីសម្រេចចិត្តជាសាធារណៈ។ ទាំងនេះជាការគាំទ្រឱ្យ មានការផ្ដាច់ចេញនូវអំណាចប្រមូលផ្ដុំនៅថ្នាក់កណ្ដាល។ ធ្វើបែបនេះ ដើម្បីធានាបាននូវតុល្យភាព និងប្រព័ន្ធត្រួតពិនិត្យចម្រុះក្នុងការអនុវត្តនយោបាយ ដើម្បីមានការអភិវឌ្ឍ។ វិមជ្ឈការប្រជាធិបតេយ្យ មានការពាក់ព័ន្ធទៅនឹងការផ្ទេររដ្ឋបាលសារពើពន្ធ និងសិទ្ធិអំណាចនយោបាយ ដើម្បីឱ្យវិមជ្ឈការទទួលបានជោគជ័យ វិមជ្ឈការ

[5] ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្ដីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

ប្រជាធិបតេយ្យ គឺជាការពង្រឹងយ៉ាងសំខាន់ក្នុងការសម្រប សម្រួលដំណើរការរៀបចំ និងការអនុវត្តផែនការនៅមូលដ្ឋាន ហើយក៏ជាវិធីសាស្ត្រមួយ ដើម្បីទំទាក់ទំនងជាមួយ អង្គការសង្គមស៊ីវិល និងធ្វើឯកជនទទួលបានសាកលភាវូបនីយកម្មផងដែរ។ វិមជ្ឈការប្រជាធិបតេយ្យ អាចជាដំណើរការ ដែលឈានទៅរកការបង្កើតឱ្យមានប្រជាធិបតេយ្យនៅមូលដ្ឋាន ធ្វើឱ្យប្រជាពលរដ្ឋមានការចូលរួមនៅ មូលដ្ឋាន ក្នុងកិច្ចការងារអភិវឌ្ឍមូលដ្ឋាន និងសង្គមជាតិ។

## ១.២.ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.២.១.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំសង្កាត់ របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់។ ការបោះឆ្នោតនេះ ត្រូវបានធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដោយការបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់។[6] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តតាម ប្រព័ន្ធសមាមាត្រដោយមានការបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ក្រោមសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ដំណើរការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវបានរៀបចំតាមលំដាប់លំដោយដូចតទៅ៖

### ១.២.២.ការចុះឈ្មោះបេក្ខជនបោះឆ្នោត

បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណៈបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីគណៈបក្សនយោបាយ។[7] បន្ទាប់មកគណៈបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណៈបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិទៅជាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ៩០ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយមានភ្ជាប់មកជាមួយនូវបញ្ជី រាយនាមបេក្ខជនដែលមានចំនួនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិករបស់ក្រុមឃុំសង្កាត់។ ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ញាតិខ្មែរពីកំណើត

---

[6] មាត្រា៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ២០០៦

[7] មាត្រា៤៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ២០០៦

- ចេះអាន និងសរសេរអក្សរខ្មែរ
- ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**ចំណែកជនត្រូវហាមមិនអោយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ រួមមាន៖**

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករដ្ឋាភិបាល និងចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង ព្រះសង្ឃ ឬបុព្វសាសនា
- ស្មៀនឃុំ សង្កាត់

### ១.២.៣.ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អោយបានយ៉ាងតិច ៩០ថ្ងៃមុនថ្ងៃបោះឆ្នោត។[8] បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់រួចគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យបញ្ជីឈ្មោះ អ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមិនត្រូវតិចជាង ១៥ថ្ងៃឡើយ។ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំ ឡើងគិតមកដល់ថ្ងៃបោះឆ្នោត
- មិនស្ថិតក្នុងស្ថានភាពជាទណ្ឌិត ឬស្ថានភាពជាជនវិកលចរិតជាដើម។[9]

### ១.២.៤.រចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួន ដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

[8] មាត្រា៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ២០០៦

[9] មាត្រា១៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ២០០៦

### ១.២.៥.ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩ ឬ១១នាក់ ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាជនដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។ ចំនួនជាក់ស្តែងនៃសមាជិក ក.ប.ឃ.ស ត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធានមួយរូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ហើយប្រធានក្រុម ប្រឹក្សាឃុំ សង្កាត់គឺ ជាមេឃុំ ឬចៅសង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាន និងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។[10]
- សមាជិក ក.ប.ឃ.ស មានតួនាទី ភារកិច្ចដូចខាងក្រោម៖
- ធានាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

### ១.២.៦.មេឃុំ ឬចៅសង្កាត់

ឃុំ សង្កាត់នីមួយៗមានមេឃុំ ឬចៅសង្កាត់មួយនាក់។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសឱ្យធ្វើជាមេឃុំ ឬចៅសង្កាត់។ មេឃុំ ឬចៅសង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ

[10] មាត្រា១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១

- ផ្ទេរសិទ្ធិដល់ជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមនៅពេលខ្លួនអវត្តមាន។[11]

**១.២.៧.ជំទប់ឃុំ ឬចៅសង្កាត់រង**

មេឃុំ ឬចៅសង្កាត់ត្រូវមានជំនួយការ ២រូបចាំបាច់គឺ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ដែលមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- **ជំទប់ទី១ ឬចៅសង្កាត់រងទី១**
- ទទួលជួយមេឃុំ ឬចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មេឃុំ ឬចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមដល់ជំទប់ទី១ ឬចៅសង្កាត់រងទី១
- បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទីករណីមេឃុំ ឬចៅសង្កាត់អវត្តមាន។
- **ជំទប់ទី២ ឬចៅសង្កាត់រងទី២**
- ជួយមេឃុំ ឬចៅសង្កាត់ក្នុងការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងកិច្ចការសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋាន
- មេឃុំ ឬចៅសង្កាត់អាចប្រគល់លើការងារបន្ថែមដល់ជំទប់ទី២ ឬចៅសង្កាត់រងទី២
- បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទី ក្នុងករណីមេឃុំ ឬចៅសង្កាត់ និងជំទប់ទី១ និងចៅសង្កាត់រងទី១ អវត្តមាន។

**១.២.៨.គណៈកម្មាធិការនានា**

មេឃុំ ឬចៅសង្កាត់ អាចចាត់តាំងគណៈកម្មាធិការផ្ដល់យោបល់។ គណៈកម្មាធិការនេះមានសមាជិកយ៉ាងតិច ០៣ នាក់ (អាចយកក្នុងចំណោមសមាជិកក្រុមប្រឹក្សា) ដើម្បីផ្ដល់យោបល់ និងជួយការងារដល់ក្រុម ប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ឬចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនានាមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ផ្ដល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជា ការកសាង ផែនការអភិវឌ្ឍ និងថវិកា (គណៈកម្មាធិការកសាងផែនការ និងថវិកា) ជាដើម
- រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន
- ផ្ដល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធនឹងការងារ។

[11] ដកស្រង់ចេញពីសៀវភៅ ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ តាមបែបវិមជ្ឈការ ឆ្នាំ២០១៧ ទំព័រទី១៣

## ១.៣.ស្មៀនឃុំ សង្កាត់

ឃុំ សង្កាត់ នីមួយៗមានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបម្រើការងារស្ថិតនៅក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលនៃក្រសួងមហាផ្ទៃ។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ មានន័យថា ការអនុវត្តការងាររបស់ស្មៀនឃុំ សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទីដូចខាងក្រោម៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញតួនាទី និងមុខងារស្របតាមតម្រូវការច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្របទៅនឹង លក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការ នានារបស់ឃុំ សង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការ លើកលែងតែបានទទួលការ អនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទ ផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[12]

### ១.៣.១.បុគ្គលិកឃុំ សង្កាត់

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកដើម្បីជួយកិច្ចការរបស់ខ្លួនបានប៉ុន្តែបុគ្គលិកប្រភេទនេះជាបុគ្គលិកដែលស្ថិតនៅក្រៅក្របខណ្ឌរដ្ឋ ការជ្រើសរើសនេះ ធ្វើឡើងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នោះផ្ទាល់។ បុគ្គលិក ឃុំ សង្កាត់មានភារកិច្ចជួយកិច្ចការតាមសេចក្តីត្រូវការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។[13]

[12] ប្រកាសលេខ ១៣២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្តីពី តួនាទី ភារកិច្ច និងស្មៀនឃុំ សង្កាត់

[13] មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១

### ១.៣.២.មេភូមិ

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិមួយនាក់ សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ មេភូមិត្រូវមានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ
- ជាអ្នកទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់ យោបល់អំពីកិច្ចការពាក់ព័ន្ធនឹងភូមិរបស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនិងភូមិរបស់ខ្លួន ដើម្បីដាក់ចូលរបាយការណ៍ ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងភូមិដល់ប្រជាពលរដ្ឋរបស់ខ្លួន
- ទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

### ១.៣.៣.តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទីមុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជម្រុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិ ស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[14]

### ១.៣.៤.អំណាចរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

---

[14] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១

- **អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់** ស្តែងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។
- **អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់** មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេច របស់ខ្លួននៅក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពតែនៅក្នុងក្របខណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យតែប៉ុណ្ណោះ។ មានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើផ្ទុយពីគោលការណ៍ និងបញ្ញត្តិដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាឡើយ។ រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យៈ

- ព្រៃឈើ
- ប្រៃសណីយ៍
- និងទូរគមនាគមន៍
- ការពារប្រទេស
- សន្តិសុខជាតិ រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ លិខិតបទដ្ឋានដែលពាក់ព័ន្ធ។[15]

### ១.៣.៥.តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានតួនាទីពីរប្រភេទគឺ តួនាទីបម្រើកិច្ចការមូលដ្ឋាន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ។

#### ក. តួនាទីបម្រើកិច្ចការមូលដ្ឋាន

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការទទួលខុសត្រូវឱ្យកិច្ចការទាំងនោះ ដំណើរការបានល្អ

[15] មាត្រា៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១

- លើកទឹកចិត្តឱ្យមានការបង្កើនជាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[16]

### ខ. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ

រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការ បង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្ត។ ប្រតិភូកម្មនេះ ត្រូវផ្តល់ចំពោះតែ សមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ **ឧទាហរណ៍៖** ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះ អ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់។

### ១.៣.៦.កិច្ចការរដ្ឋបាលឃុំ សង្កាត់

កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់មានដូចជា លិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងឯកសារ ការគ្រប់គ្រងសម្ភារៈបរិក្ខារ និងការរៀបចំកិច្ចប្រជុំជាដើម។

### ១.៣.៧.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតាក់តែង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តកិច្ចការនានា។ ប្រភេទលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់មានដូចជា៖

### ១.៣.៨.ដីកាឃុំ សង្កាត់

ដីកាឃុំសង្កាត់គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើង សំដៅបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាព មិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ ត្រូវ

[16] មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១

ចុះហត្ថលេខាដោយមេឃុំ ឬចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

## ១.៤.សេចក្តីសម្រេចឃុំសង្កាត់

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើត ការតែងតាំង ការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានា ក្នុងក្របខណ្ឌ តួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន។ សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែល និងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាង ដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។ សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវ ផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយ មេឃុំ ឬចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពី ពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។ករណីមានប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះ និងត្រូវដាក់ជូន កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាប់ ដើម្បីពិនិត្យឡើងវិញអំពីភាពមិនត្រឹមត្រូវតាមច្បាប់។[17]

### ១.៤.១.លិខិតរដ្ឋបាលឃុំ សង្កាត់

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានា ក្នុងគោលបំណងជូនព័ត៌មាន អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឱ្យទៅបំពេញបេសកកម្ម។ លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការរួមមាន លិខិតស្នើ លិខិតជូនដំណឹង ឬសេចក្តីជូន ដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីកាអម។

- **លិខិតស្នើ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយដែលខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួងស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

[17] ដកស្រង់ចេញពីសៀវភៅ ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់តាមបែបវិមជ្ឈការ ឆ្នាំ២០១៧ ទំព័រ២២

- **សេចក្តីជូនដំណឹង** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើឬជូនដំណឹងឱ្យសាធារណៈបានដឹងព័ត៌មានទាំងឡាយដែលឃុំសង្កាត់ត្រូវកាផ្សព្វផ្សាយ។
- **លិខិតអញ្ជើញ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីអញ្ជើញបុគ្គល តំណាងក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬអង្គភាពទាំងនោះ ដោយមានបញ្ជាក់ឈ្មោះ និងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធ កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។
- **លិខិតបញ្ជាបេសកកម្ម** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។លិខិតនេះមានភ្ជាប់ជាមួយទិដ្ឋាការពេលធ្វើដំណើរ។
- **ទិដ្ឋាការធ្វើដំណើរ** គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឱ្យអ្នកដែលមានភារៈកិច្ចទៅ បំពេញបេសកកម្ម យកទៅចុះទិដ្ឋាការនៅទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខា របស់អង្គភាពដែលមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលទទួលដឹងឮ អំពីការចេញ ដំណើរ និងការមកដល់ពីដំណាក់មួយទៅដំណាក់មួយទៀត។ នៅពេលត្រឡប់មកវិញ ត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបអំពីលទ្ធផល សំខាន់ៗដែលខ្លួនបានទៅចូលរួម។
- **របាយការណ៍** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាព ដំណើការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងឱ្យទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។
- **កំណត់ហេតុ** គឺជាការកត់ត្រា ស្រង់មតិយោបល់ សេចក្តីសម្រេច និងការឯកភាពលើសកម្មភាព ដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។
- **លិខិតផ្ទេរសិទ្ធិ** គឺជាលិខិតរបស់មេឃុំ ឬចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិឱ្យទៅជំទប់ ចៅសង្កាត់រងតាមឋានានុក្រម ដើម្បីធ្វើជាមេឃុំ ឬចៅសង្កាត់ស្តីទីក្នុងកំឡុងពេលដែលមេឃុំចៅសង្កាត់អវត្តមាន។

- **ដីការអម** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំលិខិត ដែលត្រូវផ្ញើចេញទៅឱ្យអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ) លើ ដីការអមនោះ។ ឃុំ សង្កាត់ប្រើដីការអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើ ចេញ។

**១.៤.២.ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខាររបស់ឃុំ សង្កាត់**

**១.៤.៣.ការគ្រប់គ្រងបុគ្គលិក**

រដ្ឋបាលឃុំ សង្កាត់មានបុគ្គលិកពីរប្រភេទ គឺស្មៀនដែលរាជរដ្ឋាភិបាលបានបញ្ជូនឱ្យមកធ្វើការក្នុងឃុំ សង្កាត់ និងបុគ្គលិករបស់ឃុំ សង្កាត់ផ្ទាល់។ ស្មៀនឃុំគ្មានសិទ្ធិគ្រប់គ្រងលើបុគ្គលិកផ្ទាល់របស់ក្រុមប្រឹក្សាឃុំទេ។ ករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនមានភាពមិនចុះសម្រុងគ្នា ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិស្នើសុំផ្លាស់ប្តូរស្មៀន ហើយក្រសួងមហាផ្ទៃត្រូវតែឆ្លើយតបជាវិជ្ជមានចំពោះការស្នើសុំនេះ។ ដូច្នេះការចាត់ចែងរបៀបនេះនាំឱ្យមានតុល្យភាពអំណាចរវាងក្រុមប្រឹក្សា និងស្មៀនឃុំ ក្នុងការងាររដ្ឋបាលប្រចាំថ្ងៃ និងការធ្វើសេចក្តីសម្រេចនានា។

ក្របខណ្ឌច្បាប់មិនបានចែងលំអិតអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ទេ ច្បាប់ គ្រាន់តែបញ្ជាក់ថាក្រុមប្រឹក្សាអាចជួលបុគ្គលិករបស់ខ្លួនផ្ទាល់ ស្ថិតក្រោមការចាត់ចែងសព្វថ្ងៃនេះក្រុមប្រឹក្សាឃុំ សង្កាត់អាចជួលគណនេយ្យករអោយជួយគ្រប់គ្រងចំណូលដែលឃុំរកបាន។

**១.៤.៤.ការគ្រប់គ្រងឯកសារ**

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយដែលមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់ផ្តល់ផលប្រយោជន៍មួយចំនួនដូចជា៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

**១.៤.៥.ការគ្រប់គ្រងសម្ភារបរិក្ខារ**

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ។ ចំពោះបញ្ជីគ្រប់គ្រងសម្ភារបរិក្ខារ នេះត្រូវរក្សាទុកឱ្យបានល្អ ប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពជាប្រចាំ គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**១.៤.៦.ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

**១.៤.៧.លិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ត្រូវធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និងផ្ញើជូនដល់អ្នកត្រូវបានចូលរួមកិច្ចប្រជុំ គ្រប់គ្នាទាំងអស់ឱ្យបានមុនពេលប្រជុំ។

លិខិតអញ្ជើញត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬជម្រាបនៅពេលប្រជុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់ជាមួយលិខិតអញ្ជើញ។

**១.៤.៨.ការបង្កើតរបៀបវារៈប្រជុំ**

គ្រប់ប្រជុំទាំងអស់ត្រូវមានរបៀបវារៈ ហើយត្រូវផ្ញើជូនដល់អ្នកចូលរួមជាមុន។ ជាការប្រសើរដល់អ្នកចូលរួមមានឱកាសចូលរួមក្នុងការរៀបរបៀបវារៈ។

ចំណុចមួយចំនួនដែលយើងគួរលើកមកក្នុងការបង្កើតរបៀបវារៈរួមមានដូចជា៖

- ការងារដែលត្រូវពិភាក្សា និងសម្រេច
- ព័ត៌មានដែលត្រូវជម្រាប
- ពេលវេលាសម្រាប់កិច្ចប្រជុំ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបីអាចបន្ថែមប្រធានបទផ្សេងទៀតដែលស្ថិតនៅ ក្នុងអំណាច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**១.៤.៩.ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណជន**

កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយបិតផ្សាយនៅលើក្ដាខៀនព័ត៌មានឃុំ សង្កាត់ និងនៅកន្លែងសាធារណៈក្នុងភូមិទាំងអស់ និងមធ្យោបាយផ្សព្វផ្សាយសមស្របដែលមាននៅមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

# ជំពូកទី២

# ដំណើរការគ្រប់គ្រងរដ្ឋបាលព្រៃកម្មសិទ្ធិ

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់ព្រែកឫស្សី

## ២.១. ប្រវត្តិ និងស្ថានភាពទូទៅ

ព្រែកឫស្សី គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង១០ របស់ក្រុងតាខ្មៅ ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹងសង្កាត់ដើមមៀន ខាងត្បូងទល់នឹងសំពង់សំណាញ់និងសង្កាត់តាក្តុល ខាងកើតទល់នឹងសង្កាត់តាខ្មៅ និងខាងលិចទល់នឹងខណ្ឌដង្កោ រាជធានីភ្នំពេញ។

### ២.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

យោងសៀវភៅឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងសៀវភៅទិន្នន័យរបស់សង្កាត់ព្រែកឫស្សីឆ្នាំ២០១៩ រៀបរៀងដោយមន្ទីផែនការខេត្តកណ្តាល ការគ្រប់គ្រងផ្នែករដ្ឋបាលសង្កាត់ព្រែកឫស្សី មានផ្ទៃដីចំនួន ២២៦.២០៩ហិកតា ចែកចេញជា៥ភូមិគឺៈ ភូមិក្រពើហា ភូមិក្រពើហាខាងកើត ភូមិព្រែកឫស្សី ភូមិព្រែកឫស្សីខាងលិច និងភូមិព្រែកអញ្ចាញ មានប្រជាពលរដ្ឋរស់នៅសរុប ២.៣៣៧គ្រួសារ ចំនួនប្រជាពលរដ្ឋសរុប ១១.០១២នាក់ ស្រី ៦.៤៤៥នាក់ ដងស៊ីតេប្រជាជន ៤.៣២៣/គម$^{២}$។[18]

### ២.១.២. ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋភាគច្រើន ជាអ្នកប្រកបរបរលក់ដូរនៅទីផ្សារក្នុងស្រុកនិងលក់ដូរនៅតាមផ្ទះចំនួន២៧.៤% ជាមន្ត្រីរាជការមួយចំនួន២១.៥% សិប្បកម្ម១.៨%ប្រកបររបរនេសាទចំនួន០.១%កម្មករចំនួន៧.១%កសិករចំនួន៥.៥% ជាបុគ្គលិកឯកជន២៨%និងផ្សេងៗមួយចំនួន៨.៦%ដែលអាចរកចំណូលបាន ជាធម្យមសម្រាប់ទ្រង់ជីវភាពគ្រួសារ។

### ២.១.៣.ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី

### ២.១.៤. សមាសភាពក្រុមប្រឹក្សា

យោងតាមប្រកាសក្រសួងមហាផ្ទៃលេខ ៣០៨៧ ប្រ.ក ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាសង្កាត់ និងសមាជិកសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចខាងក្រោមៈ

១- លោក ឆេង ឆៃ ជាប្រធានក្រុមប្រឹក្សាសង្កាត់

[18] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០២២-២០២៤ ទំព័រទី១០

២- លោក យូ សារី ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៣- លោក យុន ផាត ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៤- លោកស្រី ពត ផារី ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៥- លោក ហេង ផានិច្ច ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៦- លោក ឆន លីដា ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៧- លោក ម៉ឹង សុខលី ជាសមាជិកក្រុមប្រឹក្សាសង្កាត់។[19]

ទទួលស្គាល់សមាសភាពជាចៅសង្កាត់ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ នៃសង្កាត់ជាសមាជិកក្រុមប្រឹក្សាសង្កាត់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដូចមាននាមដូចខាងក្រោមៈ

១- លោក ឆេង ឆៃ ជាចៅសង្កាត់

២- លោក សារី ជាចៅសង្កាត់រងទី១

៣- លោក យុន ផាត ជាចៅសង្កាត់រងទី២។[20]

### ២.១.៥. គណៈកម្មាធិការនានារបស់សង្កាត់ព្រែកឫស្សី

១- គណៈកម្មាធិការ កសាងផែនការ និងថវិកា

២- គណៈកម្មាធិការ ទទួលបន្ទុកកិច្ចនារី និងកុមារ

៣- គណៈកម្មការ លទ្ធកម្ម

៤- គណៈកម្មាធិការ ផែនការគណនេយ្យភាពរួមស្តីពីការងារគណនេយ្យសង្គម

៥- គណកម្មការ ដោះស្រាយទំទាស់

៦- គណកម្មការ អេដស៍ ។

### ២.១.៦.ការអភិវឌ្ឍរបស់សង្កាត់ព្រែកឫស្សី

ផែនការអភិវឌ្ឍសង្កាត់ គឺមានអាណត្តិរយៈពេលប្រាំឆ្នាំ ដូចអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍសង្កាត់ ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយ រាល់បញ្ហាទាំងនោះ សំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

[19] សេចក្តីសម្រេច លេខ ៣០៨៧ ប្រ.ក ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០២២ ស្តីពីការទទួលសមាសភាព ក្រុមប្រឹក្សាសង្កាត់ ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល

[20] សម្ភាសជាមួយ លោក ឆេង ឆៃ ជាចៅសង្កាត់ ព្រែកឫស្សី នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២:៣០ នាទី

### ២.១.៧.កម្មវិធីវិនិយោគ

ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី អាណត្តិទី៤ នេះ បានរៀបចំនូវកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ សម្រាប់ឆ្នាំ២០២០-២០២២ ស្របតាមអាណត្តិនៃការគ្រប់គ្រងរបស់ក្រុមប្រឹក្សា ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (អនុក្រឹត្យលេខ១២៩ អនក្របក) ប្រកាសឲ្យប្រើប្រាស់នៅខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(អនុក្រឹត្យលេខ ១៥២ អនក្របក) ប្រកាសឲ្យប្រើនៅ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ (ប្រកាសអន្តរក្រសួងលេខ ៣៥១៤ ប្រ.ក) ស្តីពីការកែសម្រួលប្រការ១ ប្រកាសឲ្យប្រើនៅ ខែតុលា ឆ្នាំ២០១៣ នៃប្រកាសក្រសួងស្តីពីការកសាងផែនការ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ (ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក) ប្រកាសឲ្យប្រើនៅខែធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់នីតិវិធីលម្អិតក្នុងការកសាងផែនការនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង (ប្រកាសអន្តរក្រសួងលេខ ០៧៣ ផ.ក) ប្រកាសឱ្យប្រើនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ។

ការរៀបចំកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់នេះ ស្របតាមសេចក្តីណែនាំបច្ចេកទេស ដោយមានការចូលរួមពិគ្រោះយោបល់ជាមួយ ក្រុមប្រឹក្សាសង្កាត់ មេភូមិ ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ក្រុមតំណាងផលប្រយោជន៍ ពិសេសក្រុមយុវជននិងកុមារ អង្គការសង្គមស៊ីវិល វិស័យឯកជន គណៈពង្រឹងមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការវិភាគស្ថានភាព សក្តានុពល បញ្ហាប្រឈម និងតម្រូវការគម្រោងជាអាទិភាព។ សម្រាប់អាណត្តិទី៤ របស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល បានរៀបចំកម្មវិធី វិនិយោគ ៣ឆ្នាំរំកិលសង្កាត់នេះឡើង ដោយផ្អែកតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោមៈ

១. ចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ចនិងសង្គម

៨. ការធានានិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌។

**កម្មវិធីវិនិយោគ** ៣ឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សី មាន ៣ជំពូកគឺ៖ ទី១).បរិយាយអំពីស្ថានភាពទូទៅនិងបញ្ហាប្រឈមក្នុងសង្កាត់ ទី២).គម្រោងសកម្មភាពនៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ ទី៣).ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់ និងគម្រោងជាអាទិភាព ដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន សក្តានុពលនានាដើម្បីអភិវឌ្ឍសេដ្ឋកិច្ច លើកកម្ពស់គុណភាពសេវា ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមគោលការណ៍យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៥ នៃរដ្ឋសភា។[21] កំណត់ហេតុនៃការប្រជុំស្តីពីការប្រមូលពត៌មានអំពីសម្រាប់កម្មវិធីវិនិយោគ៣ឆ្នាំរំកិលអភិវឌ្ឍ(២០២០-២០២២) ឆ្នាំពីរពាន់ដប់ប្រាំបួន ខែឧសភា នាថ្ងៃទីដប់ប្រាំពីរ វេលាម៉ោងប្រាំបីព្រឹក នៅសាលាសង្កាត់ព្រែកឫស្សី បានរៀបចំកិច្ចប្រជុំណែនាំការប្រមូលព័ត៌មាន អំពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សីកិច្ចប្រជុំនេះស្ថិតក្រោមអធិបតីភាពលោក ឆេង ឆៃ ចៅសង្កាត់ ព្រែកឫស្សី។[22]

**ក. សមាសភាពចូលរួម**

សមាសភាពចូលរួម រួមមាន អស់លោក លោកស្រី សមាជិកក្រុមប្រឹក្សាសង្កាត់ គណៈកម្មាធិការកសាងផែនការនិងថវិកាសង្កាត់ ស្មៀន ជំនួយការសង្កាត់ មេភូមិ ដូចមានភ្ជាប់បញ្ជីវត្តមកជាមួយ។

**ខ. របៀបវារៈ**

១.មតិស្វាគមន៍របស់លោកចៅសង្កាត់

២.ការបង្ហាញពីគោលបំណងការប្រមូលព័ត៌មានអំពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សី ។

**គ. របៀបវារៈទី១**

លោក ឆេង ឆៃ ចៅសង្កាត់ព្រែកឫស្សី មានមតិបើកកិច្ចប្រជុំ ដោយបញ្ជាក់ពីគោលបំណងនៃកិច្ចប្រជុំដូចតទៅ៖

កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់សង្កាត់មាន ៣ជំហានគឺ ទី១.ការប្រមូលព័ត៌មានអំពីតម្រូវការរបស់មូលដ្ឋាន សម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទី២.ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ទី៣.ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល។ គោលបំណងនៃជំហានទី១នេះគឺដើម្បីប្រមូលព័ត៌មានបឋមស្តីពីតម្រូវការអភិវឌ្ឍរបស់មូលដ្ឋាន សម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការ

---

[21] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០២២-២០២៤ ទំព័រទី៧

[22] មាត្រា ៦៨នៃច្បាប់ស្តីពីការគ្រប់គ្រង ឃុំ សង្កាត់ ឆ្នាំ២០០១

យុទ្ធសាស្ត្រថវិកា គម្រោងថវិកាប្រចាំឆ្នាំ ដូច្នេះ គ.ផ.ថ ត្រូវឯកភាពគ្នាលើការកំណត់យកបញ្ហាទីតាំងនៃបញ្ហាមូលហេតុ តម្រូវការនិងដំណោះស្រាយនៅក្នុងសង្កាត់ ដើម្បីពិនិត្យ និងវិភាគលើស្ថានភាពទូទៅ និងសូមដាក់ជូនដល់ លោក លោកស្រី មានមតិពិភាក្សាឱ្យបានផុលផុស ធ្វើយ៉ាងណាឱ្យដំណើរការកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលនេះប្រកបដោយជោគជ័យ។

**ឃ. របៀបវារៈទី២**

លោក អាន ដារិទ្ធ ស្មៀនសង្កាត់ បានពន្យល់អំពីវិធីនៃការវិភាគស្ថានភាពទូទៅរបស់សង្កាត់ និងការរៀបចំតារាង ១.១ក តម្រូវការគម្រោងសកម្មភាពជាអាទិភាព។

នៅក្នុងការវិភាគស្ថានភាពទូទៅ ក៏ដូចជាតារាង ១.១.ក ត្រូវបានក្រុមការងារ គ.ផ.ថ រៀបរាប់ទៅតាមលំដាប់លំដោយមានដូចជា៖ សេចក្តីសង្ខេបទិន្នន័យចម្បង ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរួមមានផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ចផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

បន្ទាប់ពីមានការពិភាក្សាយ៉ាងល្អិតល្អន់រួចមក លោកប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់សមាជិកសមាជិកា ទាំងអស់ដែលបាន ចូលរួមក្នុងកិច្ចប្រជុំនាថ្ងៃនេះ ធ្វើឱ្យកិច្ចប្រជុំទទួលបានលទ្ធផលល្អប្រសើរ សូមជូនពរដល់សមាជិកចូលរួមទាំងអស់ជួបតែសំណាងល្អទទួលបានជ័យជំនះគ្រប់ភារកិច្ចនិងទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**២.១.៨. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់**

សង្កាត់ព្រែកឫស្សី ជានីតិបុគ្គលសាធារណៈដែលមានធនធាន ថវិកាសម្រាប់សកម្មភាពរបស់ខ្លួន។ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល សង្កាត់ សង្កាត់នីមួយៗមានមានហិរញ្ញវត្ថុ និងសម្បត្តិផ្ទាល់ខ្លួន។ ដូច្នេះរដ្ឋបាលសង្កាត់មានសិទ្ធិអំណាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន និងប្រភពចំណូល និងចំណាយរបស់ខ្លួនផង។[23]

**២.១.៩.ការរៀបចំ និងអនុម័តថវិការបស់សង្កាត់**

គម្រោងថវិការបស់សង្កាត់ព្រែកឫស្សី ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់ចៅសង្កាត់ និងដោយមានជំនួយពីគណៈកម្មកសាងផែនការ ថវិការបស់សង្កាត់ព្រែកឫស្សី រួមបញ្ជូនទៅក្រុមប្រឹក្សាសង្កាត់ ដើម្បីពិនិត្យ និងអនុម័ត។ ជារៀងរាល់ឆ្នាំ ដើរចងការរៀបចំការរបស់សង្កាត់ព្រែកឫស្សី ត្រូវបានកំណត់គោលដៅមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើរជួយផ្តល់ជាមតិយោបល់ ព្រមទាំងផ្ចិតមេដៃបញ្ជាក់ពីការចូលរបស់ខ្លួន។ ជារឿយៗ

[23] មាត្រា១៥ នៃអនុក្រឹត្យលេខ២៦ អនក្រ បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់

ក្រោយពីការប្រកាសជួយអោយការចូលរួមពីសំណាក់ប្រជាពលរដ្ឋហើយ ប្រជាពលរដ្ឋដែលរស់នៅ សង្កាត់ព្រែកឫស្សី ហាក់មិនចាប់អារម្មណ៍ និងពុំសូវឱ្យតម្លៃពីការចូលរួមរបស់ខ្លួនឡើយ។ ម្យ៉ាងវិញទៀត ដោយហេតុថាប្រជាពលរដ្ឋចាំបាច់ប្រកបរប្រចាំថ្ងៃជាជាការចូលរួមនេះ។

នៅដំណាក់កាលបន្ទាប់ ពីកាអនុម័តគម្រោងថវិកានៅថ្នាក់សង្កាត់រួចហើយចៅសង្កាត់ព្រែកឫស្សី បញ្ជូនគម្រោង។ ថវិកាទៅកាន់អភិបាលខេត្តកណ្តាល។ ក្រោយពីមានការឯកភាពលើគម្រោងថវិកានេះហើយ អភិបាលខេត្តកណ្តាល ស្តីបញ្ជូនគម្រោងតាមកកាន់ ចៅសង្កាត់ព្រែកឫស្សី វិញនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់ ពីការទទួលស្គាល់នៅគម្រោងថវិកា ដែលសេចក្តីជូនដំណឹងនេះក៏មានការចម្លងជូន និងភ្ជាប់ជាមួយគម្រោងបើកទៅ ឱ្យសេដ្ឋកិច្ច និងហិញ្ញវត្ថុ រតនាគារខេត្តកណ្តាលដែរ។[24]

### ២.១.១០.កំណត់ហេតុប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី

ឆ្នាំដប់ម្ភៃពីរ ខែធ្នូ ថ្ងៃទីសាមសិបមួយ វេលាម៉ោងប្រាំបីព្រឹក នៅសាលាសង្កាត់ព្រែកឫស្សី បានរៀបចំកិច្ចប្រជុំវិសាមញ្ញ របស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ក្រោមអធិបតីភាពលោក ឆេង ឆៃ ជាប្រធានក្រុមប្រឹក្សាសង្កាត់ ។

I.កូរ៉ុមប្រជុំនិងសមាសភាពចូលរួមប្រជុំ ៖

សមាជិក សមាជិកានៃក្រុមប្រឹក្សាសង្កាត់ ដែលបានអញ្ជើញចូលរួមប្រជុំ មានចំនួន០៧រូបលើ០៧រូប គ្រប់កូរ៉ុម អង្គប្រជុំ អាចដំណើរការបាន ។

**១.**របៀបវារៈនៃអង្គប្រជុំ៖

អង្គប្រជុំបានអនុម័តលើរបៀបវារៈ សំរាប់កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ មានដូចខាងក្រោម៖

1- ពិភាក្សាអំពីសេចក្តីពង្រាងបិទថវិកាសង្កាត់ឆ្នាំ២០២២
2- បញ្ហាផ្សេងៗ

## ២.២ ការពិភាក្សា និងការសម្រេច

**១).របៀបវារៈទី១ ៖** ពិភាក្សាអំពីសេចក្តីពង្រាងបិទថវិកាសង្កាត់ ឆ្នាំ២០២២

លោកឆេង ឆៃប្រធានអង្គប្រជុំបានមានប្រសាសន៍ថាសេចក្តីពង្រាងបិទថវិកាសង្កាត់ឆ្នាំសារពើពន្ធ២០២២ នេះមានសារៈសំខាន់ដែលសំខាន់លើសកម្មភាពរដ្ឋបាលទូទៅ និងការអភិវឌ្ឍនានាក្នុងដែនដីសង្កាត់យើង ដូចនេះសូមសមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ ជួយពិនិត្យ និងពិភាក្សាគ្នាលើពង្រាងបិទ ថវិកាសង្កាត់

[24] មាត្រា១៥ នៃអនុក្រឹត្យលេខ២៦ អនក្រ បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់

ឆ្នាំ២០២២ តើមានចំណុចណាខ្លះ ត្រូវបន្ថែម ឬបន្ថយសម្រាប់ប្រៀបធៀបគម្រោងថវិការនិងលទ្ធផលជាក់ស្តែង ដើម្បីឆ្លើយតបតបទៅនឹងតម្រូវការជាក់ស្តែងក្នុងមូលដ្ឋានសង្កាត់យើង ។[25]

កិច្ចបន្តមក លោក អាន ដារិទ្ធ ជាស្មៀនសង្កាត់ បានអានពង្រាងបិទថវិកាឆ្នាំ ២០២២ជូនអង្គប្រជុំជូនជ្រាប ដូច ខាងក្រោម៖

សរុបចំណូលចរន្ត(ក+ខ)482,299,000រស្មើនឹង69,39ភាគរយ

សរុបចំណូលចរន្ត(ក្រុមទី១+ក្រុមទី២)៖482,299,000រស្មើនឹង69,39ភាគរយ

ក្រុមទី១៖ចំណូលពិត(ប្រ.១+ប្រ.២)៖482,299,000រស្មើនឹង69,39ភាគរយ

ប្រភេទទី២ ៖ ចំណូលមិនមែនសារពើពន្ធ៖482,299,000រស្មើនឹង69,39ភាគរយ

+៧៣ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា ៖ 2,463,000រ ស្មើនឹង61,58ភាគរយ ក្នុងនោះមាន

-៧៣០២៨ ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ៖2,463,000រ ស្មើនឹង61,58ភាគរយ

-៧៣០៣១ ការជួលសហគ្រាសសាធារណៈ ៖0រ ស្មើនឹង0ភាគរយ

+៧៥ ការឧបត្ថម្ភ និងអំណោយ ៖ 479,836,000រ ស្មើនឹង69,43ភាគរយ ក្នុងនោះរួមមាន ៖

-៧៥០១១ ឧបត្ថម្ភកធនពីក្រសួង ស្ថាប័ន ៖ 195,902,000រ ស្មើនឹង99,95ភាគរយ

-៧៥០៣១ ការចូលរួមពីសមាសភាពអភិវឌ្ឍមូលដ្ឋាន ៖ 26,400,000រ ស្មើនឹង100ភាគរយ

-៧៥១០១ អតិរេកនៃការិយបរិច្ឆេទ ៖ 0រ ស្មើនឹង0ភាគរយ

-៧៥១១១ ឧបត្ថម្ភកធនពីថ្នាក់ជាតិ សម្រាប់ចំណាយវិនិយោគ ៖ 224,534,000រ ស្មើនឹង99,97ភាគរយ

-៧៥១២១ ឧបត្ថម្ភកធនពីរាជធានីខេត្ត សម្រាប់ចំណាយវិនិយោគ ៖ 31,000,000រ ស្មើនឹង100ភាគរយ

-៧៥១៣១ ចំណូលពីការចូលរួមចំណែករបស់ប្រជាជន ៖ 2,000,000រ ស្មើនឹង100ភាគរយ

I.**សរុបរួមចំណាយថវិកា** ( **ក**+**ខ** ) ៖ 423,158,933**រ ស្មើនឹង**58,28**ភាគរយ**

ក-សរុបចំណាយចរន្ត (ក្រុមទី១+ក្រុមទី២)៖ 423,158,933រ ស្មើនឹង58,28ភាគរយ

ក្រុមទី១ ៖ចំណាយពិត(ប្រ.១+ប្រ.២+ប្រ.៣+ប្រ.៤) ៖423,158,933រ ស្មើនឹង58,28ភាគរយ

ប្រភេទទី១ ៖ មធ្យោបាយនិងសេវា ៖ 423,158,933រ ស្មើនឹង58,28ភាគរយ

ជំពូក60 ការទិញ ៖ 16,495,100រ ស្មើនឹង55,05ភាគរយ ក្នុងនោះរួមមាន ៖

-60011 សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ ៖ 300,000រ ស្មើនឹង50ភាគរយ

-60012 សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំ ៖ 1,200,000 ស្មើនឹង40.0ភាគរយ

[25] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល ២០២២-២០២៤

-60013 សម្ភារៈផ្គត់ផ្គង់ថែទាំផ្លូវថ្នល់ ៖ 1,000,000 ស្មើនឹង41.67ភាគរយ

-60015 ប្រេងឥន្ធនៈ និងប្រេងរំអិល ៖ 3,564,000៛ ស្មើនឹង66ភាគរយ

-60021 សម្ភារៈការិយាល័យ ៖ 1,429,000៛ ស្មើនឹង39.69ភាគរយ

-60023 ការបោះពុម្ព ៖ 653,000៛ ស្មើនឹង24.7ភាគរយ

-60041 ឯកសណ្ឋាន ៖2,400,000៛ ស្មើនឹង85.71ភាគរយ

-60061 អគ្គិសនី ៖ 5,801,300៛ ស្មើនឹង80,57ភាគរយ

-60062 ទឹក ៖ 147,800៛ ស្មើនឹង26.79ភាគរយ

សេវាកម្ម ៖ 266,996,554៛ ស្មើនឹង49,94ភាគរយ ក្នុងនោះរួមមាន ៖

-61053 ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ៖ 247,396,554៛ ស្មើនឹង49,43ភាគរយ

-61091 ភ្នាក់ងារជាតិជាប់កិច្ចសន្យា ៖ 16,400,000៛ ស្មើនឹង62,12ភាគរយ

-61103 ប្រជុំ សិក្ខាសាលា និងសន្និសីទ ៖ ,000៛ ស្មើនឹង00ភាគរយ

-61142 សោហ៊ុយទូរគមនាគមន៍ ៖ 3,200,000៛ ស្មើនឹង66.67ភាគរយ

បន្ទុកបុគ្គលិក ៖ 135,490,600៛ ស្មើនឹង98,70ភាគរយ ក្នុងនោះរួមមាន ៖

-64033 រង្វាន់ ៖ 1,970,400៛ ស្មើនឹង61,58ភាគរយ

-64073 ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាសង្កាត់ ៖ 70,680,000៛ ស្មើនឹង100ភាគរយ

-64074 ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ ៖ 60,640,000៛ ស្មើនឹង99.08ភាគរយ

-64981 បន្ទុកបុគ្គលិកផ្សេងៗទៀត ៖ 2,200,000៛ ស្មើនឹង100ភាគរយ

អត្ថប្រយោជន៍សង្គម៖ 4,176,400៛ ស្មើនឹង51.2ភាគរយ ក្នុងនោះរួមមាន ៖

-60021 ជំនួយដល់ប្រជាជនសំរាកពេទ្យ ៖ 1,000,000៛ ស្មើនឹង78.13ភាគរយ

-60024 ជំនួយជនរងគ្រោះធម្មជាតិ ៖ 500,000៛ ស្មើនឹង25ភាគរយ

-60028 ជំនួយសង្គមផ្សេងៗទៀត ៖ 2,000,000៛ ស្មើនឹង47.62ភាគរយ

-62041 ឧបត្ថម្ភដល់អង្គការមូលដ្ឋាន ៖ 676,400៛ ស្មើនឹង100ភាគរយ

-62981 អត្ថប្រយោជន៍សង្គមផ្សេង ៖ 0៛ ស្មើនឹង0ភាគរយ

ចំណាយមិនបានគ្រោងទុក៖ 0៛ ស្មើនឹង0ភាគរយ ក្នុងនោះរួមមាន ៖

-69021 ចំណាយមិនបានគ្រោងទុកផ្សេងៗ ៖ 0៛ ស្មើនឹង0ភាគរយ

## II.ស្ថានភាពឥណទានឆ្នាំ២០២២និងអនិរេភាវីថវិការ

ឥណទានចំណាយប្រចាំឆ្នាំ២០២២

នៃថវិកាដំបូងមានចំនួន726,062,387របានអនុវត្តចំណាយចំនួន423,158,454រ

ឥណទាននៅសល់ទំនេរចំនួន302.903.933រ00។ឥណទានថវិកាឆ្នាំ២០២២

ដែលនៅសល់ទំនេរចំនួន302.903.933រ

ត្រូវបានលុបចោលដោយមិនបានបូកយោងទៅប្រើប្រាស់នៅក្នុងថវិកាឆ្នាំបន្ទាប់ឡើយ។[26]

អតិរេកការិយបរិច្ឆេទថវិកាឆ្នាំ២០២២

ដែលមានទឹកប្រាក់ចំនួន242.062.387ត្រូវបានផ្ទេរទៅក្នុងគណនីមូលនិធិបំរុងលេខ75101ដែលបានបើកនៅក្នុងលេខនានៃរតនាគារខេត្តកណ្តាល។ បន្ទាប់ពីការអានអង្គប្រជុំបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់ហើយបានសម្រេចឯកភាពអនុម័តលើការបិទបញ្ជីថវិកាឆ្នាំ២០២២ដោយសំឡេងយល់ស្របឲសំឡេង លើ៧រូប ។ លោក ឆេង ឆៃ ប្រធានអង្គប្រជុំ បានមានមតិបូកសរុប និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ដែលបានអញ្ជើញចូលរួមប្រជុំ ។ អង្គប្រជុំ បានបញ្ចប់នៅវេលាម៉ោងដប់មួយ នាថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និតស្នាល ។

### ២. ២.១.ចំណូល ចំណាយថវិការរបស់សង្កាត់

មានស្ថានភាព ហិរញ្ញវត្ថុថវិកាឆ្នាំ២០២១ របស់សង្កាត់ព្រែកឫស្សី មានចំណូល ចំណាយដូចតទៅះ

| | |
|---|---|
| – ចំណូលចរន្ត | 482.299.000 |
| – ចំណូលមូលធន | គ្មាន |
| – ផ្នែកចំណូលមូលនិធិឃុំសំរាប់រដ្ឋបាល | 225.000.000 |
| – ចំណូលមិនបានគ្រោងទុក | 20.000.000 |
| – សមាសភាគអភិវឌ្ឍមូលដ្ឋាន | 18.450.000 |
| – ចំណូលមូលនិធិឃុំសម្រាប់អភិវឌ្ឍ | 214.550.000 |
| – ចំណូលកម្រៃសេវារដ្ឋបាល | 1.200.000 |
| – ចំ/លពីការចូលរួមចំណែករបស់ប្រព | 500.000 |
| **ប្រាក់ចំណូលសរុបះ** | 961.999.000 |
| – ផ្នែកចំណាយ | |
| – ប្រាក់បំណាច់ក្រុមប្រឹក្សាឃុំ | 70.680.000 |
| – ប្រាក់ឧបត្ថម្ភភូមិ | 85.680.000 |

[26] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០២២-២០២៤ ទំព័រទី៣៣

- ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំ+ភ្ជុំបិណ្យ 2.800.000
- ប្រាក់ជួលជំនួយការ 19.200.000
- ប្រាក់ជួលគ្រូមត្តេយ្យសហគមន៍ 18.000.000
- ប្រាក់សមាគមក្រុមប្រឹក្សាឃុំ 674.800
- ប្រាក់ចំណាយមិនបានគ្រោងទុក 20.000.000
- ទូទាត់ប្រាក់រង្វាន់ 1.080.000
- ប្រជុំ សិក្ខាសាលា និងសន្និសិទ្ធ 2.000.000

**ប្រាក់ចំណាយសរុបៈ** 220.114.880

សំរាប់រដ្ឋបាល2022 វិភាជសរុបអ/ភិ+រដ្ឋបាល2022 សំរាប់អភិវឌ្ឍ2022។

### ២.២.២.ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាចៅសង្កាត់ និងមន្ត្រីភូមិ

យោងតាមអនុក្រឹត លេខ៣៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ២០២០ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់សមាជិកក្រុមប្រឹក្សាសង្កាត់និងមន្ត្រីភូមិនៃសង្កាត់ព្រែកឫស្សីដែលត្រូវអនុវត្តចាប់ពីថ្ងៃទី០១ខែមេសាឆ្នាំ២០២០ បានកំណត់ដូចខាងក្រោមៈ

| | | |
|---|---|---|
| ចៅសង្កាត់ | ១,១១០,០០០ | រៀល |
| ចៅសង្កាត់រង១និងចៅសង្កាត់រង២(១នាក់) | ៨៧០,០០០ | រៀល |
| សមាជិកក្រុមប្រឹក្សាសង្កាត់ | ៧៦០,០០០ | រៀល |
| មេភូមិ | ៤៣០,០០០ | រៀល |
| អនុប្រធានភូមិ | ៣១០,០០០ | រៀល |
| សមាជិកភូមិ | ២៨០,០០០ | រៀល |

### ២.២.៣. ប្រព័ន្ធទូទាត់ គណនេយ្យភាពលទ្ធកម្ម

សង្កាត់ ត្រូវបង្កើតគណនីប្រាក់បញ្ញើរតនាគារខេត្តក្រុង។ ចៅសង្កាត់ គឺជាអាណាប័ក និងមានសិទ្ធិពេញលេញលើការប្រមូល ឬសន្យាចំណាយ និងបញ្ជាចំណាយដោយផ្អែកលើថវិការដែលបានអនុម័ត។ ចៅសង្កាត់អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅឲ្យជំទប់របស់រដ្ឋបាលសង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់ចៅសង្កាត់។ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ។ ហើយអ្នកទទួលសិទ្ធិនិងបុគ្គលិករដ្ឋបាលសង្កាត់ព្រែកឫស្សី មិនត្រូវអនុញ្ញាតឲ្យកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយ លើកលែងក្នុងករណីទូទាត់បេឡាបុរេប្រទាន និងចំណូលដែលប្រមូលបានដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀត

សិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឱ្យមនុស្សតែមួយម្នាក់ឡើយ ហើយរតនាគាខេត្តកណ្ដាលត្រូវបំពេញមុខងារជាគណនេយ្យកររបស់សង្កាត់ព្រែកឫស្សី។

**២.៣.៤.ប្រព័ន្ធទូទាត់**

ការទូទាត់ផ្ទាល់ គឺជាការទូទាត់តាមរយៈរតនាគាខេត្ត ហើយការទូទាត់តាមរយៈបេឡាបុរេប្រទានត្រូវប្រើសម្រាប់តែចំណាយចរន្ត (លើកលែងប្រាក់បៀវត្ស ប្រាក់បំណាច់) និងចំណាយវិនិយោគរដ្ឋបាល។ ហើយការចំណាយមួយលើកៗចេញពីបេឡាបុរេប្រទានត្រូវមានចំនួនទឹកប្រាក់ នៅក្រោមកម្រិតមួយជាកំណត់ និងតាមនីតិវិធីបេឡាបុរេប្រទាន។

**២.២.៥.ប្រព័ន្ធគណនេយ្យ**

**គណនេយ្យហិរញ្ញវត្ថុ** គឺជាកិច្ចបញ្ជីការរាល់ចំណូលចំណាយនៅក្នុងប្រព័ន្ធគណនេយ្យ។ ហើយអ្នកដែលមានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ គឺគណនេយ្យករនៅរតនាគាខេត្តកណ្ដាល។

**គណនេយ្យថវិកា** គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូល ចំណាយ និងថវិកាដែលមានអនុម័ត។ អ្នកដែលមានភារកិច្ចក្នុងការទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកាគឺ លោក ឆេង ឆៃ ដែលជាចៅសង្កាត់ នៃសង្កាត់ព្រែឫស្សី។

**២.២.៦.កិច្ចលទ្ធកម្មសង្កាត់**

កិច្ចលទ្ធកម្ម គឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ទទួលបានទំនិញ សំណង់ ឬសេវាកម្ម។ ចំណែកឯលទ្ធកម្មវិញ សំដៅទៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ ឬសេវាកម្មតាមរយៈវិធីសាស្ត្រដែលបានកំណត់។[27]

គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មមានដូចជា៖

- លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមានតម្លាភាព ប្រសិទ្ធភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព
- អ្នកទទួលការ អ្នកផ្ដល់សេវា និងអ្នកផ្គត់ផ្គង់ត្រូវមានឱកាសស្មើៗគ្នា ដើម្បីចូលរួមក្នុងដំណើរការដេញ ថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ

ចំពោះសមាសភាពគណៈកម្មការលទ្ធកម្មរបស់សង្កាត់មាន ៤រូប ក្នុងនោះមានលោក ឆេង ឆៃ ជាប្រធានគណៈកម្មការលទ្ធកម្ម និងជាចៅសង្កាត់ព្រែកឫស្សី រួមទាំងសមាជិកក្រុមប្រឹក្សា ២រូប ហើយស្មៀនសង្កាត់

[27] សេចក្ដីសម្រេច លេខ០០៨/១៣ សសរ ឆ្នាំ២០១៨ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈកម្មការលទ្ធកម្ម សង្កាត់ព្រែកឫស្សី

១រូប ដែលបំពេញតួនាទីជាលេខាធិការឱ្យគណៈកម្មការលទ្ធកម្មសង្កាត់ព្រែកឫស្សី។ ដោយឡែកចំពោះវិធីសាស្ត្រវិញ គឺ ត្រូវអនុវត្តដូចជា ការដេញថ្លៃដោយមានការប្រកួតប្រជែងជាចំហ (ជាសាធារណៈ) ការស្ទង់តម្លៃក្នុងស្រុក និង ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ (ការចរចារតម្លៃផ្ទាល់)។[28]

### ២.២.៧.គោលការណ៍អភិវឌ្ឍ

### ២.២.៨. ចក្ខុវិស័យអភិវឌ្ឍ

នៅក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ប្រជាពលរដ្ឋនិងមានជីវភាពកាន់តែប្រសើរឡើងដោយធ្វើការកាត់បន្ថយអត្រាក្រីក្ររបស់ប្រជាជន តាមរយៈការគៀងគរដៃគូ អភិវឌ្ឍ ការបង្កើននូវចំណេះដឹងវិជ្ជាជីវៈ បង្កើតមុខរបរជូនប្រជាពលរដ្ឋ អប់រំផ្សព្វផ្សាយ ពីសុខមាលភាព និងការកែលម្អរហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដែលនៅមានសេសសល់ កន្លងមក អោយស្របតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី ៤ នៃរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ២.៣. គោលបំណងអភិវឌ្ឍ

ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ មានការពិភាក្សា ពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាពលរដ្ឋអង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងសង្កាត់ ដែលមានគោលបំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសង្កាត់។ ផែនការនេះទៀតសោធនិងធានាបានការអភិវឌ្ឍមួយ ប្រកបដោយនិរន្តរភាព និងចំទិសដៅដែលប្រជាពលរដ្ឋក្នុងសង្កាត់ចង់បាន។ [29]

### ២.៣.១. គោលដៅអភិវឌ្ឍ

ដើម្បីបន្តជម្រុញការកសាង និងអភិវឌ្ឍសង្កាត់ព្រែកឫស្សី ឱ្យសម្រេចបានសមិទ្ធិផលថ្មីៗថែមទៀត ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សីបានផ្តោតទៅលើសកម្មភាពសំខាន់ៗដូចខាងក្រោមៈ

១. ជម្រុញការបង្កបង្កើនផល ឱ្យអស់លទ្ធភាពផ្ទៃដីដាំដុះដែលមានស្រាប់ ជម្រុញការប្រើជីកំប៉ុស ដើម្បីកែប្រែគុណភាពដី ប្រើពូជថ្មី និងបច្ចេកទេសទំនើបទទួលបានទិន្នផលខ្ពស់។

២. បន្តគ្រប់គ្រងថែទាំ និងជួសជុលផ្លូវបេតុង ផ្លូវថ្មបំបែក ផ្លូវគ្រួសក្រហម និងការសាងសង់ផ្លូវថ្មីៗ ថែមទៀតស្របតាមតម្រូវការជាក់ស្តែងរបស់ប្រជាជន។

៣. ជម្រុញកូនចៅរបស់ប្រជាជនគ្រប់អាយុ ឱ្យបានចូលរៀនគ្រប់ៗគ្នា ដោយយកចិត្តទុកដាក់មានការជម្រុញពីអាណាព្យាបាលកុមារយកកុមារទៅរៀននៅមត្តេយ្យរដ្ឋនិងឯកជន។

---

[28] សៀវភៅអភិវឌ្ឍរយៈពេលប្រាំឆ្នាំរបស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០១៧-២០២២ ទំព័រទី២៥

[29] សៀវភៅអភិវឌ្ឍរយៈពេលប្រាំឆ្នាំរបស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០១៧-២០២២ ទំព័រទី២៨

៤. បន្តសកម្មភាពគាំទ្រស្ត្រីសម្រាលកូន និងស្ត្រីមានផ្ទៃពោះបាន ទៅពិនិត្យសុខភាពតាមការកំណត់របស់មណ្ឌលសុខភាព។
៥. ខិតខំលើកទឹកចិត្តស្ត្រីឱ្យចូលរួមជាថ្នាក់ដឹកនាំក្នុងការទទួលខុសត្រូវការងារកសាង និងអនុវត្តផែនការអភិវឌ្ឍ និងអភិបាលកិច្ចល្អក្នុងភូមិ សង្កាត់។
៦. បន្តការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋទូទៅដោយមិនប្រកាន់និន្នាការនយោបាយ តម្លាភាព និងគ្មានអំពើពុករលួយ។
៧. ពង្រឹង និងកែលម្អការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា តាមយន្តការច្រកចេញចូលតែមួយ។
៨. បន្តអនុវត្តគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព ទាំង៧ចំណុចឲ្យមានប្រសិទ្ធិភាព។
៩. បន្តជម្រុញសកម្មភាពវេទិកាផ្សព្វផ្សាយរបស់ក្រុមប្រឹក្សាសង្កាត់ និងនគរបាលជាមួយប្រជាជន ដើម្បីក្តាប់បានពីកង្វល់ ការថ្នាំងថ្នាក់ និងដំណោះស្រាយជូនប្រជាជន។
១០. លើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ថ្នាក់សង្កាត់ឱ្យមានតម្លាភាព យុត្តិធម៌តាមច្បាប់កំណត់ ជាធរមាន។[30]

### ២.៣.២. យុទ្ធសាស្ត្រអភិវឌ្ឍ

ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍនីមួយៗដែលបានកំណត់ខាងលើ។ ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី អាណត្តិទី៥ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍសង្កាត់ ដែលកំណត់តាមផ្នែកនីមួយៗ ដូចខាងក្រោម ៖

### ២.៣.៣. យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួន សម្រាប់ការអភិវឌ្ឍសង្កាត់ រយៈពេល ៥ ឆ្នាំ ខាងមុខនេះ ដូចខាងក្រោម៖
កែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ មានដូចជា ការជួសជុលផ្លូវបេតុងអាមេ ផ្លូវក្រាលថ្មជម្មជាតិ ស្ពារប្រឡាយរំដោះទឹក ការដាក់លូ រំដោះទឹក ។ល។ បង្កើនបច្ចេកទេសលើដំណាំរួមផ្សំនិងជម្រុញការសាងសង់ថ្មី និងជួសជុលកែលម្អអាគារសិក្សាឡើងវិញ ។

### ២.៣.៤. យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

ដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍរបស់សង្កាត់ព្រែកឫស្សីក្រុមប្រឹក្សាសង្កាត់ បាន កំណត់ យុទ្ធសាស្ត្រ មួយចំនួនមានដូចជា៖

[30] សៀវភៅអភិវឌ្ឍរយៈពេលប្រាំឆ្នាំ របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០១៧-២០២២

ជម្រុញកុមារទាំងពីរភេទបានចូលរៀនគ្រប់ៗគ្នា

ពង្រឹងការគ្រប់គ្រងបញ្ជីស្ថិតិសិស្ស និងស្ថិតិអក្ខរជន

ពង្រឹងការរៀនសូត្ររបស់សិស្ស

បង្កើនប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់

ជម្រុញការយល់ដឹងពីអនាម័យ ហូបស្អាត រស់នៅស្អាត ។

បង្កើនការថែទាំសុខភាពរបស់ប្រជាពលរដ្ឋ និងជម្រុញសេវាសុខភាពដល់ប្រជាពលរដ្ឋ

បន្តជម្រុញចាក់វ៉ាក់សាំងដូសជំរុញការពារកូវីដ ១៩ ដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្នា

បង្កើនមុខរបរវិជ្ជាជីវៈដល់ជនរងគ្រោះ និង ឧបត្ថម្ភចាស់ជរាគ្មានទីពឹង និងកុមារកំព្រា

ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្ររៀនពូកែទាំងនៅមធ្យមសិក្សា និងបឋមសិក្សា ។[31]

### ២.៣.៥. យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ជាការឆ្លើយតបទៅហ្នឹងយុទ្ធសាស្ត្រផ្នែកនេះក្រុមប្រឹក្សាសង្កាត់ បានយកចិត្តទុកដាក់ ក្នុងការជ្រើសរើសគម្រោងនានា ដើម្បីពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដូចខាងក្រោម៖

អប់រំផ្សព្វផ្សាយចំណេះដឹងពីបរិស្ថាន ធនធានធម្មជាតិ និងប្រែប្រួលអាកាសធាតុ

ដាក់ប៉ាណូផ្សព្វផ្សាយបរិស្ថាន

បំផុសចលនាដាំដើមឈើ

ជម្រុញសេវាកម្មដឹកសម្រាម

ផ្សព្វផ្សាយច្បាប់ជលផល ។ល។

### ២.៣.៦. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

បញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍ ប្រកបដោយចីរភាព ហេតុនេះទើបនៅក្នុងអាណត្តិទី៥ នៃក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សីបានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនសម្រាប់អនុវត្តរយៈពេល ៥ ឆ្នាំ ដូចខាងក្រោម ៖

ពង្រឹងការគ្រប់គ្រង និងអនុវត្តច្បាប់

ពង្រឹងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលសង្កាត់

[31] សម្ភាសជាមួយ លោក ឆេង ឆៃ ជាចៅសង្កាត់ ព្រែកឬស្សី នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២:00 នាទី

រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវសាធារណៈ

ពង្រឹងការយល់ដឹងអត្រានុកូលដ្ឋាន

ពង្រីកការផ្សព្វផ្សាយពត៌មាន និងទទួលដោះស្រាយបញ្ហាពីព័ត៌មានត្រឡប់

ជម្រុញការផ្សព្វផ្សាយច្បាប់អំពើហិង្សាឱ្យបានទូលំទូលាយ

ជម្រុញ ស្ត្រី កុមារ ឱ្យចូលរួមគ្រប់សកម្មភាពការងារអភិវឌ្ឍ។

# ជំពូកទី៣
# សមិទ្ធផល បញ្ហាប្រឈម
# និងដំណោះស្រាយ

# ជំពូកទី៣
# សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. សមិទ្ធផល

ស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល សម្រាប់ធ្វើការបង្កិតសេវាឱ្យកាន់តែជិតប្រជាពលរដ្ឋដើម្បីមានភាពងាយស្រួលក្នុងការទទួលយកវាប្រកបដោយ តម្លាភាព សមភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ជូនប្រជាពលរដ្ឋដោយដាក់ឱ្យរដ្ឋបាលសង្កាត់ព្រែកឫស្សីបានអនុវត្ត នូវប្រកាសអន្តរក្រសួង លេខ ១៤៣៤៤ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការលើកលែងការយកប្រាក់កម្រៃសេវា សាធារណៈមួយចំនួននៅថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់។ក្នុងនោះកិច្ចការបម្រើមូលដ្ឋានមានការងារជាច្រើនលើគ្រប់វិស័យដូចជា ការគ្រប់គ្រងរដ្ឋបាលទូទៅ ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ការអនុវត្តថវិកាសង្កាត់ ការងារសេដ្ឋកិច្ច សង្គមកិច្ច សន្តិសុខសណ្តាប់ធ្នាប់ ការបម្រើ សេវាសាធារណៈ គម្រោងផែនការអភិវឌ្ឍការងាររបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សីនិងការចុះបញ្ជីឈ្មោះបោះឆ្នោតជាដើម។

### ៣.១.១.ការគ្រប់គ្រងរដ្ឋបាល

ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី មានភារកិច្ចបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋមូលដ្ឋាន ។ មិនតែប៉ុណ្ណោះក្រុមប្រឹក្សាសង្កាត់ ក៏មានភារកិច្ចអភិបាលកិច្ចរាល់សកម្មភាពទូទៅក្នុងរស់នៅរបស់ប្រជពលរដ្ឋ មានការងារជាមូលដ្ឋាន លើការគ្រប់គ្រងរដ្ឋបាលជាច្រើនផ្នែកដូចជា ការគ្រប់គ្រងស្ថិតិប្រជាជន ការគ្រប់គ្រងលិខិតស្នាម និងផែនការអភិវឌ្ឍ និងថវិការបស់សង្កាត់ ដែលអនុវត្តក្នុងឆ្នាំ២០២១។[32]

### ៣.១.២.ការគ្រប់គ្រងស្ថិតិ

រដ្ឋបាលសង្កាត់ព្រែកឫស្សី បានអនុវត្តគោលការណ៍ណែនាំថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាល់ការចុះបញ្ជីអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ជូនប្រជាពលរដ្ឋយកទៅប្រើប្រាស់

[32] សម្ភាសជាមួយ លោក អាន ដារិទ្ធ ជាស្មៀននៅសង្កាត់ ព្រែកឫស្សី នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២:៤០ នាទី

ស្របច្បាប់ ជាក់ស្តែងក្នុងឆ្នាំ២០១៧ កុមារអាយុក្រោម ៥ឆ្នាំ ចុះសំបុត្រកំណើតបានចំនួន ២៦០នាក់ ស្មើនឹង ១០០%។

### ៣.១.៣. លិខិតបទដ្ឋានគតិយុត្ត និងលិខិតនានា

ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី អាណិតទី៤ ក្នុងឆ្នាំ២០២១ បានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងលិខិតនានា មានចំនួនដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ដីកាក្រុមប្រឹក្សា | ចំនួន | ០១ | ច្បាប់ |
| សេចក្តីសម្រេច | ចំនួន | ១០ | ច្បាប់ |
| សេចក្តីជូនដំណឹង | ចំនួន | ០៥ | ច្បាប់ |
| របាយការណ៍ | ចំនួន | ២០ | ច្បាប់ |
| កំណត់ហេតុ | ចំនួន | ៣០ | ច្បាប់ |
| លិខិតអញ្ជើញ | ចំនួន | ៨០ | ច្បាប់ |
| លិខិតបេសកកម្ម | ចំនួន | ១០ | ច្បាប់ |
| ទិដ្ឋាការធ្វើដំណើរការ | ចំនួន | ១០ | ច្បាប់ |
| លិខិតឧទ្ទេសនាម | ចំនួន | ១៥ | ច្បាប់ |
| លិខិតផ្ទេរសិទ្ធិ | ចំនួន | ០៣ | ច្បាប់ |
| សៀវភៅផែនការអភិវឌ្ឍ | ចំនួន | ១៥ | ច្បាប់ |
| សៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំ | ចំនួន | ១៥ | ច្បាប់ |

### ៣.១.៤. ស្ថិតិក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិក

| | | |
|---|---|---|
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ចំនួន | ៧ នាក់ |
| មេឃុំ ចៅសង្កាត់ | ចំនួន | ១ នាក់ |
| ជំទប់ទី១ ចៅសង្កាត់រងទី១ | ចំនួន | ១ នាក់ |
| ជំទប់ទី២ ចៅសង្កាត់រងទី២ | ចំនួន | ១ នាក់ |
| ស្មៀនឃុំ សង្កាត់ | ចំនួន | ១ នាក់ |
| បុគ្គលិកកិច្ចសន្យា | ចំនួន | ២ នាក់ |
| មេភូមិ | ចំនួន | ៥ នាក់ |
| អនុប្រធានភូមិ | ចំនួន | ៥ នាក់ |
| សមាជិកភូមិ | ចំនួន | ៥ នាក់ |

| | | |
|---|---|---|
| អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ | | គ្មាន |
| ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ | ចំនួន | ៣ នាក់ |

### ៣.១.៥. ដីកា សេចក្តីសម្រេច និងលិខិត

| | | |
|---|---|---|
| ដីកាដែលបានដាក់ចេញ | ចំនួន | គ្មាន |
| សេចក្តីសម្រេចដែលបានដាក់ចេញ | ចំនួន | គ្មាន |
| លិខិតរដ្ឋបាលដែលបានដាក់ចេញ | ចំនួន | ១៣ |
| លិខិតដែលបានទទួល | ចំនួន | ២១៧[33] |

### ៣.១.៦. កិច្ចប្រជុំក្រុមប្រឹក្សានិងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងសង្កាត់ (គ.ក.ន.ក)

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលសង្កាត់ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសង្កាត់ និង លិខិតបទដ្ឋានពាក់ព័ន្ធនឹងរដ្ឋបាលសង្កាត់ នៅក្នុងអាណត្តិទី៤ របស់ក្រុមប្រឹក្សាសង្កាត់ រដ្ឋបាលសង្កាត់ ព្រែកឫស្សី បានរៀបចំកិច្ចប្រជុំសាមញ្ញ កិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹង រដ្ឋបាលសង្កាត់ ឬគណៈកម្មាធិការនានា រួមមាន៖

| | | | |
|---|---|---|---|
| កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ចំនួន | ៦០ | លើក |
| កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ចំនួន | 0 | លើក |
| កិច្ចប្រជុំស្វាគមរបស់ក្រុមប្រឹក្សា | ចំនួន | គ្មាន | |
| កិច្ចប្រជុំ គ.ក.ន.ក | ចំនួន | ៦០ | លើក |

### ៣.១.៧. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល

ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្នុងអាណត្តិទី៤ ឆ្នាំ២០២១ សម្រេចបាននូវការបម្រើសេវារដ្ឋបាលជូន ប្រជាពលរដ្ឋរបស់ខ្លួនក្នុងមូលដ្ឋានមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| សំបុត្រកំណើត | ចំនួន | ៣០ | សន្លឹក |
| សំបុត្របញ្ជាក់កំណើត | ចំនួន | ៣០ | សន្លឹក |
| សេចក្តីចម្លងសំបុត្របញ្ជាក់ | ចំនួន | ៥៨ | សន្លឹក |
| សំបុត្រអាពាហ៍ពិពាហ៍ | ចំនួន | ២៥ | សន្លឹក |
| សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ចំនួន | ៤៩ | សន្លឹក |

[33] របាយការណ៍ស្តីពីការអនុវត្តការងាររបស់សង្កាត់ព្រែកឫស្សី ប្រចាំខែមីនា ឆ្នាំ២០២២

| | | |
|---|---|---|
| សំបុត្រមរណភាព | ចំនួន ១០ | សន្លឹក |
| សេចក្តីចម្លងសំបុត្រមរណភាព | ចំនួន ២៥ | សន្លឹក |

### ៣.១.៨.ការសម្រុះសម្រួលទំនាស់

ផ្អែកតាមតួនាទីនិងភារកិច្ចរបស់រដ្ឋបាលសង្កាត់ រដ្ឋបាលសង្កាត់ដើមមៀន បានខិតខំនិងយកចិត្តទុកដាក់ដោះស្រាយឬសម្រុះសម្រួលទំនាស់ដែលបានកើតមានឡើងក្នុងរយៈពេល៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាសង្កាត់។ ជាក់ស្តែង ទំនាស់មួយចំនួនត្រូវបានដោះស្រាយរួច និងទំនាស់មួយចំនួនទៀត ត្រូវបានស្នើទៅស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ ស្ថានភាពនៃការដោះស្រាយ ឬការសម្រុះសម្រួលទំនាស់ដែលបានកើតឡើងនៅក្នុងអាណត្តិរបស់ក្រុមប្រឹក្សា សង្កាត់ព្រែកឫស្សីមានដូចខាងក្រោម៖

-ទំនាស់ដែលបានដោះស្រាយឬសម្រុះសម្រួលរួចមានចំនួន១២ករណី

-ទំនាស់ដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធមានចំនួន២ករណី។

### ៣.១.៩. ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ

គណៈបញ្ជាការឯកភាពរដ្ឋបាលសង្កាត់ បានសហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាល ធ្វើសកម្មភាពរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋបានល្អ។ ដោយមានកម្លាំងប៉ូលិស ៤រូប និងប្រជាការពារ ៥០រូប ជាកម្លាំងស្នូលធ្វើសកម្មភាពផ្សព្វផ្សាយគោលការណ៍នានា ពិសេសគោលការណ៍នយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ធ្វើឱ្យសង្កាត់ទាំងមូលមានសណ្តាប់ធ្នាប់សង្គមល្អ។ ក្រៅពីនោះបានធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ ៩៧០សន្លឹក សៀវភៅគ្រួសារ ៤០០ក្បាល និងសៀវភៅស្នាក់នៅ ៤០៥ក្បាល។ ជាក់ស្តែងប៉ុស៏នគបាលរដ្ឋបាល សង្កាត់ព្រែកឫស្សីបានចុះផ្សព្វផ្សាយជូនប្រជាពលរដ្ឋចំពោះផលប៉ះពាល់ និងបញ្ហាផ្សេងៗមួយចំនួនដូចជា៖

| | | | |
|---|---|---|---|
| បង្ក្រាបបានល្បែងស៊ីសងចំនួន | ចំនួន | ២ | ករណី |
| ដោះស្រាយទំនាស់របស់ប្រជាពលរដ្ឋ | ចំនួន | ១០ | ករណី |
| បង្ក្រាបបទល្មើសព្រហ្មទណ្ឌ | ចំនួន | ១៥ | ករណី |
| នឹងបទល្មើសគ្រឿងញៀន | ចំនួន | ១០ | ករណី។ |

### ៣.១.១០. ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន វប្បធម៌ បេតិកភណ្ឌជាតិ

រដ្ឋបាលសង្កាត់ បានសហការណ៏ជាមួយក្រុមហ៊ុនឯកជនមួយ លើការប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹង ក្នុងភូមិទាំងប្រាំ។ ក្រុមប្រឹក្សាសង្កាត់ ភូមិ និងប្រជាការពារ ចុះអនាម័យជាប្រចាំ មួយសប្តាហ៍២ដង

ដើម្បីសម្អាតតាមផ្លូវជាតិលេខ២ ។ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ពីការរៀបចំទុកដាក់សំរាមតាមប្រភេទ និងជៀសវាងការចោលសំរាមក្នុងទឹកស្ទឹង។

**៣.១.១១. ការងារសហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន**

សហការគាំទ្រដល់ក្រុមការងារចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ ក្នុងការវាស់វែង និងរៀបចំបែបបទស្នើសុំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋ សម្រេចបាន ១០០% ។ ស្ថានភាពជំងឺកូវីដ១៩ នៅសង្កាត់ព្រែកឫស្សីគិតចាប់តាំងពីព្រឹត្តការណ៍សហគមន៍ ២០កុម្ភៈ រហូតមកដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ នេះ មានអ្នកឆ្លងជំងឺកូវីដ១៩ សរុប១៥៤នាក់ ស្រី៧៧នាក់ ក្នុងនោះមានកុមារចំនួន ១៧នាក់ ស្រី ៩នាក់ បានជាសះស្បើយទាំងអស់ និងមានអ្នកស្លាប់ដោយសារជំងឺកូវីដ១៩ សរុប ៨នាក់ ស្រី ៣នាក់ ចំពោះអ្នកស្លាប់ដោយសារជំងឺកូវីដ១៩ បានទទួលប្រាក់ឧបត្ថម្ភពីមន្ទីរក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ក្នុងសពមួយដែលមានសមាជិកមួយនាក់ទទួលបានប្រាក់ឧបត្ថម្ភ ៤៤០,០០០រៀល សមាជិកចាប់ពី២នាក់ទៅ៣នាក់ទទួលបានប្រាក់ឧបត្ថម្ភ ៦២៥,០០០រៀល និងសមាជិកចាប់ពី៤នាក់ឡើងទទួលបានប្រាក់ឧបត្ថម្ភ៧៦០,០០០រៀល និងប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងសពមួយទទួលបានប្រាក់ឧបត្ថម្ភ ២,០០០,០០០រៀល ។ អង្គការមិត្តសម្លាញ់ និងអង្គការការីតាសកម្ពុជា បានជួយឧបត្ថម្ភស្បៀងអាហារមួយចំនួនដល់ពលរដ្ឋដែលរងគ្រោះពីការបិទខ្ទប់ ជាពិសេសគ្រួសារធ្វើចត្តាឡីស័ក។ សហការជាមួយមន្ទីរអភិវឌ្ឍ ចុះស្រង់ទិន្នន័យអនាម័យ និងទឹកស្អាត ដើម្បីដាក់ផែនការ ឈានទៅដល់ការបញ្ឈប់បន្ទោរបង់៣សវាល ៣សកាល(ODF) ទូទាំងសង្កាត់។ សហការជាមួយអង្គការតស៊ូមតិ និងគោលនយោបាយ(API) លើគម្រោងគណនេយ្យភាពសង្គម ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល។

**៣.១.១២. ការឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត**

ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្នុងអាណត្តិទី៤ ឆ្នាំ២០២១ ក្រុមប្រឹក្សាបានរៀបចំការចុះឈ្មោះមានចំនួនដូចក្រោម៖

| | | | |
|---|---|---|---|
| ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មីខែនេះ | ចំនួន | ៤ | នាក់ |
| ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ចំនួន | ២៦៥ | នាក់ |
| ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | ចំនួន | ៧១៤៨ | នាក់ |

**៣.១.១៣.គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាសង្កាត់**

ក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិការបស់រដ្ឋបាលសង្កាត់ សរុបចំនួន៦គម្រោង តម្លៃ១.២៣៨.៨៨៥.៨៨៩រៀល ក្នុងនេះមាន៖ ផ្នែកសេដ្ឋកិច្ចមានគម្រោងចំនួន៦គម្រោង តម្លៃចំនួន១.២៣៨.៨៨៥.៨៨៩រៀល

ផ្នែកសង្គមកិច្ចមានគម្រោងចំនួន០គម្រោង តម្លៃចំនួន០រៀល ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានគម្រោងចំនួន០តម្លៃចំនួន០ ផ្នែកសេវារដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ មានគម្រោងចំនួន០តម្លៃចំនួន០។

### ៣.១.១៤.គម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង

ដូចគ្នានេះដែរ ចំពោះគម្រោងវិនិយោគរបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី ដែលបានអនុវត្តជាក់ស្តែង ក្នុងអាណត្តិរបស់ក្រុមប្រឹក្សានេះ សរុបចំនួន៦គម្រោង តម្លៃគម្រោងចំនួន៤៨៩.១២១.១១៨រៀល ក្នុងនេះមាន៖ ផ្នែកសេដ្ឋកិច្ចមានគម្រោងចំនួន៦គម្រោង តម្លៃចំនួន៤៨៩.១២១.១១៨រៀល

ផ្នែកសង្គមកិច្ចមានគម្រោងចំនួន០គម្រោង តម្លៃចំនួន០រៀល

ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានគម្រោងចំនួន០តម្លៃចំនួន ០ ផ្នែកសេវារដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ មានគម្រោងចំនួន០តម្លៃចំនួន០។

ដោយឡែក គម្រោងរបស់សង្កាត់២០២២ គិតថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ មានតម្លៃសរុប ៣៩៦.៩៣៣.១៣៣(រៀល)មានដូចខាងក្រោម៖

**ក)-គម្រោងសង្កាត់ដែលពុំទាន់ធ្វើលទ្ធកម្ម មានតម្លៃគម្រោងសរុប**៣៩៦.៩៣៣.១៣៣(រៀល)

ក្នុងនេះមាន៖ គម្រោងសាងសង់ផ្លូវចាក់ថ្ម ប្រវែង៧១៥ម ទទឹង៥ម នៅភូមិព្រែកអញ្ចាញ មានតម្លៃគម្រោង២៨៣.៩៣៣.១៣៣រៀល

គម្រោងសាងសង់លូដោះទឹក ប្រវែង២០០ម មុខកាត់៦តឹក នៅភូមិព្រែកឫស្សី មានតម្លៃគម្រោង ៥៦.៥០០.០០០រៀល

គម្រោងសាងសង់លូដោះទឹក ប្រវែង២០០ម មុខកាត់៦តឹក នៅភូមិក្រពើហាមានតម្លៃ៥៦.៥០០.០០០ រៀល ។

### ៣.១.១៥.ការអនុវត្តថវិកា

ក្នុងអំឡុង៥ឆ្នាំនៃអាណត្តិក្រុមប្រឹក្សាសង្កាត់ រដ្ឋបាលសង្កាត់ព្រែកឫស្សី បានអនុវត្តថវិកាដូចខាងក្រោម៖

| ឆ្នាំ | ចំណូល(គិតលានរៀល) | | | ចំណាយ(គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | **អនុម័ត** | **ជាក់ស្តែង** | **ភាគរយ** | **អនុម័ត** | **ជាក់ស្តែង** | **ភាគរយ** |
| ២០១៧ | ២៤០.០៧៧.១៤២ | ២២៨.០៨៦.៥៤២ | ៩៥ | ២៤០.០៧៧.១៤២ | ១៧៥.៣៤៧.៤០០ | ៧៣.០៣ |
| ២០១៨ | ២៨៨.៩៧៩.១៤២ | ២៨៦.៥៧៩.១៤២ | ៩៩.១៩ | ២៨៨.៩៧៩.១៤២ | ១៧៧.៩៦៩.៩៨៣ | ៦១.៥៨ |
| ២០១៩ | ៤៣៩.៧២១.២០៤ | ៤៣៨.៩៨៨.២០៤ | ៩៩.៨៣ | ៤៣៩.៧២១.២០៤ | ៣២៥.៩២៤.២២៧ | ៧៤.១២ |

| ឆ្នាំ | ចំណូល(គិតលានរៀល) | | | ចំណាយ(គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | **អនុម័ត** | **ជាក់ស្តែង** | **ភាគរយ** | **អនុម័ត** | **ជាក់ស្តែង** | **ភាគរយ** |
| ២០២០ | ៥៨៨.០៥០.៣២៧ | ៤៩៤.៤៤៣.០២៧ | ៨៤.០៨ | ៥៨៨.០៥០.៣២៧ | ៣៨២.៤៥៤.៤០៣ | ៦៥.០៣ |
| ២០២១ | ៥១៩.០៦២.២៧៤ | ៤០៦.៨៥៤.០០០ | ៧៨.៣៨ | ៥១៩.០៦២.២៧៤ | ២៧៤.៨៥៣.៨៨៧ | ៥២.៩៥ |
| **សរុប** | ២.០៧៥.៨៩០.០៨៩ | ១.៨៥៤.៦៨០.៩១៥ | ៨៩.៣៤ | ២.០៧៥.៨៩០.០៨៩ | ១.៣៣៦.៥៤៩.៩០០ | ៦៤.៣៨ |

ទន្ទឹមនេះដែរ ស្ថានភាពថវិការបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី ឆ្នាំ២០២២ គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ រួមមាន៖

**ក)-ស្ថានភាពថវិកា(គិតជាលានរៀល)**

- ផ្នែកចំណូល៖ អនុម័តចំនួន695.062.387រៀល ជាក់ស្តែងចំនួន254.500.000រៀល និងនៅសល់ចំនួន440.562.387រៀល
- ផ្នែកចំណាយ៖ អនុម័តចំនួន695.062.387រៀល ជាក់ស្តែងចំនួន117.922.137រៀល និងនៅសល់ចំនួន577.140.250រៀល ។

**ខ)-ស្ថានភាពសាច់ប្រាក់រដ្ឋទេយ្យបុរេប្រទាន**

សាច់ប្រាក់រដ្ឋទេយ្យបុរេប្រទាន៖

ចំណូលចំនួន34.492.000រៀល ចំណាយចំនួន.000រៀល និងនៅសល់ចំនួន34.492.000រៀល ។

**គ)-ស្ថានភាពសាច់ប្រាក់ផ្សេងៗទៀត ក្រៅពីរដ្ឋទេយ្យបុរេប្រទាន**

សាច់ប្រាក់ផ្សេងៗទៀត៖

ចំណូលចំនួន500.000រៀល ចំណាយចំនួន0 និងនៅសល់ចំនួន500.000រៀល ។

### ៣.១.១៦.ការគ្រប់គ្រងទ្រព្យសម្បត្តិ

គិតមកដល់ត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ រដ្ឋបាលសង្កាត់ព្រែកឫស្សី មានទ្រព្យសម្បត្តិមួយចំនួនដូចជា៖

ទ្រព្យសម្បត្តិដែលបានទិញឬទទួល (ថ្មី) ចំនួន0

ទ្រព្យសម្បត្តិដែលបានកាត់ចេញ ចំនួន0

ទ្រព្យសម្បត្តិសរុបចំនួន៣៤ ។

### ៣.១.១៧. ការអភិវឌ្ឍសមត្ថភាព

ក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាសង្កាត់ រដ្ឋបាលសង្កាត់ព្រែកឫស្សី ទទួលបានការបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងឬស្ថាប័ន ឬអង្គការសមាគម ឬអង្គភាពពាក់ព័ន្ធចំនួន៧៥វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន១៥០នាក់ (ស្រី២៣នាក់)។

### ៣.១.១៨.សកម្មភាពសេវាសង្គម

នៅក្នុងអំឡុង៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាសង្កាត់ រដ្ឋបាលសង្កាត់ព្រែកឫស្សី បានយកចិត្តទុកដាក់សម្របសម្រួល គាំទ្រ និងដោះស្រាយបញ្ហាសេវាសង្គមចាំបាច់មួយចំនួន សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើងតាមរយៈការងារឬសកម្មភាពសេវាសង្គមនៅសង្កាត់ រួមមាន៖

មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីរដ្ឋបាលសង្កាត់ចំនួន០

គ្រួសារងាយរងគ្រោះគាំទ្រដោយរដ្ឋបាលសង្កាត់ សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ)ចំនួន០នាក់

គ្រួសារងាយរងគ្រោះគាំទ្រដោយរដ្ឋបាលសង្កាត់ ដែលទទួលបានទឹកស្អាតប្រើប្រាស់ចំនួន០

គ្រួសារងាយរងគ្រោះគាំទ្រដោយរដ្ឋបាលសង្កាត់ ដែលទទួលបានបង្គន់អនាម័យប្រើប្រាស់ ចំនួន០

គ្រួសារងាយរងគ្រោះដែលរដ្ឋបាលសង្កាត់បានចុះកំណត់អត្តសញ្ញាណចំនួន៤៦២គ្រួសារ

ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដែលទទួលការគាំទ្រពីរដ្ឋបាល សង្កាត់ចំនួន០នាក់។

### ៣.១.១៩.ការងារអត្រានុកូលដ្ឋាន

ក្នុងអំឡុង៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាសង្កាត់ រដ្ឋបាលសង្កាត់ព្រែកឫស្សី បានខិតខំយកចិត្តទុកដាក់ផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាជន ស្របតាមបែបបទ នីតិវិធី និងគោលការណ៍ណែនាំរបស់ក្រសួងឬស្ថាប័នមានសមត្ថកិច្ច។ ជាក់ស្តែង ក្នុងអាណត្តិរបស់ក្រុមប្រឹក្សានេះ រដ្ឋបាលសង្កាត់ព្រែកឫស្សី បានផ្តល់សេវាអត្រានុកូលដ្ឋាន រួមមាន៖

សំបុត្រកំណើតចំនួន១០៦៤នាក់ សំបុត្របញ្ជាក់កំណើតចំនួន៤២២នាក់

សេចក្តីចម្លងសំបុត្រកំណើតចំនួន២២៥៤សន្លឹកនិងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតចំនួន៧៦៤សន្លឹក ។ សំបុត្រអាពាហ៍ពិពាហ៍ចំនួន៣៥៧គូ និងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន៧៥៤សន្លឹក។សំបុត្រមរណភាពចំនួន២៤៧នាក់ និងសេចក្តីចម្លងសំបុត្រមរណភាពចំនួន៦២៥នាក់ ។

### ៣.១.២០.ការផ្តល់សេវារដ្ឋបាល

នៅថ្នាក់សង្កាត់ រដ្ឋបាលសង្កាត់ជាច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាជនស្របតាមបែបបទនិងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល។ ជាក់ស្តែង ក្នុងអំឡុង៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សា

សង្កាត់ព្រែកឫស្សី បានផ្តល់សេវារដ្ឋបាលចំនួន៤៦៩៧ និងទទួលបានចំណូលពីសេវានេះ ចំនួន ១៣.៩២៧.០០០រៀល។

**ការងារសេដ្ឋកិច្ច សង្គមកិច្ច** ក្នុងរយៈពេល ៥ឆ្នាំ សង្កាត់ព្រែកឫស្សីយើងកសាងផ្លូវចាក់បេតុងបានចំនួន ១៣ខ្សែ មានប្រវែងសរុប ៥,៦៥៦ម៉ែត្រ ដាក់លូរំដោះទឹក ៦កន្លែង មានប្រវែងសរុប ១,៤៦២ម៉ែត្រ ជួសជុលផ្លូវចាក់បេតុងប្រវែង៣៨៨ម៉ែត្រ ទទឹង៥ម៉ែត្រ និងចាក់ថ្មមិចប្រវែង ១,៤៦១ម៉ែត្រសរុប១,៨៥៩ ម៉ែត្រ ចាក់កំទេចថ្មប្រវែង ៥០ម៉ែត្រ ចាក់ដីសប្រវែង ១០០ម៉ែត្រ កសាងទទឹកប្រវែង ៤៥០ម៉ែត្រ ទទឹង ១ម៉ែត្រ ធ្វើរ៉ឺហ្គ័រ និងស្តាលូប្រវែង ២៦០ម៉ែត្រ ។ ក្នុងការអភិវឌ្ឍនេះមានការចូលរួមគាំទ្រជួយឧបត្ថម្ភមានដូចតទៅ ៖

- រដ្ឋបាលខេត្តកណ្តាលបានជួយកសាងផ្លូវបេតុងអាមេចំនួន ៣ខ្សែ ខ្សែទី១នៅភូមិព្រែកអញ្ចាញប្រវែង ៤៨៧ម៉ែត្រ ទទឹង៤ម៉ែត្រ ខ្សែទី២ នៅភូមិព្រែកឫស្សីប្រវែង ១២០០ម៉ែត្រ ទទឹង ៥ម៉ែត្រ សរុប ១៦៨៧ម៉ែត្រ ។ ដាក់លូចំនួន ២ខ្សែ នៅភូមិក្រពើហាប្រវែង ៤៧៥ម៉ែត្រ និងភូមិព្រែកអញ្ចាញប្រវែង ៤៨០ម៉ែត្រ សរុប ៩៥៥ម៉ែត្រ និងខ្សែទី៣ នៅភូមិក្រពើហាខាងក្រោយពេទ្យជ័យជំនះប្រវែង ៣៩៨ ម៉ែត្រ ទទឹង៨ម៉ែត្រ ។
- មន្ទីរសាធារណៈការខេត្តកណ្តាលបានជួយឧបត្ថម្ភចាក់ថ្មមិចនៅភូមិក្រពើហាប្រវែង ៥០ម៉ែត្រ ទទឹង ១០ម៉ែត្រ កសាងផ្លូវចាក់បេតុង១ខ្សែនៅភូមិក្រពើហាកើតប្រវែង ៨០០ម៉ែត្រ ទទឹង ៨ម៉ែត្រ កំពុងដាក់លូប្រអប់មុខកាត់០,៥ម៉ែត្រ ប្រវែង២០០ម៉ែត្រ និងស្តាប្រឡាយទឹកបាន១លើក ជាប់ព្រំប្រទល់សង្កាត់កំពង់សំណាញ់។ ជួលជុលផ្លូវបេតុង១ខ្សែនៅភូមិព្រែកឫស្សី ប្រវែង៣៨៨ម៉ែត្រ ទទឹង៥ម៉ែត្រ។
- មូលនិធិក្រុងបានឧបត្ថម្ភបេតុងប្រវែង ៥០៦ម៉ែត្រ និងលូប្រវែង ៣៦០ម៉ែត្រថវិកាសរុប **៣៩៧,៩០០.០០០** និងដាក់លូនៅភូមិក្រពើហាកើតប្រវែង ២០១ម៉ែត្រ មុខកាត់ ៦តឹក។
- មូលនិធិសង្កាត់កសាងផ្លូវបេតុងបានចំនួន ៣ខ្សែ ខ្សែទី១ នៅភូមិព្រែកអញ្ចាញប្រវែង ១៥៣ម៉ែត្រ អស់ថវិកា ១៨,៥៤៦ .០០០រៀល ខ្សែទី២ នៅភូមិក្រពើហាកើត និងភូមិព្រែកឫស្សីប្រវែង ៤១៥ម៉ែត្រ ម៉ែត្រ អស់ថវិកា ៨៨.៧០៤.០០០ រៀល និងខ្សែទី៣ ប្រវែង ២១៤ម៉ែត្រ ទទឹង ៤ម៉ែត្រ អស់ថវិកា ៧២.៣៧៣.០០០រ សរុបទាំងអស់ប្រវែង **៧៨២**ម៉ែត្រ ថវិកាសរុបចំនួន **១៧៩.៦២៣.០០០** រៀល និងផ្លូវចាក់បេតុងខាងក្រោយវត្តក្រពើហាប្រវែង៦៥ម៉ែត្រ ទទឹង ៤ម៉ែត្រ ។[34]

[34] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០២២-២០២៤

- លោក អេង ថន កសាងផ្លូវបេតុងចំនួន ២ខ្សែ ប្រវែង ៨២១ម៉ែត្រ ទទឹង ៥ម៉ែត្រ អស់ថវិកា **៦៥.៥៨៥ដុល្លា** ជួសជុលផ្លូវចាក់ថ្មមិចចំនួន ២ខ្សែ ប្រវែង ៨០២ម៉ែត្រ ទទឹង ៦ម៉ែត្រ អស់ថវិកា **៩.៣៣០**ដុល្លា និងដាក់លូនៅភូមិព្រែកអញ្ចាញប្រវែង ១៥១ម៉ែត្រ មុខកាត់ ០,៦ម៉ែត្រ អស់ថវិកា **៦.០៤០**ដុល្លា សរុបថវិកាទាំងអស់ **៨០.៩៥៥ដុល្លា ។**
- លោក អេង ថន លោកសុខ សុធារ៉ា និងលោកធាង ទ្រី បានចាក់ថ្មមិចនៅភូមិព្រែកអញ្ចាញ ប្រវែង ៦០២ម៉ែត្រ អស់ថវិកា **៦.០០០ ដុល្លា** ។
- លោក ថេង ង៉ែត ជាប្រជាជនដែលរស់នៅក្នុងភូមិក្រពើហាកើត បានចាក់ផ្លូវបេតុង ប្រវែង១០៥ម៉ែត្រ អស់ថវិកា ៧.២៥០ដុល្លា ។
- លោក ប៉ាញ់ ប៉េងឃុន ជួយផ្លូវបេតុងនៅភូមិក្រពើហាកើតប្រវែង ៧៦ម៉ែត្រ ទទឹង៣ម៉ែត្រ ។
- សប្បុរសជន បានកសាងផ្លូវចាក់បេតុងប្រវែង ៤៥០ម៉ែត្រ ទទឹង ៥ម៉ែត្រ និងចាក់បេតុងនៅភូមិក្រពើហាកើត ប្រវែង ៤២ម៉ែត្រ ទទឹង ៣ម៉ែត្រ អស់ថវិកា ៨០០.០០០៛ ចាក់កំទេចថ្មប្រវែង ៥០ម៉ែត្រ ។ ចាក់ដីសនៅភូមិក្រពើហា ប្រវែង១០០ម៉ែត្រ និងកសាងទទឹកប្រវែង៤៥០ម៉ែត្រ ទទឹង១ម៉ែត្រ។
- លោក ចៅសង្កាត់ និងសប្បុរសជន បានធ្វើរ៉ុហ្គ័រ និងដាក់លូ១កន្លែង នៅភូមិព្រែកអញ្ចាញអស់ថវិកា ៤០០.០០០ រៀល និងដាក់លូប្រវែង ១៥៥ម៉ែត្រ មុខកាត់៦តឹក និង៣តឹក អស់ថវិកា ៣.៩០០ដុល្លា
- លោក អភិបាលក្រុង និងសប្បុរសជនភូមិក្រពើហាកើតបានជួសជុលផ្លូវប្រវែង ៧ម៉ែត្រ ទទឹង ៤ម៉ែត្រ
- អស់ថវិកា ៧៣០.០០០ រៀល ។ រដ្ឋបាលសង្កាត់ បានសហការជាមួយមន្ទីរកសិកម្មខេត្ត លើការអប់រំបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសដាំដុះ ការប្រើប្រាស់ជី និងថ្នាំ ដល់ប្រជាពលរដ្ឋ និងការលើកទឹកចិត្តឱ្យប្រើប្រាស់ជីធម្មជាតិ។ រដ្ឋបាលសង្កាត់ បានបង្កើតសមាគមមនុស្សចាស់ និងកាអនុវត្តគោលនយោបាយគាំពារសង្គម ដែលរដ្ឋបានកំណត់ និងមានការចូលរួមពីសប្បុរសជន។ បច្ចុប្បន្នសមាគមមនុស្សចាស់សង្កាត់ មានសមាជិកសរុប ៥២២នាក់ មានមូលនិធិទ្រទ្រង់សមាគម ដោយការចូលរួមពីសមាជិកក្នុង ១នាក់១០០០៛ ក្នុង១ខែ និងមានការឧបត្ថម្ភពីសប្បុរសជន ដើម្បីប្រគល់ជូនសមាជិកគ្រួសារអ្នកស្លាប់ក្នុងម្នាក់ៗ ៤០០ ០០០.៛ សរុប ៥ឆ្នាំមានសមាជិកស្លាប់ ៥១ នាក់ ចំណាយថវិកាសរុប ២០ ៤០០ ០០០.៛។និងសួរសុខទុក្ខ១៦នាក់ ថវិកា១ ៦០០ ០០០រៀល ។រដ្ឋបាលសង្កាត់បានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់និងគណៈកម្មាធិការនានា ដើម្បីជួយគាំពារដល់ស្ត្រីនិងកុមារ ស្ត្រីសម្រាលកូន មានផ្ទៃពោះ ចាស់ជរាគ្មានទីពឹង ជនពិការ កុមារកំព្រាជនងាយរងគ្រោះ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។សង្កាត់មានមណ្ឌលសុខភាព ១កន្លែង មាន

បុគ្គលិក ១០នាក់ ស្រី ៩នាក់ ដែលមានសមត្ថភាពពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋជាប្រចាំថ្ងៃ ធ្វើឲ្យស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋ ពិសេសស្ត្រី និងកុមារ មានសុខភាពល្អ។

## ៣.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ព្រែកឫស្សី គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង១០ របស់ក្រុងតាខ្មៅ ខេត្តកណ្ដាល មានព្រំប្រទល់ខាងជើងទល់នឹងសង្កាត់ដើមមៀន ខាងត្បូងទល់នឹងកំពង់សំណាញ់និងសង្កាត់តាក្ដុល ខាងកើតទល់នឹងសង្កាត់តាខ្មៅ និងខាងលិចទល់នឹងខណ្ឌដង្កោ រាជធានីភ្នំពេញ។

យោងសៀវភៅឯកសារព័ត៌មានស្ថានភាព ស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច និងសៀវភៅទិន្នន័យរបស់សង្កាត់ព្រែកឫស្សីឆ្នាំ២០១៩ រៀបរៀងដោយមន្ទីរផែនការខេត្តកណ្ដាល ការគ្រប់គ្រងផ្នែករដ្ឋបាលសង្កាត់ព្រែកឫស្សី មានផ្ទៃដី ២២៦.២០៩ហិកតា ចែកចេញជា៥ភូមិគឺ៖ ភូមិក្រពើហា ភូមិក្រពើហាខាងកើត ភូមិព្រែកឫស្សី ភូមិព្រែកឫស្សីខាងលិច និងភូមិព្រែកអញ្ចាញ មានប្រជាពលរដ្ឋរស់នៅសរុប ២.៣៣៧គ្រួសារ ចំនួនប្រជាពលរដ្ឋសរុប ១១.០១២នាក់ ស្រី ៦.៤៤៥នាក់ ដង់ស៊ីតេប្រជាជន ៤.៣២៣/គម២។

ប្រជាពលរដ្ឋភាគច្រើន ជាអ្នកប្រកបរបរលក់ដូរនៅទីផ្សារក្នុងស្រុកនិងលក់ដូរនៅតាមផ្ទះចំនួន២៧.៤% ជាមន្ត្រីរាជការមួយចំនួន២១.៥% សិប្បកម្ម១.៨%ប្រកបរបរនេសាទចំនួន0.១%កម្មករចំនួន៧.១%កសិករចំនួន៥.៥% ជាបុគ្គលិកឯកជន២៨%និងផ្សេងៗមួយចំនួន៨.៦%ដែលអាចរកចំណូលបាន ជាមធ្យមសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។

ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពបច្ចុប្បន្នរបស់សង្កាត់ព្រែកឫស្សី នៃដំណើរការកសាងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់ ឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងលទ្ធផលនៃការវិភាគពិន្ទុវិស័យ និងស្ថានភាពសង្កាត់ព្រែកឫស្សី ឆ្នាំ២០១៩ ឃើញថា សង្កាត់ព្រែកឫស្សី មានបញ្ហាប្រឈមតាមផ្នែកសំខាន់ៗ ដូចតទៅ៖

### ៣.២.១. ផ្នែកសេដ្ឋកិច្ច

សកម្មភាពចម្បងៗនៅក្នុងសេដ្ឋកិច្ច និងបញ្ហាប្រឈមនានាតាមវិស័យរួមមាន៖

#### ក. ផ្នែកអាជីវកម្ម

ក្នុងវិស័យនេះសង្កាត់ព្រែកឫស្សី មានមូលដ្ឋានផលិតកម្មមួយចំនួនដូចជា សិប្បកម្ម ផលិតគ្រឿងសង្ហារិមពីឈើ សិប្បកម្មផលិតទឹកសុទ្ធ សិប្បកម្មកាត់ដេរ ទំនិញប្រើប្រាស់ គ្រឿងឡិចត្រូនិក សម្ភារសំណង់ អាជីវកម្មខ្នាតតូច ជួសជុលគ្រឿងរថយន្តម៉ូតូ គ្លីនិច និងឱសថស្ថាន បានកំពុងរីកលូតលាស់ និង ផ្ដល់ការងារបន្ថែមទៀតដល់ប្រជាពលរដ្ឋរបស់យើង។ រីឯបញ្ហាប្រឈមគឺ សិប្បកម្មមួយចំនួនមិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ ផលិតផលខ្លះមិនទាន់ធានាលើគុណភាព ខ្លះទៀតមិនទាន់មានច្បាប់អនុញ្ញាតអាជីវកម្ម ដែលតម្រូវឲ

ឱ្យទៅសុំច្បាប់ ឬបន្តច្បាប់អនុញ្ញាតអាជីវកម្មនៅការិយាល័យច្រកចេញចូលតែមួយ ឬស្ថាប័នផ្សេងទៀត សិប្បកម្មខ្លះមាន លក្ខណៈមិនទាន់ត្រឹមត្រូវតាមស្តង់ដារបច្ចេកទេសការដាក់តាំងសម្ភារលក់ដូររបស់ប្រជាពលរដ្ឋ រំលោភមកលើចិញ្ចើមផ្លូវសាធារណៈ។[35]

**ខ. កសិកម្ម និងការប្រើប្រាស់ដីធ្លី**

សង្កាត់ព្រែកឬស្សី មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ដូចជា ទឹកស្ទឹង ព្រែកត្នោត និងប្រព័ន្ធទឹកផ្សេងៗទៀត ប្រជាកសិករប្រមាណ៥.៥% បានប្រកបរបរកសិកម្ម បង្កបង្កើនផលដូចជា ធ្វើស្រែក ដាំដំណាំរយៈពេលវែង ដំណាំរយៈពេលខ្លី ដាំបន្លែ អាជីវកម្មលក់បំណែកកូនពូជរុក្ខជាតិ។ល។ ទន្ទឹមនឹងនោះផងដែលក៏មានបញ្ហាខ្វះខាតបច្ចេកទេសកសិកម្ម ប្រជាកសិករបានលក់ដីស្រែចំការរបស់ខ្លួនដើម្បីផ្លាស់ប្តូរមុខរបរ ខ្វះបច្ចេទេសការប្រើប្រាស់ថ្នាំគីមីលើសកម្រិត ។

សង្កាត់ព្រែកឬស្សី មានផ្ទៃដីសរុប ២២៦.២០៩ហិកតា  បែងចែកចេញជា ៤ផ្នែកគឺៈ ផ្ទៃដីលំនៅដ្ឋានសរុប១២៨,៧១២៧ហាត ផ្ទៃដីស្រែសរុប៤៧,៧១២៨ហិកតាដីចំការ១៧.៥៧៧៣ហិកតានិងផ្ទៃដី ផ្សេងៗសរុប៣២,០២០៦២ហិកតា ។ ផ្ទៃដីទាំងអស់ត្រូវបានចុះបញ្ជីច្បាស់លាស់ និងបានផ្តល់ប័ណ្ណកម្មសិទ្ធិសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ជូនដល់ប្រជាជនប្រើប្រាស់ជាបន្តបន្ទាប់ ។  ដីស្រែចំការមួយចំនួនធំត្រូវបានប្រែក្លាយជាដីលំនៅដ្ឋាន  សហគ្រាស ប្រជាកសិករបានលក់ដីដើម្បីផ្លាស់ប្តូរមុខរបរដែលបណ្តាលឱ្យមុខរបរកសិកម្មថយចុះ។ ការប្រើប្រាស់ដីធ្លីនេះក៏មានបញ្ហាកើតឡើងផងដែរ ដូចជា កសាងសង់សំណង់មិនទាន់មានរបៀបរៀបរយ មានសំណង់បណ្តោះអាសន្ននៅលើដីរដ្ឋដូចជានៅលើប្រឡាយ ចំណីស្ទឹង ព្រែក និងចញ្ចើមផ្លូវ។ល។ ធ្វើឱ្យជួបការលំបាកក្នុងការគ្រប់គ្រង ដើម្បីដោះស្រាយបញ្ហានេះ។

**គ. ផ្នែកឧស្សាហកម្ម**

សង្កាត់ព្រែកឬស្សី មានឧស្សាហកម្ម សិប្បកម្ម រោងចក្រ និងការងារសំណង់សំខាន់ៗ ដូចជារោងចក្រកាត់ដេរ សិប្បកម្មផលិតអំបោះ សិប្បកម្មផលិតគ្រឿងសង្ហារិមពីឈើ ដោយបានផ្តល់ការងារមួយចំនួន ជូនដល់ប្រជាពលរដ្ឋដើម្បីរួមចំណែកដោះស្រាយជីវភាពបានល្អប្រសើរ។ ទន្ទឹមនឹងនោះក៏មានចំណុចអសកម្មដូចជា និយោជក និយោជិតពុំទាន់អនុវត្តត្រឹមត្រូវតាមច្បាប់ការងារ ។

**ឃ. ផ្នែកគមនាគមន៍**

សង្កាត់ព្រែកឬស្សី មានផ្លូវជាតិឆ្លងកាត់១ខ្សែ គឺផ្លូវជាតិលេខ២ផ្លូវខេត្ត និង ផ្លូវលំក្នុងភូមិខ្វាតខ្វែងរួមមានផ្លូវបេតុងអាមេ ផ្លូវក្រាលគ្រួសជាដើម តែសម្រាប់អភិវឌ្ឍ ក្នុងឆ្នាំ២០២០ និងឆ្នាំបន្តទៀត សង្កាត់នឹងប្រែ

[35] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្នាំ របស់សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ២០២២-២០២៧

ក្លាយផ្លូវដីសក្នុងភូមិ ឱ្យទៅជាផ្លូវបេតុងមេទាំងអស់។ ទោះបីមានការខិតខំប្រឹងប្រែងរបស់អាជ្ញាធរ ខេត្ត ក្រុង សង្កាត់ ធ្វើឱ្យមានសក្ដានុពលយ៉ាងខ្លាំងនេះក្ដី ក៏នៅមានបញ្ហាប្រឈមតិចតួចដូចជា ហេដ្ឋារចនាសម្ព័ន្ធ មួយចំនួនមានការដឹកទំនិញលើសកម្រិតទម្ងន់ហាមឃាត់ មានទឹកលិចផ្លូវនៅរដូវវស្សា ប្រព័ន្ធលូរំដោះទឹក ពុំមានគ្រប់គ្រាន់ ប្រព័ន្ធលូ ប្រឡាយខ្លះទៀតមានការខកខានមិនបានស្តា និងខ្លះទៀងតបានត្រូវប្រជាជនចាក់ដីលុបនិងធ្វើលំនៅដ្ឋានពីលើ រីឯផ្លូវលំមួយចំនួនតូចចង្អៀតជួបការលំបាកដល់ការធ្វើចរាចរយានយន្ត។

**ខ. ផ្នែកអគ្គិសនី**

បានតបណ្ដាញដាក់ជូនប្រជាពលរដ្ឋប្រើប្រាស់បានចំនួន១០០%។ ថ្វីបើសង្កាត់ព្រែកឫស្សី មានអគ្គិសនីប្រើប្រាស់គ្រប់ក្រុមគ្រួសារក៏ដោយ ប៉ុន្តែការតបណ្ដាញអគ្គិសនីនៅមានកន្លែងខ្លះខ្វះសណ្ដាប់ធ្នាប់ អាចបង្កហានីភ័យ ហើយនៅតាមដងផ្លូវសំខាន់ៗមួយចំនួន មានការខ្វះខាតភ្លើងបំភ្លឺផ្លូវសាធារណៈ ដែលត្រូវឱ្យមានការខិតខំជម្រុញការតបណ្ដាញអគ្គិសនី និងបន្ថែមភ្លើងបំភ្លឺបន្ថែមទៀតរីឯ (ទឹកលិចតិច ខ្សោយ) បញ្ហាទឹកស្អាត កន្លែងខ្លះមានការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការទាន់ពេលវេលា។ ផ្នែកការវិនិយោគ សង្កាត់ព្រែកឫស្សី មានការចូលរួមវិនិយោគជាច្រើនពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងវិស័យឯកជន ជាក់ស្ដែងដូចជា រោងចក្រកាត់ដេរ សំណង់ផ្ទះល្វែង ផ្លូវ ស្ពាន ពិសេស ផ្លូវជាតិលេខ២ (វីឯមហាវិថីរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា (ផ្លូវ៦០ម៉ែត្រ) ក៏បានបើកឱ្យដំណើរការប្រើប្រាស់ និងឆ្លោះមកឆ្លងកាត់ភូមិសាស្ត្រសង្កាត់ព្រែកឫស្សីផងដែរ។ ទោះបីមានការចូលរួមអភិវឌ្ឍយ៉ាងនេះក្ដី ក៏នៅមានបញ្ហាខ្វះចន្លោះដូចជា ការសង់សំណង់មួយចំនួន ពុំបានសុំច្បាប់អនុញ្ញាតពីអាជ្ញាធរ ការចតយានជំនិះមកលើផ្លូវសាធារណៈ ពុំមានសណ្ដាប់ធ្នាប់ ការដាក់តាំងសម្ភារៈ លក់ដូរហៀរមកលើចិញ្ចើមផ្លូវសាធារណៈ ។

**៣.២.២.ផ្នែកសង្គមកិច្ច**

**ក. ផ្នែកអប់រំ**

ក្នុងវិស័យនេះ សង្កាត់ព្រែកឫស្សី មានសាលាមត្តេយ្យឯកជន សាលាបឋមសិក្សា អនុវិទ្យាល័យឯកជន សាលាបណ្តុះបណ្ដាលភាសាបរទេសឯកជន កុមារអាយុ ៦ឆ្នាំ បានចូលរៀន ១០០%។ ទន្ទឹមនឹងសក្ដានុពលនេះ ការសិក្សារបស់កុមារក៏ពុំទទួលបានចំណេះដឹងស្មើគ្នាដែរ ។[36]

**ខ. ផ្នែកសុខាភិបាល**

ភូមិសាស្ត្រសង្កាត់ព្រែកឫស្សី ស្ថិតនៅក្នុងទីប្រជុំជនរបស់ក្រុងតាខ្មៅ ខេត្តកណ្ដាល ងាយស្រួលដល់ការទៅរកសេវាព្យាបាលផ្សេងៗ បានទាន់ពេលវេលា។ ស្ត្រីបានសម្រាលកូន ដោយពេទ្យឆ្មបប្រកបដោយ

[36] សម្ភាសជាមួយ លោក ឆេង ឆៃ ជាចៅសង្កាត់ ព្រែកឫស្សី នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២:00 នាទី

សុខវត្ថិភាព ចាក់វ៉ាក់សាំងបង្ការជំងឺ១១មុខ ដល់កុមារអាយុចាប់ពី ៩-១២ខែ បានគ្រប់ចំនួន ស្មើនឹង ១០០%។ ទន្ទឹមនឹងសក្តានុពលខាងលើនេះ យើងពិនិត្យឃើញមានគ្រួសារមានសមាជិកកើតជំងឺអេដស៍មានចំនួន២៤នាក់ នៃប្រជាជនសរុប។ បញ្ហាដែលកើតមានខាងលើនេះ ។

**គ. សមភាពយេនឌ័រ**

ក្នុងវិស័យសេដ្ឋកិច្ច ស្ត្រីចំនួន ៤៥%មានមុខរបរចម្បងក្នុងផលិតកម្ម និងសេវាកម្ម ភាគរយស្ត្រីចេះអក្សរអាយុចាប់ពី ១៨-៤៥ឆ្នាំមានចំនួន១០០%បានចូលរួមធ្វើការសម្រេចចិត្តដូចបុរសនៅគ្រប់កិច្ចការសង្គម បានចូលរួមបម្រើការងារតាមមន្ទីរ អង្គភាព ក្រុមប្រឹក្សាក្រុង និងថ្នាក់ដឹកនាំភូមិ ក្នុងនោះស្ត្រី៣៣% បានធ្វើការនៅក្នុងក្រុមប្រឹក្សាសង្កាត់។ ទន្ទឹមនឹងចំណុចសកម្មខាងលើនេះ ស្ថានភាពយេនឌ័រមានបញ្ហាប្រឈមមួយចំនួនដូចជា នៅមានគ្រួសារខ្លះប្រើអំពើហិង្សា ស្ត្រីប្រមាណ១%ធ្វើការ ចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ។

**ឃ. អន្តោប្រវេសន៍និងការផ្លាស់លំនៅ**

ដោយសង្កាត់ព្រែកឫស្សី ស្ថិតនៅជិតបង្គើយក្នុងក្រុងតាខ្មៅ និងក្រុងតាខ្មៅជាមជ្ឈមណ្ឌលសេដ្ឋកិច្ច ពាណិជ្ជកម្ម និងរដ្ឋបាលរបស់ខេត្តកណ្តាល ហើយមានភូមិសាស្ត្រជាប់រាជធានីភ្នំពេញ មានរោងចក្រ សហគ្រាសខ្នាតតូច ធំៗ ជាច្រើន អាចផ្តល់ការងារច្រើនប្រភេទដល់ប្រជាពលរដ្ឋ កម្មករ ជាកត្តានាំឱ្យមានការបំលាស់ទីមកពីខេត្តផ្សេងទៀតៗ មកស្នាក់នៅដើម្បីប្រកបមុខរបររបស់ខ្លួន។ ទោះជាមានសក្តានុពលដូចខាងលើក្តី ក៏ប្រជាពលរដ្ឋក្នុងសង្កាត់ នៅមានការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ។

**ង. ធនធានធម្មជាតិ**

សង្កាត់ព្រែកឫស្សី មានស្ទឹង ព្រែក ជាកន្លែងផ្តល់នូវផលប្រយោជន៍សម្រាប់ប្រកបមុខរបរធ្វើកសិកម្ម និងដាំដំណាំផ្សេងៗ។ ប្រជាកសិករប្រមាណ៥,៥% ប្រកបរបរលើវិស័យកសិកម្ម និងប្រកបរបរផ្សេងៗទៀតសម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ ទន្ទឹមនឹងនោះ ក៏មានបញ្ហាប្រឈមដែលកើតមានឡើងដូចជា ទឹកស្ទឹងមានច្រើនតែរដូវវស្សាខ្វះខាតក្នុងរដូវប្រាំង ទឹកស្ទឹងមានភាពកខ្វក់ដោយមានការហូរចូលទឹកសំអុយពីរាជធានីភ្នំពេញ ប្រជាពលរដ្ឋមិនអាចយកទឹកនេះមកប្រើប្រាស់បាន ម្យ៉ាងទៀត ប្រជាពលរដ្ឋមួយចំនួនខ្វះការយល់ដឹងពីការគ្រប់គ្រងការថែរក្សាធនធានធម្មជាតិ មានការបោះសំរាមនិងបង្ហូរកាកសំណល់ផ្សេងៗចូលក្នុង ស្ទឹង ព្រែក ។

**ច. ផ្នែកបរិស្ថាន**

ចំនួនគ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះ សរុបចំនួន ១២០៨គ្រួសារ ស្មើនឹង ៥៣,៦៤%មួយចំនួនទៀតមិនទាន់មានការយល់ដឹងពីការគ្រប់គ្រងកាកសំណល់ឱ្យបានត្រឹមត្រូវនាំឱ្យមានផលប៉ះពាល់បរិស្ថាន

យ៉ាងធូន់ធ្ងរ ម្យ៉ាងទៀត សេវាប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ិនទ្រី មិនទាន់បានពង្រីកការប្រមូលនៅតាមខ្នងផ្ទះប្រជាពលរដ្ឋគ្រប់ចំនួននៅឡើយ។

### ៣.២.៣. អភិបាលកិច្ច

ការដឹកនាំគ្រប់គ្រងរបស់អាជ្ញាធរសង្កាត់ បានបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋ អនុវត្តបានល្អទៅតាមគោលការណ៍នៃអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងការផ្តល់សេវារដ្ឋបាលលើផ្នែកអត្រានុកូលដ្ឋានមួយចំនួនជូនប្រជាពលរដ្ឋ មិនតម្រូវឱ្យគិតកម្រៃសេវាឡើយ ដូចជា អត្រានុកូលដ្ឋានកំណើតអាពាហ៍ពិពាហ៍ មរណភាព ការធ្វើនិងផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅនិងសេវារដ្ឋបាលមួយចំនួនទៀតមានការកំណត់លើតារាងសេវាតម្លៃ

រដ្ឋបាលច្បាស់លាស់ ដែលតម្រូវឱ្យអ្នកស្នើសុំទៅធ្វើនៅការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ។ ទន្ទឹមនឹងនេះ ក៏នៅមានបញ្ហាលំបាកខ្លះក្នុងការគ្រប់គ្រងផ្នែកស្ថិតិនេះដែរ ដោយម្ចាស់អាជីវកម្ម សេវាកម្មខ្លះមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់នៅឡើយ ដូចនេះ ត្រូវបន្តផ្សព្វផ្សាយព័ត៌មានអំពីសេវារដ្ឋបាលផ្សេងៗដែលលើសពីសមត្ថកិច្ចរបស់សង្កាត់ ឱ្យទៅសុំនៅការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅដើម្បីចូលរួមអនុវត្តច្បាប់ទាំងអស់គ្នា។

កាមេរ៉ាសុវត្ថិភាពនៅទីតាំងស្តុបផ្លូវសំខាន់ៗ ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ ច្បាប់គ្រឿងញៀន មានវិធានការអប់រំ ផាកពិន័យដល់អ្នកប្រព្រឹត្តល្មើសច្បាប់ជាដើម។ល។

### ៣.២.៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ក្រោមការដឹកនាំប្រកបដោយប្រាជ្ញាឈ្លាសវៃ និងកត្តិបណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំ ណែនាំដោយផ្ទាល់របស់ ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល ថ្នាក់ដឹកនាំខេត្ត មន្ទីរអង្គភាពនានាជុំវិញខេត្ត និង គណៈអភិបាលក្រុងតាខ្មៅ ធ្វើឱ្យសង្កាត់ព្រែកឫស្សី មានការរីកចម្រើនទៅមុខជាលំដាប់ ដោយបានបម្រើផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋឥតឈប់ឈរពីមួយអាណត្តិទៅមួយអាណត្តិ រាល់ការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលសង្កាត់។គឺមានការចូលរួមពីប្រជាពលរដ្ឋ គោរពតាមច្បាប់របស់រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីណែនាំផ្សេងៗទៀត ប្រកបដោយតម្លាភាព មានការព្រមព្រៀងឯកភាពគ្នា មានសមធម៌ មានគណនេយ្យភាព និងមានការឆ្លើយតបតាមតម្រូវការមូលដ្ឋានបានទាន់ពេលវេលា ក្នុងនោះរដ្ឋបាលសង្កាត់ព្រែកឫស្សី មានការគ្រប់គ្រងដូចខាងក្រោម៖

## ៣.៣.ដំណោះស្រាយ

### ៣.៣.១.ពង្រឹងផ្នែកសេដ្ឋកិច្ច

### ក. ពង្រឹងផ្នែករបរជីវកម្ម

ដោយសារអាជីវករនៅមានកម្រិត មិនមានជំនាញប្រកបមុខរបរច្បាស់លាស់ទើបធ្វើឱ្យទទួលបានចំណូល តិច។ ដូច្នេះខាងសង្កាត់ត្រូវរៀបចំ វគ្គបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈមុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយនូវបញ្ហាដូចជាភាពក្រីក្រ ដែលកំពុងតែកើតឡើងប្រកបដោយប្រសិទ្ធភាពខ្ពស់ តម្រូវឱ្យមានការត្រួតពិនិត្យផ្សព្វផ្សាយច្បាប់ ឬបណ្តុះបណ្តាលបច្ចេកទេសថ្មីៗ។

### ខ. ការពង្រឹងវិស័យកសិកម្ម និងដីធ្លី

ដោយសង្កាត់ព្រែកឫស្សី ជាសង្កាត់ដែលពឹងផ្អែកលើវិស័យកសិកម្ម ដូច្នេះបញ្ហាដីធ្លីគឺជាបញ្ហាចំបងមួយដែល សំខាន់សម្រាប់រដ្ឋបាលសង្កាត់យកចិត្តទុកដាក់ក្នុងការដោះស្រាយ ហើយដើម្បីដោះស្រាយនៅរាល់បញ្ហា ដែលបាន កើតមានដោយអាជ្ញាធរសង្កាត់ទទួលបានជំនួយពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំបណ្តុះបណ្តាល លើបច្ចេកទេសដាំដុះស្រូវវស្សា ព្រមទាំងវិធានការការពារការបំផ្លាញពីសត្វល្អិត រួមទាំងការជ្រើសរើសពូជស្រូវ ពូជដំណាំផ្សេងៗដល់ប្រជាកសិករ។ ដោយឡែក សម្រាប់ប្រព័ន្ធធារាសាស្ត្រ អាជ្ញាធរសង្កាត់ក៏បានខិតខំស្វែងរកប្រភពធនធានពីបណ្តាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងប្រភពពីថ្នាក់ជាតិបន្ថែម តាមរយៈការជួបប្រជុំ លើកសំណូមពរពីតម្រូវការរបស់សង្កាត់ព្រែកឫស្សីនៅថ្នាក់ក្រុង និងថ្នាក់ខេត្ត ដើម្បីធ្វើការសាងសង់ប្រព័ន្ធស្រោចស្រពសម្រាប់បម្រើដល់វិស័យកសិកម្មរបស់សង្កាត់ឱ្យមានការរីកចម្រើនកាន់តែខ្លាំង។ ចំពោះបញ្ហាទាក់ទងដីធ្លីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់តាមរយៈមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីខេត្តកណ្តាលនិងការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់និងបានដោះស្រាយបញ្ហាដីធ្លីដែលកើតមាននៅក្នុងសង្កាត់ព្រែកឫស្សី ដើម្បីបញ្ចៀសជម្លោះដីធ្លី។ ត្រូវយកចិត្តទុកដាក់ មានវិធានណែនាំដល់ប្រជាពលរដ្ឋ មកសុំច្បាប់សាងសង់នៅការិយាល័យច្រកចេញចូលតែមួយក្រុង តាខ្មៅ និងផ្សព្វផ្សាយច្បាប់ភូមិបាល។ ទាមទារឲ្យធ្វើការបើវគ្គបណ្តុះបណ្តាលបច្ចេកទេសដាំដុះ បច្ចេកទេសការចិញ្ចឹមសត្វ និងពង្រឹងសមត្ថភាពប្រជាពលរដ្ឋ។

### គ. ការព្រឹងឧស្សាហ៍កម្ម និងសិប្បកម្ម

ដើម្បីដោះស្រាយនូវបញ្ហាទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ កសាង ពង្រីកផ្លូវ ចាក់បេតុង កៅស៊ូ ឱ្យបានសមរម្យ ដើម្បីមាននិរន្តភាពចរាចរណ៍ ស្តារប្រព័ន្ធលូ ដើម្បីធានារំដោះទឹកចេញនៅរដូវភ្លៀងធ្លាក់ទាន់ពេលវេលា។ និងដើម្បីអភិវឌ្ឍវិស័យនេះឱ្យកាន់រីកចម្រើនជាងមុន នោះចៅសង្កាត់ព្រែកឫស្សីត្រូវមានការរៀបចំដូចជា ការពន្យល់ប្រជាពលរដ្ឋឱ្យបានច្រើនទាក់ទងនិងច្បាប់ស្តីពី ការគ្រប់គ្រងឧស្សាហកម្ម និងសិប្បកម្ម

ហើយគ្រប់ប្រជាពលរដ្ឋទាំងអស់មុននិងបើកធ្វើឧស្សាហ៍កម្ម ឬសិប្បកម្ម អ្វីមួយត្រូវមានសមត្ថភាព ជំនាញច្បាស់លាស់ មានសម្ភារៈបច្ចេកទេសគ្រប់គ្រាន់ និងត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចរបស់ សង្កាត់ ។ បន្ថែមជាងនេះសង្កាត់ត្រូវធ្វើការឱ្យសកម្មពាក់ព័ន្ធការចុះទៅពន្យល់អប់រំ ផ្សព្វផ្សាយច្បាប់សំខាន់ៗដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននោះដើម្បីឱ្យពួកគាត់កាន់តែមានយល់ដឹងខ្ពស់ និងអនុវត្តទៅបានជោគជ័យ។

**ឃ. គែលម្ពប្រព័ន្ធទូរគមនាគមន៍**

ដោយមានការមើលឃើញថា ប្រព័ន្ធទូរគមនាគមន៍នៅតែជាកត្តាមួយដ៏សំខាន់បំផុតសម្រាប់ជាផ្លូវដែល ឱ្យប្រជាពលរដ្ឋធ្វើដំណើរដើម្បីឱ្យប្រកបដោយសុវត្ថិភាព។ ក្នុងផ្នែកការវិនិយោគ សង្កាត់ព្រែកប្ញស្សីមានការចូលរួមវិនិយោគជាច្រើនពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងវិស័យឯកជន ជាក់ស្តែងដូចជារោងចក្រកាត់ដេរ សំណង់ផ្ទះល្វែង ផ្លូវ ស្ពាន ពិសេស ផ្លូវជាតិលេខ២ (វិថីមហាវិថីរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា (ផ្លូវ៦០ម៉ែត្រ) ក៏បានបើកឱ្យដំណើរការប្រើប្រាស់ និងឆ្លោះមកឆ្លងកាត់ភូមិសាស្ត្រសង្កាត់ព្រែកប្ញស្សីផងដែរ។

**ខ. ពន្លឺអគ្គិសនី**

សង្កាត់ព្រែកប្ញស្សីបានយកចិត្តទុកដាក់ផ្សព្វផ្សាយអំពីសេវារដ្ឋបាល ពាក់ព័ន្ធនឹងការអនុញ្ញាតច្បាប់សាងសង់សំណង់ផ្សេងៗ របស់ការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ និងរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានជាប្រចាំ។ ដែលត្រូវឲ្យមានការខិតខំជម្រុញការតបណ្តាញអគ្គិសនី និងបន្ថែមភ្លើងបំភ្លឺ បន្ថែមទៀតរីឯ (ទឹកលិចតិច ខ្សោយ) បញ្ហាទឹកស្អាត កន្លែងខ្លះមានការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការទាន់ពេលវេលា។

**៣.៣.២.សង្គមកិច្ច**

**ក. ការលើកកម្ពស់គុណភាពអប់រំ**

ដើម្បីជម្រុញឱ្យការអប់រំនៅក្នុងសង្កាត់ព្រែកប្ញស្សីមានប្រសិទ្ធភាព និងឆ្លើយតបបានទៅនឹងតម្រូវការរបស់ សិស្ស និងគ្រូបង្រៀន រដ្ឋបាលថ្នាក់ជាតិដែលមានក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមន្ទីរចំណុះរបស់ខ្លួន នៅខេត្តកណ្តាល និងការិយាល័យអប់រំ យុវជន និងកីឡាក្រុងតាខ្មៅ គប្បីពិនិត្យលទ្ធភាពផ្តល់ថវិកា ឬស្វែងរក ជំនួយ ដើម្បីកសាងវិទ្យាល័យមួយមាននៅក្នុងសង្កាត់ព្រែកប្ញស្សីសិស្សានុសិស្ស និងគ្រូបង្រៀនងាយស្រួលធ្វើ ដំណើរទៅសាលារៀន និងកាត់បន្ថយពេលពេលវេលាក្នុងការធ្វើដំណើរ។ បន្ថែមពីនេះ ការលើកទឹកចិត្តគ្រូ បង្រៀន តាមរយៈការបង្កើនប្រាក់បៀវត្សរ៍ ប្រាក់លើកទឹកចិត្ត ឬប្រាក់ឧបត្ថម្ភផ្សេងៗដែលជាកត្តាមួយជម្រុញឱ្យគ្រូ មានកម្លាំងចិត្ត និងកម្លាំងកាយក្នុងការផ្តល់ចំណេះដឹងដល់សិស្សគ្រប់រូបនៅក្នុងសង្កាត់ព្រែកប្ញស្សីនេះផងដែរ។ លើស ពីនេះសង្កាត់

ព្រៃកប្បស្សី បានសហការជាមួយស្ថាប័នពាក់ព័ន្ធបង្កើតមត្តេយ្យសហគមន៍ និងមត្តេយ្យរដ្ឋនៅតាមភូមិ នានាដែលចំណុះសង្កាត់ព្រៃកប្បស្សីជាពិសេស រដ្ឋបាលសង្កាត់ព្រៃកប្បស្សី ក៏បានចូលរួមកាត់បន្ថយចំណាយរបស់សិស្ស ដែលក្រីក្រ តាមរយៈការផ្ដល់អាហាររូបករណ៍ (ថ្នាក់បឋម និងមធ្យមសិក្សា) ពង្រឹង និងកំណត់មុខសញ្ញាឱ្យបាន ល្អជាងមុនសម្រាប់កម្មវិធីផ្ដល់អាហារពេលព្រឹកនៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តដល់សិស្សថ្នាក់ទី ០៧ ដល់ទី ០៩ ។ កាត់បន្ថយអក្ខរជនឱ្យនៅកម្រិតទាបបំផុត និងឈានទៅបំបាត់នាពេលខាងមុខ តាមរយៈការធ្វើ កិច្ចសហការជាមួយការិយាល័យអប់រំសង្កាត់ព្រៃកប្បស្សី មន្ទីរអប់រំខេត្តកណ្ដាល និងដៃគូពាក់ព័ន្ធនានា ក្នុងការបង្កើត ថ្នាក់អក្ខរកម្ម ពីព្រោះភាពអវិជ្ជមាននៃប្រជាជនជាឧបសគ្គសម្រាប់ការអភិវឌ្ឍជីវភាពគ្រួសារ និងសង្គមជាតិ។

**ខ. ការថែទាំសេវាសុខាភិបាល**

ចំពោះការលើកកម្ពស់សេវាសុខាភិបាលនៅសង្កាត់ព្រៃកប្បស្សី ត្រូវចាប់ផ្ដើមពីការជួយផ្គត់ផ្គង់សម្ភារៈ និងថ្នាំ ពេទ្យឱ្យបានគ្រប់គ្រាន់ដល់មណ្ឌលសុខភាពពីសំណាក់របស់មន្ទីរសុខាភិបាល និងណែនាំដល់ប្រជាពលរដ្ឋ ឱ្យកែប្រែទម្លាប់សម្រាលកូនដោយឆ្មប ឱ្យមកប្រើសេវាពេទ្យឆ្មបដែលធានាសុវត្ថិភាពជាមួយបុគ្គលិកក្រសួងសុខាភិបាល ដែលមានជំនាញច្បាស់លាស់ រួមទាំងការចាក់វ៉ាក់សាំងដល់កុមារគ្រប់រូបដែលរស់នៅក្នុងមូលដ្ឋាន។ ដោយ ឡែកបញ្ហាទាក់ទងជាមួយប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ កុមារកំព្រាក្រោមអាយុ ១៨ឆ្នាំ ជនពិការ សង្កាត់ មានគោលដៅសហការជាមួយអង្គការ ស្ថាប័ន ដែលពាក់ព័ន្ធឱ្យជួយស្ដារលទ្ធភាពរាងកាយជនពិការ ហើយនិងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ កម្មវិធីអាហារូបត្ថម្ភ អប់រំសុខភាពបន្តពូជ សុខភាពមាតា និងកុមារ លុបបំបាត់មូលហេតុដែល ណ្ដាលឱ្យមានជំងឺ ចាត់វិធានបង្ការ និងផ្ដល់ការព្យាបាលដែលចាំបាច់ដល់ប្រជាពលរដ្ឋ។ ប្រការមួយទៀតនោះ គឺ ការសម្អាតបរិស្ថាន ដោយអាជ្ញាធរសង្កាត់គួរតែខិតខំបន្តបើកវគ្គបណ្ដុះបណ្ដាលបន្ថែមដល់ប្រជាពលរដ្ឋឱ្យយល់ ដឹងពីការរក្សាអនាម័យក្នុងការរស់នៅ ក្រោមពាក្យស្លោក ហូបស្អាត ផឹកស្អាត រស់នៅស្អាត ព្រមទាំងការទុកដាក់ សំណល់ផ្សេងឱ្យមានរបៀបរៀបរយ និង វិធីបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ដើម្បីសុខុមាលភាពប្រជាពលរដ្ឋ ទាំងមូល ពិសេសកុមារ និងចាស់ជរា។ ត្រូវបន្តយកចិត្តទុកដាក់បង្កើនការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងពីសុខភាពទូទៅ ជំងឺឆ្លង និងមិនឆ្លងនានាដែលកើតមានឡើងជាយថាហេតុ ដើម្បីរកសេវាព្យាបាលឱ្យបានទាន់ពេលវេលា។

**គ. សមភាពយេនឌ័រ**

សង្កាត់ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ច្បាប់ជួញដូរស្ត្រីនិងកុមារ ពង្រឹងការយល់ដឹងពីសិទ្ធិកុមារ បញ្ជ្រាបយេនឌ័រក្នុងផែនការសង្កាត់ និងអប់រំដល់ស្ត្រីអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ហើយសង្កាត់ត្រូវមានការជម្រុញគាំទ្រដូចជា៖

- អប់រំផ្សព្វផ្សាយពីសិទ្ធិតួនាទី បុរសនិងស្ត្រី
- ជម្រុញលើកទឹកចិត្តស្ត្រីចូលរួមក្នុងការអភិវឌ្ឍ
- ផ្សព្វផ្សាយច្បាប់អំពើហឹង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរ រំលោភបំពានផ្លូវភេទទៅលើស្ត្រី និងកុមារ
- ផ្សព្វផ្សាយតួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍ
- ផ្សព្វផ្សាយយេនឌ័រ និងសិទ្ធិកុមារ។

**ឃ. អន្តោប្រវេសន៍និងការផ្លាស់ប្តូរលំនៅ**

ដូចនេះត្រូវយកចិត្តទុកដាក់អប់រំផ្សព្វផ្សាយការចំណាកស្រុកប្រកបដោយសុវត្ថិភាព មានវិធានការគ្រប់គ្រង ត្រួតពិនិត្យអ្នកស្នាក់នៅតាមផ្ទះជួល ឬអ្នកស្នាក់នៅផ្សេងៗទៀតឱ្យបានច្បាស់លាស់ ដើម្បីធានាបាននូវការអនុវត្តគោលនយោបាយ ភូមិ សង្កាត់ មានសុវត្ថិភាពល្អ។

**ង. ធនធានធម្មជាតិ**

សង្កាត់ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ ចាត់វិធានការការពារនិងត្រៀមលក្ខណៈសម្បត្តិដើម្បីឆ្លើយតប ដោះស្រាយបន្ទាន់ចំពោះផលប៉ះពាល់ ដែលបង្កឡើងជាយថាហេតុដោយគ្រោះមហន្តរាយ។ សង្កាត់បានយកចិត្តទុកដាក់ធ្វើរបាំងការពារច្រាំងស្ទឹងត្រង់ចំណុចទឹកហូរបុក និងផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងដីរដ្ឋ វិធានការការពារផ្សេងៗ ដល់ប្រជាពលរដ្ឋដែលស្នាក់នៅតាមតំបន់ងាយរងគ្រោះដើម្បីចៀសវាងគ្រោះថ្នាក់កើតឡើងជាយថាហេតុ និងអប់រំបញ្ហាសុខភាពដល់ប្រជាពលរដ្ឋនៅពេលមានបញ្ហាអាកាសធាតុប្រែប្រួលនានា។

**ច. ផ្នែកបរិស្ថាន**

សង្កាត់បាន យកចិត្តទុកដាក់បង្កើនរថយន្តដឹកសំរាម ទំនាក់ទំនងរកដៃគូកែច្នៃសំណល់ប្រើប្រាស់ឡើងវិញ បន្ថែមការដាក់ស្លាកសញ្ញាហាមឃាត់ការចាក់សំរាម បន្តអប់រំផ្សព្វផ្សាយច្បាប់បរិស្ថានដល់ប្រជាពលរដ្ឋក្នុងសង្កាត់ឱ្យបានយល់ដឹងគ្រប់ៗគ្នា និងអនុវត្តនូវវិធានការណ៍រដ្ឋបាលផាកពិន័យតាមច្បាប់កំណត់ និងត្រូវធ្វើការអប់រំផ្សព្វផ្សាយពីច្បាប់បរិស្ថាន។

**៣.៣.៣.ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ**

ជាការឆ្លើយតប ចំពោះកង្វះខាតក្នុងការបំពេញការងាររដ្ឋបាលរបស់សាលាសង្កាត់ព្រែកឬស្សី ក្រសួងមហាផ្ទៃបានរៀបចំជារឿយៗនូវកម្មវិធីបណ្តុះបណ្តាលមេឃុំ ក្រុមប្រឹក្សាសង្កាត់ និងស្មៀនសង្កាត់ ពាក់ព័ន្ធនឹងការងារ រៀបចំផែនការវិនិយោគ និងផែនការថវិការបស់សង្កាត់ជាដើម។ មួយវិញទៀត ក្រសួងមហាផ្ទៃក៏បានយកចិត្តទុកដាក់ បន្ថែមលើការបណ្តុះបណ្តាល ស្មៀនសង្កាត់ ដើម្បីឱ្យក្លាយទៅជាធនធានមនុស្ស

ដ៏សំខាន់ សម្រាប់ទទួលបន្ទុក សម្រួលការងាររដ្ឋបាលសង្កាត់ឱ្យមានដំណើរការរលូនស្របតាមគោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្ត។ ក្រៅពីនេះមានការកសាងផ្លូវថ្នល់ គឺកំពុងដំណើរការសាងសង់នូវឡើយ ដែលឧបត្ថម្ភដោយ ក្រសួងមហាផ្ទៃផងដែរ។ រដ្ឋបាលសង្កាត់ព្រែកឫស្សី ក៏បានផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន ការធ្វើសៀវភៅគ្រួសារ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់ព្រែកឫស្សី ដើម្បីលើកកម្ពស់ការយល់ដឹង អំពីការបម្រើសាធារណៈរបស់រដ្ឋបាលសង្កាត់ សំដៅបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ។

### ៣.៣.៤. ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ផ្អែកតាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សង្គម រដ្ឋបាលសង្កាត់ព្រែកឫស្សី បានអនុវត្តតាមសេចក្តីណែនាំលេខ ០២០ របស់ក្រសួងមហាផ្ទៃស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ដោយអនុវត្តជាប្រចាំ។ សកម្មភាពទាំងនេះ មានការគាំទ្រពីក្រសួងមហាផ្ទៃ ស្នងការនគរបាលខេត្តកណ្តាល អធិការដ្ឋាននរគបាលក្រុងតាខ្មៅ ប៉ុស្តិ៍នរគបាលរដ្ឋបាលសង្កាត់ គណៈបញ្ជាការឯកភាពសង្កាត់ព្រែកឫស្សី ហើយបានផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីច្បាប់របស់រដ្ឋ និងគោលនយោបាយ គឺធ្វើយ៉ាងណាជម្រុញឱ្យសង្កាត់ព្រែកឫស្សី ភូមិចំណុះក្លាយជាមូលដ្ឋានដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឃុំ សង្កាត់ ជានីតិបុគ្គលសាធារណៈ។ កាលណានិយាយអំពីរដ្ឋបាលឃុំ សង្កាត់ គឺសំដៅដល់ក្រុម ប្រឹក្សាឃុំ សង្កាត់។ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមនយោបាយ បែបវិមជ្ឈការ ដូច្នេះប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់។ អំណាចដឹកនាំ និងគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់បានមកពីការបោះឆ្នោតជាសកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។ រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីកំណែទម្រង់រដ្ឋបាលតាមនយោបាយវិមជ្ឈការឃុំ សង្កាត់ ជាការលើកកម្ពស់សមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់សម្រាប់តម្រូវការជាមូលដ្ឋានជូនប្រជាពលរដ្ឋ។ ចំពោះវិមជ្ឈការនៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ជាកត្តាចម្បងដែលមិនអាចមានការធ្វេសប្រហែសបានឡើយ ហើយត្រូវតែយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមបច្ចេកទេសនៃប្រព័ន្ធវិមជ្ឈការ ស្របនឹងទីកន្លែង ពេលវេលា និង តម្រូវការជាក់ស្តែង។ ជាពិសេសគោលនយោបាយនេះ បានកាត់បន្ថយការិយាធិបតេយ្យ និងបានធ្វើការបង្កិត សេវាឱ្យកាន់តែជិតប្រជាពលរដ្ឋ ដើម្បីចំណេញពេលវេលា សន្សំប្រាក់កាក់ និងកាត់បន្ថយភាពក្រីក្រ។ សិទ្ធិអំណាចមូលដ្ឋានដែលត្រូវបានទទួលយកដោយក្រុមតំណាងរបស់ប្រជាពលរដ្ឋមូលដ្ឋាន ហៅថា ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដោយក្រុមប្រឹក្សានេះធ្វើសកម្មភាពដើម្បី ប្រយោជន៍ទូទៅ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងកិច្ចអភិវឌ្ឍដែលរាស្ត្របានបោះឆ្នោតជាតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន និងមាន បេសកកម្មបម្រើផលប្រយោជន៍ទូទៅរបស់ឃុំ សង្កាត់សាមី។ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមួយអាណត្តិមានរយៈ ពេល ០៥ឆ្នាំ ដែលមានប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ និងប្រព័ន្ធវិសហមជ្ឈការ។

ជាក់ស្តែងសង្កាត់ព្រែកឬស្សីជានីតិបុគ្គលសាធារណៈដែលមានតួនាទីសំខាន់ៗគឺ បម្រើកិច្ចការមូលដ្ឋាន សម្រាប់ផលប្រយោជន៍ទូទៅរបស់សង្កាត់ និងជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់ អាជ្ញាធររដ្ឋ។ រដ្ឋបាលសង្កាត់ព្រែកឬស្សី ត្រូវបានដឹកនាំ គ្រប់គ្រងកិច្ចការងាររដ្ឋបាលដោយក្រុមប្រឹក្សាឃុំចំនួន ០៧ រូប ដែលមាន ០១ រូប ជាប្រធានក្រុមប្រឹក្សា ០២ រូបជាជាចៅសង្កាត់រង និង ០៤ រូបផ្សេងទៀតជាសមាជិកក្រុមប្រឹក្សាក្នុង អាណត្តិទី៤ របស់សង្កាត់ព្រែកឬស្សី។ ក្រុមប្រឹក្សាសង្កាត់គ្រប់រូប បានខិតខំបំពេញការងារជូនរដ្ឋបាលសង្កាត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាធរមាន។

រដ្ឋបាលសង្កាត់តែងតែគិតគូពីសុខទុក្ខរបស់ប្រជាពលរដ្ឋ ដោយមានកិច្ចប្រជុំរបស់ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីលើកឡើងនូវផែនការ និងរិះរកឱ្យឃើញពីបញ្ហា មូលហេតុនៃបញ្ហា តម្រូវការចាំបាច់យក

មកដោះស្រាយ។ ការដោះស្រាយបញ្ហាទាំងនោះ ដោះស្រាយនូវបញ្ហាតម្រូវការអាទិភាព និងបញ្ហាបន្ទាប់បន្សំ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងសេចក្តីសន្និដ្ឋានខាងលើ យើងខ្ញុំបាទ សូមចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ពិសេសអាជ្ញាធរ សង្កាត់ព្រែកឫស្សីផ្ទាល់ ក្នុងការថែរក្សា ការពារនូវបូរណភាពទឹកដី ការគ្រប់គ្រងរដ្ឋបាលដែនដី ជាពិសេសដើម្បីពង្រឹង លើការអនុវត្តនូវគោលនយោបាយវិមជ្ឈការនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- អាជ្ញាធរសង្កាត់គួរសាងសង់មណ្ឌលសុខភាពក្នុងសង្កាត់ ដើម្បីឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការព្យាបាលជំងឺដោយមិនចាំបាច់ទៅព្យាបាលនៅមណ្ឌលសុខភាពដែលស្ថិតក្នុងទីកន្លែងផ្សេងៗ។ អាជ្ញាធរសង្កាត់គួរពង្រឹងសមត្ថភាព និងភាពច្នៃប្រឌិតក្នុងការងារ ពិសេសពង្រឹងសមត្ថភាពការធ្វើការងារ ជាក្រុមបច្ចេកទេសកុំព្យូទ័រ ភាសារជាតិ បរទេស និងបណ្តាញអ៊ីនធ័រណែត។
- អាជ្ញាធរសង្កាត់គួរបង្កើនការលើកកម្ពស់សោភ័ណភាពតំបន់រមណីយដ្ឋានក្បែរជើងភ្នំ ដែលមាននៅក្នុងសង្កាត់ ឱ្យមានសក្តានុពលទេសចរណ៍ ពិសេសតំបន់រមណីយដ្ឋានធម្មជាតិ និងវប្បធម៌។
- ចំពោះផលដំណាំ ម្ហូបអាហារ អាជ្ញាធរសង្កាត់គួរតែមានវិធានការអប់រំប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយ ឬមិនត្រូវប្រើប្រាស់សារធាតុគីមីដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាព។
- សូមអាជ្ញាធរសង្កាត់ បើកវេទិកាសាធារណៈឱ្យបានញឹកញាប់ ដើម្បីទទួលបាននូវរាល់បញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសង្កាត់ រួចរកដំណោះស្រាយជូនប្រជាពលរដ្ឋឱ្យបានសមស្របតាមលទ្ធភាព។ សូមរាជរដ្ឋាភិបាល អាជ្ញាធរខេត្ត ស្រុក និងឃុំ សង្កាត់ ជម្រុញការងារភូមិមួយ ផលិតផលមួយ ដើម្បីជួយសម្រួលការរកទីផ្សារផលិតផល ចំណីអាហារ គ្រឿងសម្ភារៈ និងរបស់របរប្រើប្រាស់ក្នុងសង្កាត់របស់ខ្លួនក្នុងការបង្កើនប្រាក់ចំណូលសេដ្ឋកិច្ចគ្រួសារជូនប្រជាពលរដ្ឋ។
- សូមរាជរដ្ឋាភិបាល អាជ្ញាធរខេត្ត ស្រុក និងសង្កាត់ បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំពោះបញ្ហាការចោលសំរាម អនាម័យ បរិស្ថាន ជាពិសេសរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ឱ្យបានទូលំទូលាយ ដើម្បីសុខភាពរបស់ប្រជាពលរដ្ឋក្នុងការរស់នៅ។ សូមរាជរដ្ឋាភិបាលបន្តបង្កើនយន្តការល្អៗក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការនៅតាម បណ្តាឃុំ សង្កាត់ទូទាំងប្រទេសកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បន្តទៀត ដើម្បីពង្រឹង លទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ ព្រមទាំងសមធម៌ឱ្យបានគ្រប់ជ្រុងជ្រោយ។ សូមរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង ស្ថាប័ននានា

ដែលមានសមត្ថកិច្ច មេត្តារៀបចំបង្កើតឡើងតុលាការ រដ្ឋបាល ដើម្បីដោះស្រាយបញ្ហាវិវាទរដ្ឋបាលនៅក្នុងប្រទេសកម្ពុជាផងដែរ។

# គន្តនិទ្ទេស

# គន្ថនិទ្ទេស

## ក.ផ្នែកបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១
- ៣.ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០១
- ច្បាប់ស្តីពីសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦
- អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០២
- អក្រឹត្យលេខ ២២ អក្រ.បក ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី ភារកិច្ច ក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ឆ្នាំ២០០២
- អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលដីធ្លី សង្កាត់ ឆ្នាំ ២០១៨
- អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ ចំណាយអភិវឌ្ឍមូលដ្ឋាន ឆ្នាំ២០១៩
- អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិក ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២០
- ប្រកាសលេខ ១៣២៩ ប្រ.ក ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ ឆ្នាំ២០០១
- ប្រកាសលេខ ១៨៣៨៤ ប្រ.ក ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦
- សេចក្តីណែនាំលេខ ០០៤ ស.ណ.ន ស្តីពីរបៀបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការភូមិ និងតួនាទី ភារកិច្ច របៀបរបបការរបស់ភូមិ ឆ្នាំ ២០០៦
- ផែនការណែនាំលេខ ០២០ ផ.ក ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១០
- ក្រណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ២០០៥

## ខ.ផ្នែកទ្រឹស្តី

- សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៩
- សៀវភៅការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៧

- សៀវភៅរដ្ឋបាលសាធារណៈ រៀបរៀងដោយ សាស្ត្រាចារ្យ ង៉ុយ ធឿន ឆ្នាំ២០១៩
- សៀវភៅនីតិរដ្ឋបាលទូទៅ រៀបរៀងដោយ អនុបណ្ឌិត អៀង សាង ឆ្នាំ២០១៧
- សៀវភៅនីតិរដ្ឋបាលទូទៅ រៀបរៀងដោយ បណ្ឌិត សាយ បូរី ឆ្នាំ២០១៥
- សៀវភៅជ្ឈការ និងវិសហមជ្ឈការ រៀបរៀងដោយ អនុបណ្ឌិត កៅ មុយថង ឆ្នាំ២០០៧

**គ.ឯកសារផ្សេងៗ**

- កម្មវិធីវិនិយោគវិនិយោគបីឆ្នាំរំកិល ២០២០-២០២៤ របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល
- របាយការណ៍ប្រចាំខែមីនា ឆ្នាំ២០១៩ ស្តីការអនុវត្តការងាររបស់រដ្ឋបាលសង្កាត់ព្រែកឫស្សី
- សៀវភៅផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ២០១៧-២០២២របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល
- អនុស្សរណៈ ស្តីពីការរៀបចំគម្រោងថវិកា ឆ្នាំ២០១៩
- បទសម្ភាសជាមួយស្មៀន ចៅសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ ១៖** | ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ |
| **ឧបសម្ព័ន្ធ ២៖** | ផែនទីសង្កាត់ព្រែកឫស្សី |
| **ឧបសម្ព័ន្ធ ៣៖** | ប្រកាសលេខ ៣០៨៧ ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាសង្កាត់ប្រធានក្រុមប្រឹក្សាចៅសង្កាត់ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ នៃសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល |
| **ឧបសម្ព័ន្ធ ៤៖** | កំណត់ហេតុស្តីពី ការអនុម័តកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សី (២០២២-២០២៤) ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ |
| **ឧបសម្ព័ន្ធ ៥៖** | របាយការណ៍ប្រចាំខែមីនា ឆ្នាំ២០២២ ស្តីពីការអនុវត្តការងាររដ្ឋបាលរបស់សង្កាត់ព្រែកឫស្សី |
| **ឧបសម្ព័ន្ធ ៦៖** | រូបថតជាមួយចៅសង្កាត់ និងមេប៉ុស្តិ៍នគរបាលសង្កាត់ព្រែកឫស្សី |
| **ឧបសម្ព័ន្ធ ៧៖** | សម្ភាសជាមួយចៅសង្កាត់ និងស្មៀនរបស់សង្កាត់ព្រែកឫស្សី |
| **ឧបសម្ព័ន្ធ ៨៖** | លិខិតបញ្ជាក់របស់រដ្ឋបាលសង្កាត់ព្រែកឫស្សី |

# ឧបសម្ព័ន្ធ ១.

# ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥

# ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

# ឧបសម្ព័ន្ធ ២.
# ផែនទីសង្កាត់ព្រៃកប្បាស្ស៊ី

# ផែនទីសង្កាត់ព្រែកឫស្សី



# ឧបសម្ព័ន្ធ ៣.

## ប្រកាសលេខ៣០៨ ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាសង្កាត់ ប្រធានក្រុមប្រឹក្សា ចៅសង្កាត់ ចៅសង្កាត់រងទី១និងចៅសង្កាត់រងទី២ នៃសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:២៣១២ ប្រ.ក

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាសង្កាត់ ប្រធានក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ នៃសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅសង្កាត់ព្រែកឫស្សី លេខកូដ ០៨-១៤៣ នៃខេត្តកណ្តាល( ទម្រង់បែបបទ១១១៨ )របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧

# សម្រេច

**ប្រការ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ឆេង ឆៃ | ជាប្រធានក្រុមប្រឹក្សាសង្កាត់ |
| ២- | លោក | យូ សារី | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៣- | លោក | យុន ផាត | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៤- | លោកស្រី | ពត ផារី | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៥- | លោក | ហេង ផេនិច្ច | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៦- | លោកស្រី | ធន លីដា | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៧- | លោក | ម៉ឹង សុខលី | ជាសមាជិកក្រុមប្រឹក្សាសង្កាត់។ |

**ប្រការ២.-**

ទទួលស្គាល់សមាសភាពជាចៅសង្កាត់ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ នៃសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ឆេង ឆៃ | ជាចៅសង្កាត់ |
| ២- | លោក | យូ សារី | ជាចៅសង្កាត់រងទី១ |
| ៣- | លោក | យុន ផាត | ជាចៅសង្កាត់រងទី២។ |

**ប្រការ៣.-**

ការអនុវត្តការងារប្រធានក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាសង្កាត់ នៃសង្កាត់ព្រែកឬស្សី ត្រូវអនុវត្តតាមវិធានដ្ឋានុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលខេត្ត ក្រុង សង្កាត់ សាមី
- ដូចក្នុងប្រការ១
  "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤.

# កំណត់ហេតុស្តីពី ការអនុម័តកម្មវិធីយោគពាន្លាំរំកិលរបស់ សង្កាត់ព្រែកឫស្សី ឆ្នាំ( ២០២២-២០២៤ )

# ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា

**បានទទួលការអនុម័តពីក្រុមប្រឹក្សា សង្កាត់ព្រែកឫស្សី**
**ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១**

## <u>មាតិកា</u>


សេចក្តីសម្រេចស្តីពី ការដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ........ ២

អារម្ភកថា ........ ៤

សេចក្តីផ្តើម ........ ៦

ផែនទីរដ្ឋបាលសង្កាត់ ........ ៨

**ជំពូកទី១៖ ស្ថានភាពទូទៅ និងបញ្ហាប្រឈម**

១.១. សេចក្តីសង្ខេបទិន្នន័យឃុំសង្កាត់ ........ ៩

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ........ ១១

- ❖ ផ្នែកសេដ្ឋកិច្ច ........ ១១
- ❖ ផ្នែកសង្គមកិច្ច ........ ១៣
- ❖ ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ........ ១៤
- ❖ ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ១៦

**ជំពូកទី ២៖ គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល**

២.១. តារាងសង្ខេបប្រភពមូលនិធិ ........ ១៨

២.២. តារាងគម្រោង សកម្មភាពកំពុងដំណើរការ ........ ២០

២.៣. តារាងគម្រោង សកម្មភាពមានថវិកាគាំទ្រ ........ ២១

២.៤. តារាងគម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ ........ ២៥

២.៥. តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ........ ២៦

២.៦. តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ........ ២៧

**ជំពូកទី៣៖ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល**

៣.១. ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ........ ២៨

៣.២. ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ ........ ២៨

៣.៣. របាយការណ៍ស្តីពីលទ្ធផលតាមដាន និងវាយតម្លៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ........ ២៨

**ឧបសម្ព័ន្ធ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្ដាល**
**ក្រុងតាខ្មៅ**
**សង្កាត់ព្រែកឬស្សី**

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ព្រែកឬស្សីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីសម្រេច
## ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល (២០២២-២០២៤)

**ប្រធានក្រុមប្រឹក្សា សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល-**

-បានឃើញព្រះរាជក្រមលេខនស រកម ០៣០១០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

-យោងអនុក្រឹត្យលេខ ២៥ អនក្រ បក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ។

-យោងអនុក្រឹត្យលេខ ២៦អនក្រ បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។

-យោងប្រកាសលេខ ៣៣១សហវ ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការអនុវត្តថវិកាឃុំ សង្កាត់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-យោងប្រកាសអន្តរក្រសួងលេខ ២៤២៣ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

-យោងប្រកាសអន្តរក្រសួងលេខ៣៤៤០ប្រករបស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែប្រែប្រការ៦ នៃប្រកាសអន្តរក្រសួងលេខ២៤២៣ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

-យោងប្រកាស លេខ ២៣៧១ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ នៃសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-យោងប្រកាសអន្តរក្រសួងផែនការ និងក្រសួងមហាផ្ទៃ ស្តីពីការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងផែនការផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ។

-យោងសេចក្តីណែនាំស្តីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២២-២០២៤) និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ប្រាំឆ្នាំ(២០១៧-២០២៣) ។

-យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ។

## សម្រេច

**ប្រការ ១**.~ ត្រូវបានដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី កាលពី ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ។

**ប្រការ ២**.~ ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ត្រូវចាត់ចែង ផ្សព្វផ្សាយកម្មវិធីវិនិយោគនេះដល់ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសង្កាត់ ត្រូវចាត់ចែង សម្របសម្រួល កៀរគរធនធានក្នុងការអនុវត្តកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ប្រកបដោយការចូលរួម មានតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣**.~ ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ត្រូវរៀបចំយន្តការប្រព័ន្ធសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍កម្មវិធីវិនិយោគនេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី។ ក្រុមប្រឹក្សាសង្កាត់ ត្រូវរៀបចំរបាយការណ៍ ស្តីពីលទ្ធផលនៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល រាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាសង្កាត់ អំពីវឌ្ឍនភាពនៃការអនុវត្តទៅតាមកាលកំណត់ និងដាក់របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តកម្មវិធីវិនិយោគនេះ ជូនក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។

**ប្រការ ៤**.~ ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ត្រូវធ្វើការវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគនៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ របស់ក្រុមប្រឹក្សាសង្កាត់ ដើម្បីវាយតម្លៃពីលទ្ធផលសម្រេចបាន ធៀបនឹងគោលដៅ និងគោលបំណងដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគ ៣ឆ្នាំ រំកិល របស់សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។

**ប្រការ ៥**.~ ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី មេភូមិ អនុភូមិ ជំនួយការ ស្មៀន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងសង្កាត់ព្រែកឫស្សី ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

**ចម្លងជូន៖**
- សាលាខេត្តកណ្តាល
- សាលាក្រុងតាខ្មៅ

*"ដើម្បីជូនជ្រាប"*

- ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី
- មេភូមិ ស្មៀន និងអ្នកពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

**ជ.ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី**

**ប្រធាន**

## **អារម្ភកថា**

ក្រុមប្រឹក្សាសង្កាត់ព្រៃកប្ញស្សី គណៈកម្មាធិការកសាងផែនការនិងថវិកា(គ.ផ.ថ) របស់សង្កាត់ព្រៃកប្ញស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល បានរៀបចំកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល នេះឡើង ស្របតាមប្រកាសអន្តរក្រសួងលេខ ០៧៣ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ ដោយបានផ្តល់ឱកាសឱ្យមានការចូលរួមពី ក្រុមប្រឹក្សាសង្កាត់ គណៈកម្មការកសាងផែនការ និងថវិកា

(គ.ផ.ថ) មេភូមិ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ដោយបានយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចជា បរិយាប័ន្ន សមធម៌សង្គម ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងដំណើរការនៃការការរៀបចំ និងការកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល សង្កាត់ព្រៃកប្ញស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។

កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលនេះ បានផ្តល់នូវគោលការណ៍ណែនាំផ្នែកគោលនយោបាយ ក្របខ័ណ្ឌអភិវឌ្ឍន៍ ដើម្បីតម្រង់ទិសដល់រដ្ឋបាលសង្កាត់ ក្នុងការអភិវឌ្ឍន៍លើផ្នែកទាំង៤ រួមមាន៖ ១).ផ្នែកសេដ្ឋកិច្ច ២).ផ្នែកសង្គមកិច្ច ៣).ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ៤).ផ្នែកគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការលើកកំពស់ផ្នែកសេវាសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ ការលើកកំពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់ព្រៃកប្ញស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល អាណត្តិទី៤ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តម បណ្ឌិត អភិបាល នៃគណៈអភិបាលខេត្តកណ្តាល លោកអភិបាលនៃគណៈអភិបាលក្រុងតាខ្មៅ** ដែលបានជួយគាំទ្រក្នុងដំណើរការនៃការរៀបចំ និងការកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល របស់សង្កាត់ព្រៃកប្ញស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រកបដោយភាពជោគជ័យ។

សូមថ្លែងអំណរគុណចំពោះ ក្រុមប្រឹក្សាសង្កាត់ព្រៃកប្ញស្សី គណៈកម្មាធិការកសាងផែនការ និងថវិកា (គ.ផ.ថ) គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារីនិងកុមារ ការិយាល័យផែនការ និងគាំទ្រសង្កាត់ មេភូមិ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល សប្បុរសជននានា គណៈពង្រឹងមូលដ្ឋាន ជាពិសេស ក្រុមយុវជន និងកុមារ និងអ្នកពាក់ព័ន្ធជាច្រើនទៀតនៅក្នុងសង្កាត់ ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល របស់សង្កាត់ព្រៃកប្ញស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល របស់យើង។

ម្យ៉ាងវិញទៀត សូមធ្វើការថ្លែងអំណរគុណ អស់ពីចិត្ត ពីថ្លើម ជូនចំពោះ **លោក ឆេង ឆៃ ចៅសង្កាត់ព្រៃកប្ញស្សី និងជាប្រធានក្រុមប្រឹក្សាសង្កាត់** លោក លោកស្រី ក្រុមប្រឹក្សាសង្កាត់ ក្រុមការងារកសាងផែនការនិងថវិកាសង្កាត់(គ.ផ.ថ) ដែលបានដឹកនាំ និងសម្របសម្រួលក្នុងដំណើរការកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល រហូតទទួលបានសម្រេចជោគជ័យជាស្ថាពរ។

ក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សី រំពឹងថា រដ្ឋបាលក្រុងតាខ្មៅ រដ្ឋបាលខេត្តកណ្តាល មន្ទីរ អង្គភាព ជំនាញ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ គណៈពង្រឹងមូលដ្ឋាន និងសប្បុរសជន នឹងជួយគាំទ្រគម្រោងសកម្មភាពសេវាជាអាទិភាពដែលអាចឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ដែលបានកំណត់និងសម្រេចឱ្យបាននៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ របស់សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។

សូមគោរពជូនពរដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់** សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ និងជួបតែសេចក្តីសុខ សេចក្តីចំរើន ជារៀងដរាបតរៀងទៅ។

ថ្ងៃព្រហស្បត៍១១រោច ខែមីគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ព្រែកឬស្សី ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១
**ជ.ក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សី**
**ប្រធាន**

## <u>សេចក្តីផ្តើម</u>

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឲ្យក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនិងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនានា។

ព្រែកឬស្សី គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង១០ របស់ក្រុងតាខ្មៅ ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹងសង្កាត់ដើមមៀន ខាងត្បូងទល់នឹងសង្កាត់កំពង់សំណាញ់និងសង្កាត់តាក្តុល ខាងកើតទល់នឹងសង្កាត់តាខ្មៅ និងខាងលិចទល់នឹងខណ្ឌដង្កោ រាជធានីភ្នំពេញ។

យោងសៀវភៅឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងសៀវភៅទិន្នន័យរបស់សង្កាត់ព្រែកឬស្សីឆ្នាំ២០១៩ រៀបរៀងដោយមន្ទីរផែនការខេត្តកណ្តាល ការគ្រប់គ្រងផ្នែករដ្ឋបាលសង្កាត់ព្រែកឬស្សី មានផ្ទៃដី ២២៦.២០៩ហិកតា ចែកចេញជា ៥ភូមិគឺ៖ *ភូមិក្រពើហា ភូមិក្រពើហាកើត ភូមិព្រែកឬស្សី ភូមិព្រែកឬស្សីលិច និងភូមិព្រែកអញ្ចាញ* មានប្រជាពលរដ្ឋរស់នៅសរុប ២.៣៣៧គ្រួសារ ចំនួនប្រជាពលរដ្ឋសរុប ១១.០១២នាក់ ស្រី ៦.៤៤៥នាក់ ដង់ស៊ីតេប្រជាជន ៤.៣២៣នាក់/គម២។

ប្រជាពលរដ្ឋភាគច្រើន ជាអ្នកប្រកបរបរលក់ដូរនៅទីផ្សារក្នុងស្រុកនិងលក់ដូរនៅតាមផ្ទះចំនួន២៧.៤% ជាមន្ត្រីរាជការចំនួន ២១.៥%សិប្បកម្ម១.៨% ប្រកបរបរនេសាទចំនួន០.១% កម្មករចំនួន៧.១%កសិករចំនួន៥.៥% បុគ្គលិកឯកជន២៨% និងផ្សេងៗចំនួន៨.៦%ដែលអាចរកចំណូលបាន ជាមធ្យមសំរាប់ទ្រទ្រង់ជីវភាពក្នុងគ្រួសារ ។

ក្រុមប្រឹក្សាសង្កាត់ព្រែកឬស្សី អាណត្តិទី៤ នេះ បានរៀបចំនូវកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់សម្រាប់ ឆ្នាំ២០២២-២០២៤ *ស្របតាមអាណត្តិនៃការគ្រប់គ្រងរបស់ក្រុមប្រឹក្សា* ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ (អនុក្រឹត្យលេខ១២៩ អនក្របក) ប្រកាសឲ្យប្រើប្រាស់នៅខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ(អនុក្រឹត្យលេខ១៥២ អនក្របក) ប្រកាសឲ្យប្រើនៅ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ (ប្រកាសអន្តរក្រសួងលេខ ៣៥១៤ ប្រ.ក) ស្តីពីការកែសម្រួលប្រការ១ ប្រកាសឲ្យប្រើនៅ ខែតុលា ឆ្នាំ២០១៣ នៃប្រកាសក្រសួងស្តីពីការកសាងផែនការនិងកម្មវិធីវិនិយោគបីឆ្នាំ រំកិលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ (ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក) ប្រកាសឲ្យប្រើនៅខែធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់នីតិវិធីលម្អិតក្នុងការកសាងផែនការនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង (ប្រកាសអន្តរក្រសួងលេខ ០៧៣ ផ.ក) ប្រកាសឱ្យប្រើនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ។

ការរៀបចំកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់នេះ ស្របតាមសេចក្តីណែនាំបច្ចេកទេស ដោយមានការចូលរួមពិគ្រោះយោបល់ជាមួយ ក្រុមប្រឹក្សាសង្កាត់ មេភូមិ ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ក្រុមតំណាងផលប្រយោជន៍ ពិសេសក្រុមយុវជននិងកុមារ អង្គការសង្គមស៊ីវិល វិស័យឯកជន គណៈពង្រឹងមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការវិភាគស្ថានភាព សក្តានុពល បញ្ហាប្រឈម និងតម្រូវការគម្រោងជាអាទិភាព។

សម្រាប់អាណត្តិទី៤ របស់ក្រុមប្រឹក្សាសង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល បានរៀបចំកម្មវិធី វិនិយោគ ៣ឆ្នាំរំកិលសង្កាត់នេះឡើង ដោយផ្អែកតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោម៖

១. ចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ចនិងសង្គម

៨. ការធានានិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌។

កម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់សង្កាត់ព្រែកឫស្សី មាន ៣ជំពូកគឺ៖ ទី១).បរិយាយអំពីស្ថានភាពទូទៅនិងបញ្ហាប្រឈមក្នុងសង្កាត់ ទី២).គម្រោងសកម្មភាពនៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ ទី៣).ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់ និងគម្រោងជាអាទិភាព ដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន សក្តានុពលនានាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច លើកកម្ពស់គុណភាពសេវា ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមគោលការណ៍យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា *អាណត្តិទី៥ នៃរដ្ឋសភា។*

## ផែនទីរដ្ឋបាលសង្កាត់

# ជំពូកទី១

# ស្ថានភាពទូទៅ និងបញ្ហាប្រឈម

## ១.១. សេចក្តីសង្ខេបទិន្នន័យចម្បងៈ

យោងតាមសៀវភៅឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២០ និងសៀវភៅទិន្នន័យសង្កាត់ព្រែកឬស្សី ឆ្នាំ២០២០ ដែលរៀបរៀងដោយមន្ទីរផែនការខេត្តកណ្តាល ក្នុងនោះ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល មានស្ថានភាពព័ត៌មានទូទៅដូចខាងក្រោមៈ

តារាងសង្ខេបទិន្នន័យចម្បងរបស់ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល

| ល.រ | បរិយាយ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | | | |
| ១ | ផ្ទៃដីសង្កាត់(គម$^២$) | ៣.២៨ | ៣.២៨ | ៣.២៨ | ៣.២៨ | ៣.២៨ |
| ២ | ចំនួនភូមិ | ៥ | ៥ | ៥ | ៥ | ៥ |
| ៣ | ចំនួនគ្រួសារ | | ១.៩៩២ | ២.០៨០ | ២.១៦៣ | ២.២៥១ |
| ៤ | %មេគ្រួសារជាស្ត្រី | ១០.៧ | ១០.៧ | ១០.៤ | ៩.៨ | ៩.២ |
| ៥ | ចំនួនប្រជាជនសរុប | ១៤.៩១៣ | ៩.៥០៨ | ៩.៦៥៨ | ១០.០៩១ | ១០.២៦៩ |
| ៦ | ចំនួនស្រី | | ៤.៧៥០ | ៥.០៦៣ | ៨.១០២ | ៥.៦៦៧ |
| ៧ | ចំនួនប្រុស | | ៤.៧៩៨ | ៤.៥៦៥ | ៥.២៥៦ | ៤.៦០២ |
| ៨ | %អ្នកមានអាយុពី០-១៧ឆ្នាំ | ៣៤.២ | ៣៤.២ | ៣៤.៦ | ៣៤.៦ | ៣៤.៤៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | %អ្នកមានអាយុពី១៨-៦០ឆ្នាំ | .0 | ៥៦.៦ | ៥៥.៩ | ៥៥.៦ | ៥៥.៣ |
| ១០ | %អ្នកមានអាយុពី៦១ឆ្នាំឡើងទៅ | ៦.៧ | ៩.២ | ៩.៥ | ៩.៨ | ១០.៤ |
| ១១ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | ៥.៤ | ០.៨ | ១.៦ | ៤.៥ | ១.៨ |
| ១២ | %អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | ៧ | ៧ | ៧ | ៥.៥ | ៥.៣ |
| ១៣ | %អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | ២.២ | ២.២ | ២.២ | ១.៨ | ១.៥ |
| ១៤ | %អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | ៨៦.៥ | ៩០.៨ | ៩០.៨ | ៩២.៧ | ៩៣.២ |
| ១៥ | %មនុស្សទៅរកការងារធ្វើក្នុងប្រទេស | ០.៥ | ០.៥ | ០.៥ | ១.០ | ១.១ |
| ១៦ | %មនុស្សទៅរកការងារធ្វើក្រៅប្រទេស | ០.៥ | ០.៥ | ០.៥ | ០.៥ | ០.៥ |
| ១៧ | %ខ្ទង់ផ្ទះមានអគ្គិសនីប្រើប្រាស់ | ៩៧ | ៩៨ | ៩៩.៨ | ១០០ | ១០០ |
| **អប់រំ** | | | | | | |
| ១៨ | %កុមារអាយុ ៣-៥ឆ្នាំ បានចូលរៀន | ៦៦.៤ | ៦៦.៤ | ៦៦.៤ | ៦៤.៩ | ៦៧.៧ |
| ១៩ | %កុមារអាយុ ៦ឆ្នាំ បានចូលរៀន | ១០០ | ១០០ | ១០០ | ១០០ | ៩៨.២ |
| ២០ | %កុមារអាយុ ៦-១១ឆ្នាំ បានចូលរៀន | ១០០ | ១០០ | ១០០ | ៩៩.៨ | ៩៧.២ |
| ២១ | %កុមារអាយុ ១២-១៤ឆ្នាំ នៅរៀន | ៦៨.៥ | ៦៨.៥ | ៦៨.៥ | ៧៧.១ | ៩៤.៦ |
| ២២ | %អ្នកចេះអក្សរអាយុ ១៥-១៧ឆ្នាំ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ២៣ | %អ្នកចេះអក្សរអាយុ ១៨-៤៥ឆ្នាំ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| **សុខាភិបាល** | | | | | | |
| ២៤ | ចំនួនមណ្ឌលសុខភាព | ០១ | ០១ | ០១ | ០១ | ០១ |
| ២៥ | %ស្ត្រីសម្រាលកូនដោយពេទ្យឆ្មប | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ២៦ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល (០-១ខែ)ក្នុង១ពាន់កំណើត | 0 | 0 | 0 | 0 | 0 |
| ២៧ | អត្រាស្លាប់របស់កុមារក្រោយពេលកើត (០-១ខែ)ក្នុង១ពាន់កំណើត | 0 | 0 | 0 | 0 | 0 |
| ២៨ | %កុមារអាយុពី ៩-១២ខែចាក់ថ្នាំបង្ការគ្រប់ចំនួន | ៩៥.៧ | ៩៥.៧ | ៩៨ | ១០០ | ១០០ |
| ២៩ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | ១២ | ១២ | ១១ | ១១ | ១៧ |
| **ភាពងាយរងគ្រោះ** | | | | | | |
| ៣០ | ចំនួនជនពិការ | ២៩ | ២៩ | ២៩ | ២៦ | ២៧ |
| ៣១ | %ជនពិការអាយុ ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | ៦០ | ៦៤.៩ | ៧២ | ៥២ | ៦៦.៧ |
| ៣២ | ចំនួនកុមារកំព្រាដោយឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | 0 | 0 | ០៨ | ០៧ | ០៦ |
| ៣៣ | ចំនួនជនចាស់ជរាគ្មានទីពឹង | ១ | ១ | ១ | ២ | ១ |
| **ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ** | | | | | | |
| ៣៤ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ | 0 | 0 | 0 | 0 | 0 |
| ៣៥ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | 0 | 0 | 0 | 0 | 0 |
| ៣៦ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | 0 | 0 | 0 | 0 | 0 |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៧ | %គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | ៣៨.១ | ៤០.១ | ៤៣.៣ | ៤៥.៦ | ៣៨.៨ |
| ៣៨ | %គ្រួសារមានទឹកស្អាតប្រើប្រាស់ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ក្នុងនោះ: | %គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| | %គ្រួសារមានទឹកអណ្តូងស្នប់ ឬអណ្តូងចម្រុះ | ០ | ០ | ០ | ០ | ០ |
| | %គ្រួសារប្រើទឹកអណ្តូងជីកមានការពារ | ០ | ០ | ០ | ០ | ០ |
| | %គ្រួសារប្រើទឹកភ្លៀងមានការពារ | ០ | ០ | ០ | ០ | ០ |
| ៣៩ | %គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ៩៩ | ៩៩ | ៩៩.៤ | ៩៩.៨ | ១០០ |
| **រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | |
| ៤០ | %កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | ៩៩ | ៩៩ | ៩៩ | ១០០ | ១០០ |
| ៤១ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | ១ | ១ | ១ | ១ | ០ |
| ៤២ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | ១ | ១ | ១ | ២ | ០ |
| ៤៣ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | ០ | ០ | ០ | ០ | ១ |
| ៤៤ | គ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | ៤៥ | ៦១ | ៧០ | ១០ | ៥៤ |

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម៖

ព្រែកឫស្សី គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង១០ របស់ក្រុងតាខ្មៅ ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹងសង្កាត់ដើមមៀន ខាងត្បូងទល់នឹងសង្កាត់កំពង់សំណាញ់និងសង្កាត់តាក្តុល ខាងកើតទល់នឹងសង្កាត់តាខ្មៅ និងខាងលិចទល់នឹងខណ្ឌដង្កោ រាជធានីភ្នំពេញ។

យោងសៀវភៅឯកសារព័ត៌មានស្ថានភាព ស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងសៀវភៅទិន្នន័យរបស់សង្កាត់ព្រែកឫស្សីឆ្នាំ២០២០ រៀបរៀងដោយមន្ទីរផែនការខេត្តកណ្តាល ការគ្រប់គ្រងផ្នែករដ្ឋបាលសង្កាត់ព្រែកឫស្សី មានផ្ទៃដី ២២៦.២០៩ហិកតា ចែកចេញជា ៥ភូមិគឺ៖ *ភូមិក្រពើហា ភូមិក្រពើហាកើត ភូមិព្រែកឫស្សី ភូមិព្រែកឫស្សីលិច និងភូមិព្រែកអញ្ចាញ* មានប្រជាពលរដ្ឋរស់នៅសរុប ២.៣៣៧គ្រួសារ ចំនួនប្រជាពលរដ្ឋសរុប ១១.០១២នាក់ ស្រី ៦.៤៤៥នាក់ ដង់ស៊ីតេប្រជាជន ៤.៣២៣នាក់/គម២។

ប្រជាពលរដ្ឋភាគច្រើន ជាអ្នកប្រកបរបរលក់ដូរនៅទីផ្សារក្នុងស្រុកនិងលក់ដូរនៅតាមផ្ទះចំនួន២៧.៤% ជាមន្ត្រីរាជការចំនួន ២១.៥%សិប្បកម្ម១.៨% ប្រកបរបរនេសាទចំនួន០.១% កម្មករចំនួន៧.១%កសិករចំនួន៥.៥% បុគ្គលិកឯកជន២៨% និងផ្សេងៗចំនួន៨.៦%ដែលអាចរកចំណូលបាន ជាមធ្យមសំរាប់ទ្រទ្រង់ជីវភាពក្នុងគ្រួសារ ។

ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពបច្ចុប្បន្នរបស់សង្កាត់ព្រែកឫស្សី នៃដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់ ឯកសារព័ត៌មានស្ថានភាព

សេដ្ឋកិច្ច សង្គមកិច្ច និងលទ្ធផលនៃការវិភាគពិន្ទុវិស័យ និងស្ថានភាពសង្កាត់ព្រែកឬស្សី ឆ្នាំ២០១៩ ឃើញថា សង្កាត់ព្រែកឬស្សី មានបញ្ហាប្រឈមតាមផ្នែកសំខាន់ៗ ដូចតទៅ៖

**✚ ផ្នែកសេដ្ឋកិច្ច**

✧ **អាជីវកម្ម៖** ក្នុងវិស័យនេះសង្កាត់ព្រែកឬស្សី មានមូលដ្ឋានផលិតកម្មមួយចំនួនដូចជា សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ សិប្បកម្មផលិតទឹកសុទ្ធ សិប្បកម្មកាត់ដេរ ទំនិញប្រើប្រាស់ គ្រឿងអេឡិចត្រូនិក សម្ភារសំណង់ អាជីវកម្មខ្នាតតូច ជួសជុលគ្រឿងរថយន្ត ម៉ូតូ គ្លីនិច និងឱសថស្ថាន បានកំពុងរីកលូតលាស់ និង ផ្តល់ការងារបន្ថែមទៀតដល់ប្រជាពលរដ្ឋរបស់យើង។ រីឯបញ្ហាប្រឈមគឺ សិប្បកម្មមួយចំនួនមិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ ផលិតផលខ្លះមិនទាន់ធានាលើគុណភាព ខ្លះទៀតមិនទាន់មានច្បាប់អនុញ្ញាតអាជីវកម្ម ដែលតម្រូវឱ្យទៅសុំច្បាប់ ឬបន្តច្បាប់អនុញ្ញាតអាជីវកម្មនៅការិយាល័យច្រកចេញចូលតែមួយ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត សិប្បកម្មខ្លះមាន លក្ខណៈមិនទាន់ត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស ការដាក់តាំងសម្ភារលក់ដូររបស់ប្រជាពលរដ្ឋ រំលោភមកលើចិញ្ចើមផ្លូវសាធារណៈ ដែលតម្រូវឲ្យមានការត្រួតពិនិត្យផ្សព្វផ្សាយច្បាប់ ឬបណ្តុះបណ្តាលបច្ចេកទេសថ្មី។

✧ **កសិកម្ម៖** សង្កាត់ព្រែកឬស្សី មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ដូចជា ទឹកស្ទឹង ព្រែកឆ្នោត និងប្រព័ន្ធទឹកផ្សេងៗទៀត ប្រជាកសិករប្រមាណ៥,៥% បានប្រកបរបរកសិកម្ម បង្កបង្កើនផលដូចជា ធ្វើស្រែ ដាំដំណាំរយៈពេលវែង ដំណាំរយៈពេលខ្លី ដាំបន្លែ អាជីវកម្មលក់បំណែកកូនពូជរុក្ខជាតិ។ល។ ទន្ទឹមនឹងនោះក៏មានបញ្ហាខ្វះបច្ចេកទេសកសិកម្ម ប្រជាកសិករបានលក់ដីស្រែចំការរបស់ខ្លួនដើម្បីផ្លាស់ប្តូរមុខរបរ ខ្វះបច្ចេកទេស ការប្រើប្រាស់ថ្នាំគីមីលើសកម្រិត ដូចនេះទាមទារឲ្យធ្វើការបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដាំដុះ បច្ចេកទេសការចិញ្ចឹមសត្វ និងពង្រឹងសមត្ថភាពប្រជាពលរដ្ឋ។

✧ **ឧស្សាហកម្ម៖** សង្កាត់ព្រែកឬស្សី មានឧស្សាហកម្ម សិប្បកម្ម រោងចក្រ និងការងារសំណង់សំខាន់ៗ ដូចជា រោងចក្រកាត់ដេរ សិប្បកម្មផលិតអំបោះ សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ ដោយបានផ្តល់នូវការងារមួយចំនួន ជូនដល់ពលរដ្ឋដើម្បីរួមចំណែកដោះស្រាយជីវភាពបានល្អប្រសើរ។ ទន្ទឹមនឹងនោះក៏មានចំនុចអសកម្មដូចជា និយោជក និយោជិតពុំទាន់បានអនុវត្តត្រឹមត្រូវតាមច្បាប់ការងារ ដូចនេះត្រូវយកចិត្តទុកដាក់បង្កើនការអប់រំផ្សព្វផ្សាយច្បាប់ការងារដល់និយោជក និយោជិតឲ្យបានយល់ដឹងកាន់តែទូលំទូលាយបន្ថែមទៀត។

✧ **គមនាគមន៍៖** សង្កាត់ព្រែកឬស្សី មានផ្លូវជាតិឆ្លងកាត់១ខ្សែ គឺផ្លូវជាតិលេខ២ ផ្លូវខេត្ត និងផ្លូវលំក្នុងភូមិខ្វាត់ខ្វែង រួមមានផ្លូវបេតុងអាមេ ផ្លូវក្រាលគ្រួសក្រហមជាដើម តែសម្រាប់ការអភិវឌ្ឍន៍ ក្នុងឆ្នាំ២០២០ និងឆ្នាំបន្តបន្ទាប់ទៅទៀត សង្កាត់នឹងប្រែក្លាយផ្លូវដីសក្នុងភូមិ ឲ្យទៅជាផ្លូវបេតុងអាមេទាំងអស់ ។ ទោះបីមានការខិតខំប្រឹងប្រែងរបស់អាជ្ញាធរខេត្ត ក្រុង សង្កាត់ ធ្វើឲ្យមានសក្តានុពលយ៉ាងខ្លាំងនេះក្តី ក៏នៅមានបញ្ហាប្រឈមតិចតួចដូចជា ហេដ្ឋារចនាសម្ព័ន្ធ មួយចំនួនមានការដឹកទំនិញលើសកម្រិតទម្ងន់ហាមឃាត់ មានទឹកលិចផ្លូវនៅរដូវវស្សា ប្រព័ន្ធលូរំដោះទឹក ពុំទាន់មានគ្រប់គ្រាន់ ប្រព័ន្ធលូ ប្រឡាយខ្លះទៀតមានការខកខានមិនបានស្តារ និងខ្លះទៀតត្រូវបានប្រជាជនចាក់ដីលុបនិងធ្វើលំនៅដ្ឋានពីលើ រីឯផ្លូវលំមួយចំនួនតូចចង្អៀតជួបការលំបាកដល់ការធ្វើចរាចរយានយន្ត។ បញ្ហាទាំងនេះត្រូវបន្តយកចិត្តទុកដាក់ កសាង ពង្រីកផ្លូវ ចាក់បេតុង កៅស៊ូ ឱ្យបានសមរម្យ ដើម្បីឲ្យមាននិរន្តរភាពចរាចរណ៍ ស្តារប្រព័ន្ធលូ ដើម្បីធានារំដោះទឹកចេញនៅរដូវភ្លៀងធ្លាក់បានទាន់ពេលវេលា។

❖ **សេវាកម្ម៖** សង្កាត់ព្រែកឬស្សី មានទីតាំងផលិតកម្មនិងសេវាកម្មចំនួន ជាច្រើនកន្លែង ដែលជាទីតាំងប្រកបមុខរបរសេវាកម្មលក់ដូរម្ហូបអាហារ សម្ភារ ទំនិញកសិផលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ ក៏នៅមានបញ្ហាមួយចំនួនកើតឡើងដូចជា ពុំមានផ្សារលក់ដូរធំទូលាយ ការលក់ដូរទំនិញផ្សេងៗ ដាក់ហៀរមកលើចិញ្ចើមផ្លូវសម្រាប់ថ្មើរជើង ពុំសូវមានសណ្តាប់ធ្នាប់។ ដូចនេះត្រូវយកចិត្តទុកដាក់រៀបចំសណ្តាប់ធ្នាប់លក់ដូរតាមចិញ្ចើមផ្លូវឲ្យបានសមរម្យ ។

❖ ផ្នែកទឹកស្អាត អគ្គិសនី បានតបណ្តាញដាក់ជូនប្រជាពលរដ្ឋប្រើប្រាស់បានចំនួន១០០%។ ថ្វីបើសង្កាត់ព្រែកឬស្សី មានអគ្គិសនីប្រើប្រាស់គ្រប់ក្រុមគ្រួសារក៏ដោយ ប៉ុន្តែការតបណ្តាញអគ្គិសនីនៅកន្លែងខ្លះខ្វះសណ្តាប់ធ្នាប់ អាចបង្កជាហានិភ័យ ហើយនៅតាមដងផ្លូវសំខាន់ៗមួយចំនួន មានការខ្វះខាតភ្លើងបំភ្លឺផ្លូវសាធារណៈ ដែលត្រូវឱ្យមានការខិតខំជម្រុញការតបណ្តាញអគ្គិសនី និងបន្ថែមភ្លើងបំភ្លឺបន្ថែមទៀតរីឯ *(ទឹកចេញតិច ខ្សោយ)*បញ្ហាទឹកស្អាត កន្លែងខ្លះមានការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការទាន់ពេលវេលា។

❖ **ការវិនិយោគ៖** សង្កាត់ព្រែកឬស្សី មានការចូលរួមវិនិយោគជាច្រើនពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងវិស័យឯកជន ជាក់ស្តែងដូចជា រោងចក្រកាត់ដេរ សំណង់ផ្ទះល្វែង ផ្លូវ ស្ពានពិសេស ផ្លូវជាតិលេខ២( រីឯ មហាវិថីរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** *(ផ្លូវ៦០ម៉ែត្រ)* ក៏បានបើកឲ្យដំណើរការប្រើប្រាស់ និងឆ្ពោះមកឆ្លងកាត់ភូមិសាស្ត្រសង្កាត់ព្រែក ឬស្សី ផងដែរ។ ទោះបីមានការចូលរួមអភិវឌ្ឍន៍យ៉ាងនេះក្តី ក៏នៅមានបញ្ហាខ្វះចន្លោះដូចជាការសង់សំណង់មួយចំនួន ពុំបានសុំច្បាប់អនុញ្ញាតពីអាជ្ញាធរ ការចតយានជំនិះមកលើផ្លូវសាធារណៈពុំមានសណ្តាប់ធ្នាប់ ការដាក់តាំងសម្ភារ លក់ដូរហៀរមកលើចិញ្ចើមផ្លូវសាធារណៈ។ ដូច្នេះត្រូវបន្តយកចិត្តទុកដាក់ផ្សព្វផ្សាយអំពីសេវារដ្ឋបាល ពាក់ព័ន្ធនឹងការអនុញ្ញាតច្បាប់សាងសង់សំណង់ផ្សេងៗ របស់ ការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ និងរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានជាប្រចាំ។

❖ **ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** សង្កាត់ព្រែកឬស្សី មានទីតាំងភូមិសាស្ត្រអំណោយផលល្អសម្រាប់វិនិយោគគិនជាច្រើន ដូចជាការបើកសិប្បកម្មកាត់ដេរ សិប្បកម្មកែច្នៃគ្រឿងសង្ហារឹមធ្វើអំពីឈើ អាលុយមីញ៉ូម ស័ង្កសី ស្ព័ន និងសិបកម្មផលិតទឹកបរិសុទ្ធ។ល។ សិប្បកម្ម ទាំងនេះបានជួយឱ្យប្រជាពលរដ្ឋទទួលបានប្រាក់ចំណូលសមរម្យសម្រាប់ផ្គត់ផ្គង់ជីវភាព ក្នុងនោះ ក្រោមការដឹកនាំណែនាំរបស់គណៈពង្រឹងមូលដ្ឋានគ្រប់ថ្នាក់ បានចុះជួយដោះស្រាយប្រជាពលរដ្ឋជាបន្តបន្ទាប់ ដូចជាយកចិត្តទុកដាក់លើការឧបត្ថម្ភសម្ភារ ថវិកា ដល់ស្ត្រីសម្រាលកូន សួរសុខទុក្ខចាស់ជរា សមាគមមនុស្សចាស់ដោះស្រាយបញ្ហាគ្រោះមហន្តរាយកើតឡើងជាយថាហេតុ និងការទាក់ទាញអ្នកវិនិយោគទុនផ្សេងៗទៀតដើម្បីមកអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

## ផ្នែកសង្គមកិច្ច

❖ **អប់រំ៖** ក្នុងវិស័យនេះ សង្កាត់ព្រែកឬស្សី មានសាលាមត្តេយ្យឯកជន សាលាបឋមសិក្សា អនុវិទ្យាល័យឯកជន សាលាបណ្តុះបណ្តាលភាសាបរទេសឯកជន កុមារអាយុ ៦ឆ្នាំ បានចូលរៀន ១០០%។ ទន្ទឹមនឹងសក្តានុពលនេះ ការសិក្សារបស់កុមារក៏ពុំទទួលបានចំណេះដឹងស្មើគ្នាដែរ ដូច្នេះត្រូវបន្តពង្រឹងគុណភាពបង្រៀន និងរៀនគ្រប់កម្រិតសិក្សាឲ្យបានល្អប្រសើរ។

❖ **សុខាភិបាល៖** ភូមិសាស្ត្រសង្កាត់ព្រែកឬស្សី ស្ថិតនៅក្នុងទីប្រជុំជនរបស់ក្រុងតាខ្មៅ ខេត្តកណ្តាល ងាយស្រួលដល់ការទៅរកសេវាព្យាបាលផ្សេងៗ បានទាន់ពេលវេលា។ ស្ត្រីបានសម្រាលកូន

ដោយពេទ្យឆ្មបប្រកបដោយសុខសុវត្ថិភាព ចាក់វ៉ាក់សាំងបង្ការជំងឺ១១មុខ ដល់កុមារអាយុចាប់ពី ៩-១២ខែ បានគ្រប់ចំនួន ស្មើនឹង ១០០%។ ទន្ទឹមនឹងសក្តានុពលខាងលើនេះ យើងពិនិត្យឃើញមានបញ្ហាគ្រួសារមានសមាជិកកើតជំងឺអេដស៍មានចំនួន ២៤នាក់ នៃប្រជាជនសរុប។ បញ្ហាដែលកើតមានខាងលើនេះ ត្រូវបន្តយកចិត្តទុកដាក់បង្កើនការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងពីសុខភាពទូទៅ ជំងឺឆ្លង និងមិនឆ្លងនានាដែលកើតមានឡើងជាយថាហេតុ ដើម្បីរកសេវាព្យាបាលឱ្យបានទាន់ពេលវេលា។

❖ **យេនឌ័រ៖** ក្នុងវិស័យសេដ្ឋកិច្ច ស្ត្រីចំនួន ៤៥%មានមុខរបរចម្បងក្នុងផលិតកម្ម និងសេវាកម្ម ភាគរយស្ត្រីចេះអក្សរអាយុចាប់ពី ១៨-៤៥ឆ្នាំមានចំនួន១០០%បានចូលរួមធ្វើការសម្រេចចិត្តដូចបុរសនៅគ្រប់កិច្ចការសង្គម បានចូលរួមបម្រើការងារតាមមន្ទីរ អង្គភាព ក្រុមប្រឹក្សាក្រុង និងថ្នាក់ដឹកនាំភូមិ ក្នុងនោះស្ត្រី៣៣% បានធ្វើការនៅក្នុងក្រុមប្រឹក្សាសង្កាត់។ ទន្ទឹមនឹងចំនុចសកម្មខាងលើនេះ ស្ថានភាពយេនឌ័រមានបញ្ហាប្រឈមមួយចំនួនដូចជា នៅមានគ្រួសារខ្លះរប្រើអំពើហិង្សា ស្ត្រីប្រមាណ១%ធ្វើកចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ដូច្នេះ ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ច្បាប់ជួញដូរស្ត្រីនិងកុមារ ពង្រឹងការយល់ដឹងពីសិទ្ធិកុមារ បញ្ជ្រាបយេនឌ័រក្នុងផែនការសង្កាត់ និងអប់រំដល់ស្ត្រីអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។

❖ **អន្តោប្រវេសន៍និងការផ្លាស់លំនៅ៖** ដោយសង្កាត់ព្រែកឬស្សី ស្ថិតនៅជិតបង្កើយក្នុងក្រុងតាខ្មៅ និងក្រុងតាខ្មៅជាមជ្ឈមណ្ឌលសេដ្ឋកិច្ច ពាណិជ្ជកម្ម និងរដ្ឋបាលរបស់ខេត្តកណ្ដាល ហើយមានភូមិសាស្ត្រជាប់រាជធានីភ្នំពេញ មានរោងចក្រ សហគ្រាសខ្នាតតូច ធំៗ ជាច្រើន អាចផ្តល់ការងារច្រើនប្រភេទដល់ប្រជាពលរដ្ឋ កម្មករ ជាកត្តានាំឲ្យមានការបំលាស់ទីមកពីខេត្តផ្សេងទៀតៗ មកស្នាក់នៅដើម្បីប្រកបមុខរបររបស់ខ្លួន។ ទោះជាមានសក្តានុពលដូចខាងលើក្តី ក៏ប្រជាពលរដ្ឋក្នុងសង្កាត់ នៅមានការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ដូចនេះត្រូវយកចិត្តទុកដាក់អប់រំផ្សព្វផ្សាយការចំណាកស្រុកប្រកបដោយសុវត្ថិភាព មានវិធានការណ៍គ្រប់គ្រង ត្រួតពិនិត្យអ្នកស្នាក់នៅតាមផ្ទះជួល ឬអ្នកស្នាក់នៅផ្សេងៗទៀតឱ្យបានច្បាស់លាស់ ដើម្បីធានាបាននូវការអនុវត្តគោលនយោបាយ ភូមិ សង្កាត់ មានសុវត្ថិភាពល្អ។

**ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ៖** សង្កាត់ព្រែកឬស្សី មានផ្ទៃដី ២២៦.២០៩ហិកតា បែកចេញជា ៥ភូមិគឺ៖ *ភូមិក្រពើហា ភូមិក្រពើហាកើត ភូមិព្រែកឬស្សី ភូមិព្រែកឬស្សីលិច និងភូមិព្រែកអញ្ចាញ* មានប្រជាពលរដ្ឋរស់នៅសរុប ២.៣៣៧គ្រួសារ ចំនួនប្រជាពលរដ្ឋសរុប ១១.០១២នាក់ ស្រី ៦.៤៤៥នាក់ ដង់ស៊ីតេប្រជាជន ៤.៣២៣នាក់/គម២។ ។ ក្នុងផ្នែកនេះ សង្កាត់ព្រែកឬស្សី មានវិធានការណ៍ដូចខាងក្រោម៖

❖ **ការប្រើប្រាស់ដីធ្លី៖** សង្កាត់ព្រែកឬស្សី មានផ្ទៃដីសរុប ២២៦.២០៩ហិកតា បែងចែកចេញជា ៤ផ្នែកគឺ៖ ផ្ទៃដីលំនៅដ្ឋានសរុប១២៨,៧១២៧ហត ផ្ទៃដីស្រែសរុប៤៧,៧១២៨ហតដីចំការ ១៧.៥៧៧៣ហិកតានិងផ្ទៃដី ផ្សេងៗសរុប៣២,០២០៦២ហត ។ ផ្ទៃដីទាំងអស់ត្រូវបានចុះបញ្ជីច្បាស់លាស់ និងបានផ្តល់ប័ណ្ណកម្មសិទ្ធិសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ជូនដល់ប្រជាប្រើប្រាស់ជាបន្តបន្ទាប់ ។ ដីស្រែចំការមួយចំនួនធំត្រូវបានប្រែក្លាយជាដីលំនៅដ្ឋាន សហគ្រាស ប្រជាកសិករបានលក់ដីដើម្បីផ្លាស់ប្តូរមុខរបរដែលបណ្តាលឲ្យមុខរបរកសិកម្មថយចុះ។ ការប្រើប្រាស់ដីធ្លីនេះក៏មានបញ្ហាកើតឡើងផងដែរ ដូចជា ការសាងសង់សំណង់មិនទាន់មានរបៀបរៀបរយ មានសំណង់បណ្តោះអាសន្ននៅលើដីរដ្ឋដូចជានៅលើប្រឡាយ ចំណីស្ទឹង ព្រែក និងចញ្ចើមផ្លូវ។ល។ ធ្វើឲ្យជួបការលំបាកក្នុងការគ្រប់គ្រង ដើម្បីដោះ

ស្រាយបញ្ហានេះត្រូវយកចិត្តទុកដាក់ មានវិធានការណ៍ណែនាំដល់ប្រជាពលរដ្ឋ មកសុំច្បាប់សាងសង់នៅការិយាល័យច្រកចេញចូលតែមួយក្រុង តាខ្មៅនិងផ្សព្វផ្សាយច្បាប់ភូមិបាល។

❖ **ធនធានធម្មជាតិ៖** សង្កាត់ព្រែកឫស្សី មានស្ទឹង ព្រែក ជាកន្លែងផ្តល់នូវផលប្រយោជន៍សម្រាប់ប្រកបមុខរបរធ្វើកសិកម្ម និងដាំដំណាំផ្សេងៗ។ ប្រជាកសិករប្រមាណ៥,៥% ប្រកបរបរលើវិស័យកសិកម្ម និងប្រកបរបរផ្សេងៗទៀតសម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ ទន្ទឹមនឹងនោះ ក៏មានបញ្ហាប្រឈមដែលកើតមានឡើងដូចជា ទឹកស្ទឹងមានច្រើនតែរដូវវស្សាខ្វះខាតក្នុងរដូវប្រាំង ទឹកស្ទឹងមានភាពកខ្វក់ដោយមានការហូរចូលទឹកសំអុយពីរាជធានីភ្នំពេញ ប្រជាពលរដ្ឋមិនអាចយកទឹកនេះមកប្រើប្រាស់បានម្យ៉ាងទៀត ប្រជាពលរដ្ឋមួយចំនួនខ្វះការយល់ដឹងពីការគ្រប់គ្រងការថែរក្សាធនធានធម្មជាតិ មានការបោះសំរាមនិងបង្ហូរកាកសំណល់ផ្សេងៗចូលក្នុង ស្ទឹង ព្រែក ដូច្នេះត្រូវធ្វើការអប់រំផ្សព្វផ្សាយពីច្បាប់បរិស្ថាន។

❖ **បរិស្ថាន៖** ចំនួនគ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះ សរុបចំនួន ១២០៨គ្រួសារ ស្មើនឹង ៥៣,៦៤%នៃគ្រួសារសរុប ។ ទន្ទឹមនឹងនោះក៏មានបញ្ហាមួយចំនួនគឺ សំរាមនៅតែមានរាយប៉ាយ កាកសំណល់ផ្សេងៗ ប្រជាពលរដ្ឋមួយចំនួនបានយកមកចោលនៅទីសាធារណៈ បោះចូលក្នុងទឹកស្ទឹង និងប្រជាពលរដ្ឋមួយចំនួនទៀតមិនទាន់មានការយល់ដឹងពីការគ្រប់គ្រងកាកសំណល់ឲ្យបានត្រឹមត្រូវ នាំឲ្យមានផលប៉ះពាល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ ម្យ៉ាងទៀត សេវាប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ិនទ្រី មិនទាន់បានពង្រីកការប្រមូលនៅតាមខ្នងផ្ទះប្រជាពលរដ្ឋគ្រប់ចំនួននៅឡើយ។ ដូចនេះ ត្រូវយកចិត្តទុកដាក់បង្កើនរថយន្តដឹកសំរាម ទំនាក់ទំនងរកដៃគូកែច្នៃសំណល់ប្រើប្រាស់ឡើងវិញ បន្ថែមការដាក់ស្លាកសញ្ញាហាមឃាត់ការចាក់សំរាម បន្តអប់រំផ្សព្វផ្សាយច្បាប់បរិស្ថានដល់ប្រជាពលរដ្ឋក្នុងសង្កាត់ឲ្យបានយល់ដឹងគ្រប់ៗគ្នា និងអនុវត្តនូវវិធានការណ៍រដ្ឋបាលផាកពិន័យតាមច្បាប់កំណត់។

❖ **គ្រោះមហន្តរាយសំខាន់ៗ៖** យោងតាមរបាយការណ៍គ្រោះមហន្តរាយប្រចាំឆ្នាំ២០១៨ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល សង្កាត់ព្រែកឫស្សី បានទទួលរងនូវគ្រោះមហន្តរាយធម្មជាតិបង្កឡើងដោយគ្រោះទឹកជំនន់ចំនួន ១លើក សរុបគ្រួសាររងគ្រោះចំនួន ៥គ្រួសារ គ្រួសារដែលខូចខាតផ្ទះសម្បែង មិនអាចរស់នៅបាន ត្រូវការបំលាស់ទីជាបន្ទាន់មានចំនួន ៥គ្រួសារ។ ដូចនេះ ត្រូវបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ ចាត់វិធានការណ៍ការពារ និងត្រៀមលក្ខណៈសម្បត្តិដើម្បីឆ្លើយតប ដោះស្រាយបន្ទាន់ចំពោះផលប៉ះពាល់ ដែលបង្កឡើងដោយថាហេតុដោយគ្រោះមហន្តរាយ។

❖ **ការប្រែប្រួលអាកាសធាតុ៖** ភូមិសាស្ត្រសង្កាត់ព្រែកឫស្សី មានស្ទឹងព្រែកត្នោតហូរឆ្លងកាត់ ដែលជាកត្តាងាយរងគ្រោះដោយទឹកជំនន់ជាញឹកញាប់ ការបាក់ច្រាំងនៅក្នុងរដូវវស្សា ជាពិសេសមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋដែលមានលំនៅដ្ឋានតាមមាត់ស្ទឹង ជាក់ស្តែងក្នុងខែសីហា ឆ្នាំ២០១៨ មានករណីរងគ្រោះដោយទឹកជំនន់ ១លើក ។ អាកាសធាតុមានការប្រែប្រួល រដូវខ្លះមានការក្តៅខ្លាំង និងរដូវខ្លះទៀតត្រជាក់ខ្លាំង ដូច្នេះ ត្រូវយកចិត្តទុកដាក់ធ្វើរបាំងការពារច្រាំងស្ទឹងត្រង់ចំណុចទឹកហូរបុក និងផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងជីវជ្ជ វិធានការណ៍ការពារផ្សេងៗ ដល់ប្រជាពលរដ្ឋដែលស្នាក់នៅតាមតំបន់ងាយរងគ្រោះដើម្បីចៀសវាងគ្រោះថ្នាក់កើតឡើងដោយថាហេតុ និងអប់រំបញ្ហាសុខភាពដល់ប្រជាពលរដ្ឋនៅពេលមានបញ្ហាអាកាសធាតុប្រែប្រួលនានា។

## ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

❖ ក្រោមការដឹកនាំប្រកបដោយប្រាជ្ញាឈ្លាសវៃ និងកត្តិបណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងក្រោមការដឹកនាំ ណែនាំដោយផ្ទាល់របស់ ឯកឧត្តម **គង់ សោភ័ណ្ឌ អភិបាល** នៃគណៈអភិបាលខេត្តកណ្តាល ថ្នាក់ដឹកនាំខេត្ត មន្ទីរអង្គភាពនានាជុំវិញខេត្ត និង គណៈអភិបាលក្រុងតាខ្មៅ ធ្វើឱ្យសង្កាត់ព្រែកឫស្សី មានការរីកចំរើនទៅមុខជាលំដាប់ ដោយបានបម្រើផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋឥតឈប់ឈរពីមួយអាណត្តិទៅមួយអាណត្តិ រាល់ការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលសង្កាត់ គឺមានការចូលរួមពីប្រជាពលរដ្ឋ គោរពតាមច្បាប់របស់រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីណែនាំផ្សេងៗទៀត ប្រកបដោយតម្លាភាព មានការព្រមព្រៀងឯកភាពគ្នាមានសមធម៌ មានគណនេយ្យភាព និងមានការឆ្លើយតបតាមតម្រូវការមូលដ្ឋានបានទាន់ពេលវេលា ក្នុងនោះរដ្ឋបាលសង្កាត់ព្រែកឫស្សី មានការគ្រប់គ្រងដូចខាងក្រោម៖.

❖ **អភិបាលកិច្ច៖** ការដឹកនាំគ្រប់គ្រងរបស់អាជ្ញាធរសង្កាត់ បានបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋ អនុវត្តបានល្អទៅតាមគោលការណ៍នៃអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងការផ្តល់សេវារដ្ឋបាលលើផ្នែកអត្រានុកូលមួយចំនួនជូនប្រជាពលរដ្ឋ មិនតម្រូវឱ្យគិតកម្រៃសេវាឡើយ ដូចជា អត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ មរណភាព ការធ្វើនិងផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និងសេវារដ្ឋបាលមួយចំនួនទៀតមានការកំណត់លើតារាងសេវាតម្លៃរដ្ឋបាលច្បាស់លាស់ដែលតម្រូវឱ្យអ្នកស្នើសុំទៅធ្វើនៅការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ។ ទន្ទឹមនឹងនេះ ក៏នៅមានបញ្ហាលំបាកខ្លះក្នុងការគ្រប់គ្រងផ្នែកស្ថិតិនេះដែរ ដោយម្ចាស់អាជីវកម្ម សេវាកម្មខ្លះមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់នៅឡើយ ដូចនេះ ត្រូវបន្តផ្សព្វផ្សាយព័ត៌មានអំពីសេវារដ្ឋបាលផ្សេងៗ ដែលលើសពីសមត្ថកិច្ចរបស់សង្កាត់ ឱ្យទៅសុំនៅការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅដើម្បីចូលរួមអនុវត្តច្បាប់ទាំងអស់គ្នា។

❖ **ការគ្រប់គ្រងដែនដី៖** សង្កាត់ព្រែកឫស្សី លើការគ្រប់គ្រងរដ្ឋបាលសង្កាត់ បែងចែកជា៥ភូមិគឺ៖ ភូមិក្រពើហា ភូមិក្រពើហាកើត ភូមិព្រែកឫស្សី ភូមិព្រែកឫស្សីលិច និងភូមិព្រែកអញ្ចាញ។ គ្រួសារដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីសរុបចំនួន ២៥៧៣គ្រួសារ និងឈានទៅដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ជូនដល់ប្រជាប្រើប្រាស់ឱ្យបានគ្រប់ៗគ្នា។ ទោះបីជាមានការគ្រប់គ្រងដែនដី ដូចរៀបរាប់ខាងលើនេះក្តី ក៏នូវមានករណីទំនាស់ដីធ្លីកើតឡើងជាញឹកញាប់ផងដែរ ជាក់ស្តែងដូចជាក្នុងឆ្នាំ២០១៧ ករណីទំនាស់ដីធ្លីកើតមានដល់ទៅ ៣ករណី ដូចនេះត្រូវបន្តអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពី ច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀត ក៏ដូចជាការផ្សព្វផ្សាយការងារចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ។

❖ **ការគ្រប់គ្រងស្ថិតិ៖** រដ្ឋបាលសង្កាត់ព្រែកឫស្សី បានអនុវត្តគោលការណ៍ណែនាំថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីប្រកាសអន្តរក្រសួងលេខ១៤៣៤២ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្តីពីការផ្តល់ថវិកាវង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាល់ការចុះបញ្ជីអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ជូនប្រជាពលរដ្ឋយកទៅប្រើប្រាស់ស្របច្បាប់ ជាក់ស្តែងក្នុងឆ្នាំ២០១៧ កុមារអាយុក្រោម ៥ឆ្នាំ ចុះសំបុត្រកំណើតបានចំនួន 260នាក់ ស្មើនឹង ១០០%។

❖ **ការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** សង្កាត់ព្រែកឬស្សី បានបង្កើតគណៈបញ្ជាការឯកភាពរដ្ឋបាលសង្កាត់ ក្រោមការដឹកនាំផ្ទាល់របស់ **លោកឆេង ឆៃ** ចៅសង្កាត់ព្រែកឬស្សី និងជាប្រធានគណៈបញ្ជាការឯភាពរដ្ឋបាលសង្កាត់ មានការចូលរួមពីកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ ភូមិ និងប្រជាការពារភូមិ ដើម្បីទទួលផែនការអនុវត្តការងារគោលនយោបាយ តាមគោលការណ៍ ៩យ៉ាង នៃលក្ខណៈសម្បត្តិភូមិ សង្កាត់មានសុវត្ថិភាព ដឹកនាំគ្រប់គ្រងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ធានាបាននូវសន្តិសុខ និងសុខសុវត្ថិភាពល្អជូនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ ក៏មានបញ្ហាប៉ះពាល់មួយចំនួនកើតឡើងផងដែរដូចជា ជាក់ស្តែងក្នុងឆ្នាំ២០២០ អំពើហិង្សាក្នុងគ្រួសារកើតឡើង ១ករណី សមាជិកគ្រួសារមានការប្រើប្រាស់គ្រឿងញៀន ១៥នាក់ លួច ១ករណី គ្រោះថ្នាក់ចរាចរណ៍៤ករណីរបួសធ្ងន់ចំនួន ៣នាក់ស្រាល១នាក់ ល្បែងស៊ីសងនានាកើតឡើងលួចលាក់ និងការដាក់តាំងសម្ភារ លក់ដូរផ្សេងៗ ហៀរមកលើចិញ្ចើមផ្លូវសាធារណៈជាដើម ដូចនេះត្រូវបន្តយកចិត្តទុកដាក់ ពង្រឹងការអនុវត្តគោលនយោបាយភូមិ សង្កាត់ មានសុវត្ថិភាព បង្កើនការអប់រំផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក បន្ថែមភ្លើងបំភ្លឺផ្លូវសាធារណៈ ភ្លើងស្តុប ដាក់ភ្លើងសញ្ញាចរាចរណ៍ គូសគំនូសសញ្ញាចរាចរណ៍ បំពាក់កាមេរ៉ាសុវត្ថិភាពនៅទីតាំងស្តុបផ្លូវសំខាន់ៗ ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ ច្បាប់គ្រឿងញៀន មានវិធានការណ៍អប់រំ ផាកពិន័យដល់អ្នកប្រព្រឹត្តល្មើសច្បាប់ជាដើម។ល។

## ជំពូកទី២
## គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល

២.១. **តារាងសង្ខេបប្រភពមូលនិធិ៖** ប្រជាពលរដ្ឋសង្កាត់ព្រែកឬស្សី ចង់បានការអភិវឌ្ឍន៍លើគ្រប់វិស័យ មានជីវភាពល្អប្រសើរឡើង ទទួលបាននូវសេវាសុខុមាលភាពសង្គម មានចំណេះដឹងខ្ពស់ រស់នៅប្រកបដោយបរិស្ថានស្អាត មានសុខសុវត្ថិភាព សុខដុមនីយកម្មក្នុងមូលដ្ឋាន ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**តារាង២.១ ៖ សង្ខេបប្រភពមូលនិធិឆ្នាំ២០២១**

| ល.រ | ស្ថាប័ន | ចំនួនគម្រោងសកម្មភាព (លានរៀល) | សរុបតម្លៃគម្រោងសកម្មភាព | ប្រភពមូលនិធិ | ចំនួនគម្រោងសកម្មភាព | តម្លៃគម្រោងសកម្មភាព (លានរៀល) |
|---|---|---|---|---|---|---|
| ១ | រដ្ឋបាលសង្កាត់ព្រែកឬស្សី | ០១គម្រោង | ២៨០,000,000 | សង្កាត់<br>ដៃគូអភិវឌ្ឍន៍<br>សប្បុរសជន | ០១គម្រោង | ២៨០ |
| ២ | ការគាំទ្រពីមន្ទីរអង្គភាព | | | | | |
| ២.១ | មន្ទីរសុខាភិបាល | ១០គម្រោង | 67,730,000 | មន្ទីរ<br>ដៃគូអភិវឌ្ឍន៍ | ១០គម្រោង | 67,73 |
| | | | | មន្ទីរ<br>ដៃគូអភិវឌ្ឍន៍ | | |
| | សរុបមន្ទីរអង្គភាព/ | ១១គម្រោង | 347,730,000 | មន្ទីរ<br>ដៃគូអភិវឌ្ឍន៍ | ១១គម្រោង | 347,73 |
| ៣ | ការគាំទ្រពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ | | | | | |
| ៣.១ | អង្គការ................................ | 0 | 0 | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣.២ | ដៃគូអភិវឌ្ឍន៍...................... | 0 | 0 | | | |
| ៣.៣ | អ្នកពាក់ព័ន្ធ.......................... | 0 | 0 | | | |
| សរុបអង្គការ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ | | 0 | 0 | | | 0 |
| សរុបរួម(៣+២+១) | | ១១គម្រោង | 347,730,000 | | | 347,73 |

## តារាង២.២ ៖ គម្រោង សកម្មភាពសង្កាត់កំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | កំរិតទុនវិនិយោគ(លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| ១.ផ្នែកសេដ្ឋកិច្ច ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ២.ផ្នែកសង្គមកិច្ច ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៤.ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |

## តារាង២.៣ ៖ គម្រោង សកម្មភាពសង្កាត់ដែលមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេល | តម្លៃគម្រោង | ប្រភពមូលនិធិ | កំរិតទុនវិនិយោគ(លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | អនុវត្ត | | | ២០២២ | ២០២៣ | ២០២៤ | សរុប | | |
| គម្រោង សកម្មភាពប្រើប្រាស់មូលនិធិសង្កាត់ | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| ១. | ផ្លូវចាក់បេតុងអាមេ | ក្រពើហា ព្រៃកអញ្ចាញ | ១៣៧៥ | ម | ៣ឆ្នាំ | ៥៣៩.២ | សង្កាត់ | ២៨០ | ១២០ | ១៣៩.២ | ៥៣៩.២ | សង្កាត់ព្រៃកឬស្សី | |
| ២.ផ្នែកសង្គមកិច្ច ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ៖ | | | | | | | | | | | | | |
| ១ | កសាងលូរំដោះទឹក | ភូមិក្រពើហាកើត ក្រពើហា ភូមិព្រៃកឬស្សី ភូមិព្រៃកអញ្ចាញ | ១៦៧០ | ម | ២ឆ្នាំ | ៤៧៣.២ | សង្កាត់ | | ១៨៤.៨ | ២៨៨.៤ | ៤៧៣.២ | សង្កាត់ព្រៃកឬស្សី | |
| ៤.ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| គម្រោង សកម្មភាព ដែលទទួលបានការសន្យាគាំទ្រមូលនិធិពីអ្នកពាក់ព័ន្ធ | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច ៖ គ្មាន | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ២.ផ្នែកសង្គមកិច្ច | | | | | | | | | | | | | |
| ១ | ផ្តល់វ៉ាក់សាំងការពារជម្ងឺ១២មុខ ដល់កុមារអាយុក្រោម១ឆ្នាំ និងថ្នាំបង្ការជម្ងឺតេតាណូសដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រី | ម.ស | ៩០ | % | ១ឆ្នាំ | 2,83 | រដ្ឋ/GAVI | 2,83 | 0 | 0 | 2,83 | មន្ទីរសុខាភិបាល | |
| ២ | ការផ្តល់សេវាសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែល | ម.ព | ៩០ | % | ១ឆ្នាំ | 8,1 | រដ្ឋ | 8,1 | 0 | 0 | 8,1 | មន្ទីរសុខាភិបាល | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បានបណ្ដុះបណ្ដាលនៅមូលដ្ឋានសុខាភិបាល (RH,HC) | ម.ស | | | | | | | | | | | |
| កម្មវិធីពន្យាកំណើត | ម.ស | ៩០ | % | ១ឆ្នាំ | 1,1 | រដ្ឋ/UNFPA | 1,1 | 0 | 0 | 1,1 | មន្ទីរសុខាភិបាល | |
| សេវាសុខភាពស្ត្រីមានផ្ទៃពោះ | ម.ស សហគមន៍ | ៩០ | % | ១ឆ្នាំ | 1,1 | រដ្ឋ/UNFPA | 1,1 | 0 | 0 | 1,1 | មន្ទីរសុខាភិបាល | |
| សកម្មភាពបង្ការ ថែទាំ និងព្យាបាលជម្ងឺអេដស៍ | ម.ព ម.ស | ៩០ | % | ១ឆ្នាំ | 1 | រដ្ឋ/មូលនិធិសកល | 1 | 0 | 0 | 1 | មន្ទីរសុខាភិបាល | |
| សកម្មភាពស្រាវជ្រាវនិងទប់ស្កាត់ការឆ្លងរាលដាលជម្ងឺរបេង | ម.ព ម.ស | ៩៥ | % | ១ឆ្នាំ | 5 | មូលនិធិសកល/CHC | 5 | 0 | 0 | 5 | មន្ទីរសុខាភិបាល | |
